ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ផលប្រយោជន៍នៃការរៀបចំគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

THE BENEFITS OF PREPARING ACCOUNTING POLICIES OF PHNOM PHENH WATER SUPPLY AUTHORITY

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH, 2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY


# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ផលប្រយោជន៍នៃការរៀបចំគោលនយោបាយ គណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## THE BENEFITS OF PREPARING ACCOUNTING POLICIES OF PHNOM PHENH WATER SUPPLY AUTHORITY

**គ្រូណែនាំ៖ ហ៊ីង សុខសាន្ត**

**ជំនាញ: គណនេយ្យ**

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH, 2025

# គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២

# ប្រធានបទៈ ផលប្រយោជន៍នៃការរៀបចំគោលនយោបាយគណនេយ្យ

# របស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ហ៊ីង សុខសាន្ត

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉េម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យនៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល៤ឆ្នាំនៃការសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេស ក្រុមយើងខ្ញុំបានយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមានសារៈសំខាន់មួយដែរ សម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តន៏កិច្ចការគណនេយ្យដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗ ដែលពាក់ព័ន្ធនឹងការងារគណនេយ្យ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យបានយល់ច្បាស់ ពីការអនុវត្តការងារគណនេយ្យពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យវាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតប ឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **”ផលប្រយោជន៍នៃការរៀបចំគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ”** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការធ្វើម៉ាឃីតធីង។ ក្រុមយើងខ្ញុំសង្ឃឹមថា ការរៀបចំសារណាមួយនេះឡើងនឹងបានចូលរួមចំណែកមួយក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានគោលបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



**កេង សុជាត្តា**

ID B22/2415



**ឆឹម លីណា**

ID Moeys22/050



**ទ្រី គីមលាង**

ID B22/2416



**ចែម និតា**

ID B22/2252



**ឡី សុខាលាភ**

ID B22/1794

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជម្រុញលើកទឹកចិត្តដល់ក្រុមយើងខ្ញុំក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតដល់អ្នកមានគុណដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បណ្តាសាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** ជាសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។ សូមគោរពថ្លែងអំណរគុណចំពោះសាស្រ្តាចារ្យ **ហ៊ីង សុខសាន្ត** ជាសាស្រ្តាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្រ្តាចារ្យនិងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំរហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២ វគ្គ៣សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទស្តីអំពី "**ផលប្រយោជន៍នៃការរៀបចំគោលនយោបាយគណនេយ្យចំពោះក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**" នេះ គឺពិតជាស្នាដៃមួយរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវ ដែលបានលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ.ពុធ..៨កើត.. ខែ.កត្តិក. ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ថ្ងៃទី.២៩.. ខែ.តុលា. ឆ្នាំ២០២៥
**ហត្ថលេខាតំណាងក្រុម**

កេង សុជាត្តា

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ជាក្រុមហ៊ុនដែលផ្គត់ផ្គង់សេវាទឹកស្អាតយូរមកហើយនៅក្នុងប្រទេសកម្ពុជាដែលបានចាប់បដិសន្ធិឡើងតាំងពីឆ្នាំ១៩៥៩ និងដោយមានការតែងតាំង ជាផ្លូវការតាម ព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាលេខ ១៦៤នស ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៦០ ជាអង្គភាពផលិតកម្ម និង អាជីវកម្ម របស់រដ្ឋចំណុះផ្ទាល់សាលាក្រុងភ្នំពេញ ហើយដែលបានប្រសិទ្ធនាមជាផ្លូវការថា «រដ្ឋាករទឹកភ្នំពេញ»។ អង្គភាពនេះ មានភារកិច្ចផលិតទឹកស្អាតនិងផ្គត់ផ្គង់បម្រើសំណូមពរប្រើប្រាស់របស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញព្រមទាំងធានាតុល្យភាពចំណូលចំណាយលើការងារ ផលិតកម្ម និងវិនិយោគ។

ឆ្លងកាត់ការវិវត្តឥតឈប់ឈរពីសម័យកាលមួយទៅសម័យកាលមួយ ទើបនៅឆ្នាំ១៩៩៦ អង្គភាពនេះត្រូវបានប្រកាសតែងតាំងដោយប្រសិទ្ធនាមជាថ្មីថា «រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ» ជាគ្រឹះស្ថានសាធារណៈមួយមានចរឹកជាគ្រឹះស្ថានឧស្សាហកម្ម និងពាណិជ្ជកម្ម តាមអនុក្រឹតលេខ០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

ឈរលើមូលដ្ឋាន ដែលជាកត្តានៅក្នុងការស្រាវជ្រាវ និងចងក្រងសារណាមួយនេះឡើង គឺស្វែងយល់អំពីចំណុចសំខាន់ៗនៃ ការរៀបចំគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញក្នុងការអនុវត្តទៅតាមគោលការណ៍ ស្តង់ដាគណនេយ្យផ្តល់នូវទិដ្ឋភាពពិត យុត្តិធម៌នៃដំណើរការ និងមុខតំណែងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ អ្នករៀបចំគោលនយោបាយគណនេយ្យត្រូវមានជំនាញមូលដ្ឋាន និងជំនាញបច្ចេកទេសដើម្បីប្រតិបត្តិការងារ។ ទំនួលខុសត្រូវគណនេយ្យកររួមមាន ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុត្រួតពិនិត្យ ការរក្សាកំណត់ត្រា ធ្វើការណែនាំ ដល់អ្នកដឹកនាំអាជីវកម្ម ស្វែងរកវិធីកាត់បន្ថយហានិភ័យរៀបចំការបង់ពន្ធ និងការប្រកាន់ខ្ជាប់នូវតម្រូវការបទប្បញ្ញត្តិរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញគណនេយ្យកររបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមានការវិភាគខ្លាំងដើម្បីពិនិត្យនិងដោះស្រាយបញ្ហាការងារបានយ៉ាងរលូនជាមួយនឹងបទពិសោធន៍ការងារជាច្រើនឆ្នាំ។ គណនេយ្យករមានទំនាក់ទំនងល្អជាមួយផ្នែកផ្សេងៗ និងការសហការគ្នាទៅវិញទៅមក។ លើសពីនេះគណនេយ្យករប្រកាន់ខ្ជាប់នូវកាតព្វកិច្ចផ្លូវច្បាប់ក្នុងការធ្វើសកម្មភាពដោយស្មោះត្រង់ និងជៀសវាងការឆ្វេសប្រហែស។

បន្ទាប់ពីធ្វើការស្រាវជ្រាវអំពី ការរៀបចំគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញរួចមក នាងខ្ញុំសង្កេតឃើញថា មានការរៀបចំបុគ្គលិកឱ្យកាន់តួនាទីរបស់ខ្លួនទៅតាមមុខងារនីមួយៗ ដែលសាកសមនឹងសមត្ថភាពរបស់បុគ្គលិកដែលធ្វើឱ្យការងារប្រកបទៅដោយភាពក្រឹត្យក្រម។ ការរៀបចំគោលនយោបាយគណនេយ្យ នៅក្នុងក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ជានានូវភាពត្រឹមត្រូវនៃឯកសារហិរញ្ញវត្ថុ ក៏ដូចជាការអនុលោមតាមច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធ រៀបចំរក្សារបាយការណ៍ហិរញ្ញវត្ថុសំខាន់ៗ។

# មាតិកា

ទំព័រ

អារម្ភកថា ........ i
រចនាសម្ព័ន្ធ ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v
មាតិកា ........ vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១
១. តើផែនការនៃការរៀបចំគោលនយោបាយគណនេយ្យរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមានលក្ខណៈដូចម្តេច?
២. តើការរៀបចំគោលនយោបាយគណនេយ្យផ្តល់ផលប្រយោជន៍អ្វីខ្លះ ដល់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ?
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៤.១ ទំហំ និងដែនកំណត់ ........ ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ២
១.៥.១ ការប្រមូលទិន្នន័យដំបូង ........ ៣
១.៥.២ ការប្រមូលទិន្នន័យបន្ទាប់ ........ ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

## ជំពូកទី២
## ផលប្រយោជន៍នៃការរៀបចំគោលនយោបាយគណនេយ្យ

២.១ លក្ខណៈទូទៅនៃគណនេយ្យ ........ ៤
២.១.១ និយមន័យគណនេយ្យ ........ ៤
២.១.២ ប្រវត្តិនៃគណនេយ្យ ........ ៤
២.១.៣ ទ្រឹស្តីនៃគណនេយ្យ ........ ៥
២.២ ផែនការនៃការរៀបចំគោលនយោបាយគណនេយ្យ ........ ៦

២.២.១ និយមន័យនៃផែនការ ........ ៧
២.២.២ ប្រវត្តិនៃផែនការ ........ ៧
២.២.៣ ទ្រឹស្តីនៃផែនការ ........ ៧
២.៣ ផលប្រយោជន៍នៃការរៀបចំគោលនយោបាយគណនេយ្យ ........ ៧
២.៣.១ និយមន័យគោលនយោបាយ ........ ៧
២.៣.២ ប្រវត្តិនៃគោលនយោបាយ ........ ៨
២.៣.៣ ទ្រឹស្តីនៃគោលនយោបាយ ........ ៨

## ជំពូកទី៣
## ផលប្រយោជន៍នៃការរៀបចំគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

៣.១ ស្ថានភាពទូទៅរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ........ ១០
៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន ........ ១០
៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ........ ១៤
ក. ចក្ខុវិស័យ ........ ១៤
ខ. បេសកកម្ម ........ ១៤
គ. គោលដៅ ........ ១៤
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រងតួនាទី និងភារកិច្ចរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ... ១៥
៣.២ ផែនការនៃការរៀបចំគោលនយោបាយគណនេយ្យរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ........ ១៦
៣.២.១ តួនាទីនៃការរៀបចំគោលនយោបាយរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ...... ១៦
៣.២.២ មុខងារនៃការរៀបគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ ........ ២១
៣. ប្រព័ន្ធគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ ........ ២១
៤. ការរៀបចំរបាយការណ៍ហិញ្ញវត្ថុ ........ ២៧
ក. របាយការណ៍តុល្យការ ........ ២២
ខ. របាយការណ៍លទ្ធផល ........ ២៤
គ. របាយការណ៍លំហូរសាច់ប្រាក់ ........ ២៥
ឃ. របាយការណ៍បម្រែបម្រួលមូលធន ........ ២៧
គ. កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ........ ២៨
៣.៣ ការរៀបចំគោលនយោបាយគណនេយ្យផ្តល់ផលប្រយោជន៍ដល់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ ........ ៣៦
៣.៣.១ មូលដ្ឋាននៃការរៀបចំគោលនយោបាយគណនេយ្យ ........ ៣៧
៣.៣.២ វិធីសាស្រ្តក្នុងការរៀបចំគោលនយោបាយគណនេយ្យ ........ ៣៧
៣.៣.៣ លទ្ធផលនៃការរៀបចំគោលនយោបាយគណនេយ្យ ........ ៣៨

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង........................................................................................ ៣៩
៤.២ ការវិភាគលើចំណុចខ្សោយ...................................................................................... ៣៩

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន .........................................................................................................៤១
៥.២ ការផ្តល់អនុសាសន៍ ....................................................................................................៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នាពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថាក្រុមហ៊ុនមួយចំនួននៅប្រទេសកម្ពុជា កំពុងតែមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់។ ការរីកចម្រើនយ៉ាងឆាប់រហ័សទាំងនេះដោយសារតែក្រុមហ៊ុនមួយចំនួនមានការរៀបចំផែនការ និងគោលនយោបាយគណនេយ្យរបស់ខ្លួនបានច្បាស់លាស់ប្រកបដោយស្តង់ដាដែលអាចជឿទុកចិត្តបាន ព្រមទាំងបានបង្ហាញនៅរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ និងសមរម្យ។ ដូចនេះការរៀបចំផែនការ និងគោលនយោបាយគណនេយ្យទាំងនេះរួមមានៈ ការគ្រប់គ្រងលើរបាយការហិរញ្ញវត្ថុ កំណត់ទៅលើប្រាក់ចំណូល ចំណាយ និងកំណត់លើប្រតិបត្តិការសាច់ប្រាក់ជាដើម។ ម្យ៉ាងវិញទៀត នៅពេលដែលមានការរៀបចំ និងបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុបានត្រឹមត្រូវ គឺមិនត្រឹមតែជាសកម្មភាពច្បាស់លាស់នោះទេ ប៉ុន្តែវាក៏ជាផ្នែកមួយយ៉ាងសំខាន់នៃការអភិវឌ្ឍឱ្យក្រុមហ៊ុនកាន់តែមានភាពជោគជ័យបន្ថែមទៀត។

ជាក់ស្តែង ក្នុងពេលបច្ចុប្បន្នការរៀបចំផែនការនៃគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនពិតជាមានសារៈសំខាន់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីធានាបាននូវភាពស៊ីសង្វាក់គ្នាភាពអាចប្រៀបធៀបបាន និងភាពត្រឹមត្រូវនៃព័ត៌មានហិរញ្ញវត្ថុទៅតាមការិយបរិច្ឆេទ និងក្រុមហ៊ុនផ្សេងៗគ្នា។ ដូច្នេះ នៅក្នុងក្រុមហ៊ុនមួយដែលអាចដំណើរការបានយ៉ាងរលូន មិនថាឡើយក្នុងអង្គភាពក្តី ឬក្រៅអង្គភាពក្តីចំពោះផ្នែកគណនេយ្យនៅក្នុងក្រុមហ៊ុន គឺមានតួនាទីសំខាន់ណាស់ក្នុងការរៀបចំ និងត្រួតពិនិត្យទៅលើរបាយការណ៍ហិរញ្ញវត្ថុពន្ធ ឬធ្វើគម្រោងថវិកាផ្សេងៗទៀត។ ការត្រួតពិនិត្យទៅលើរបាយការណ៍ហិរញ្ញវត្ថុ គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការការពារក្រុមហ៊ុនពីហានិភ័យផ្សេងៗ។ បន្ថែមលើនេះ ទៅទៀតក្រុមហ៊ុនក៏ចាំបាច់ត្រូវតែធ្វើការរៀបចំប្រព័ន្ធគ្រប់គ្រងគណនេយ្យជារៀងរាល់ឆ្នាំ ដើម្បីការពារបញ្ហាផ្សេងៗ ដែលកើតឡើងដោយថាហេតុណាមួយ គេតែងតែគិតគូរដល់វាជានិច្ចមិនថាអ្នកប្រើប្រាស់ខាងក្នុង និងអ្នកប្រើប្រាស់ខាងក្រៅនោះឡើយ។

ដោយមើលឃើញនូវបញ្ហាបែបនេះហើយ ទើបក្រុមនាងខ្ញុំបានសម្រេចចិត្តធ្វើការជ្រើសរើសយកនូវប្រធានបទមួយស្តីពី «**ផលប្រយោជន៍នៃការរៀបចំគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** (The Benefit Accounting Of Phnom Penh Water Supply Authority)» យកមកធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំជារបាយការណ៍សម្រាប់ទុកឱ្យនិស្សិតជំនាន់ក្រោយៗបានសិក្សាស្រាវជ្រាវបន្ត។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការរៀបចំគោលនយោបាយគណនេយ្យមានសារៈសំខាន់ណាស់ សម្រាប់ធ្វើឱ្យក្រុមហ៊ុនមួយកាន់តែមានភាពជោគជ័យ ព្រោះវិនិយោគិនមុននឹងធ្វើការសម្រេចចិត្តវិនិយោគក្នុងក្រុមហ៊ុនមួយ ពួកគេត្រូវការព័ត៌មានហិរញ្ញវត្ថុលម្អិតរបស់ក្រុមហ៊ុននោះ ដើម្បីធ្វើសេចក្តីសម្រេចចិត្តក្នុងការបណ្តាក់ទុន។ ដូច្នេះក្រុមហ៊ុននីមួយៗត្រូវរៀបចំគោលនយោបាយគណនេយ្យឱ្យត្រឹមត្រូវ រួមទាំងមានការបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុ ដែលមានភាពប្រាកដច្បាស់លាស់របស់ខ្លួន ដោយអនុលោមទៅតាមគោលការណ៍គណនេយ្យរបស់អន្តរជាតិ ដើម្បី

ជាទំនុកចិត្តរបស់វិនិយោគិន ព្រមទាំងអ្នកគ្រប់គ្រងក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ ហេតុដូច្នេះ នៅក្នុងកិច្ចសិក្សាស្រាវជ្រាវរបស់ក្រុមនាងខ្ញុំនិងបកស្រាយទៅលើសំណួរដូចខាងក្រោម៖

១.តើផែនការនៃការរៀបចំគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមានលក្ខណៈដូចម្តេច?

២.តើការរៀបចំគោលនយោបាយគណនេយ្យផ្តល់ផលប្រយោជន៍អ្វីខ្លះ ដល់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវនេះ គឺដើម្បីយល់ដឹងឱ្យកាន់តែច្បាស់អំពីការអនុវត្តជាក់ស្តែង ទុកសម្រាប់ជាទុនក្នុងការរៀបចំរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សារបស់ក្រុមនាងខ្ញុំ។ នៅក្នុងការសិក្សាស្រាវជ្រាវមួយនេះបានផ្តោតសំខាន់លើការយកចិត្តទុកដាក់ចំណុចសំខាន់ៗដូចជា៖

- ដើម្បីយល់ពីសំណុំនៃវិធាន និងផែនការដែលក្រុមហ៊ុនប្រើប្រាស់ដើម្បីរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- ស្វែងយល់ពីទ្រឹស្តី និងនិយមន័យមនៃការវិភាគការរៀបចំគោលនយោបាយគណនេយ្យ
- និយាយពីប្រវត្តិ និងស្ថានភាពទូទៅរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បង្ហាញពីភាពខ្លាំង និងភាពខ្សោយរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- ការបង្ហាញពីគោលនយោបាយ ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- ធ្វើការប្រៀបធៀបដោយផ្សារភ្ជាប់ទ្រឹស្តី និងការអនុវត្ត
- ជាមួយការសន្និដ្ឋាន និងអនុសាសន៍។

## ១.៤ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

### ១.៤.១ ទំហំនៃដែនកំណត់

ក្នុងការសិក្សាស្រាវជ្រាវនេះ មានប្រសិទ្ធភាពគឺផ្តោតសំខាន់ទៅលើតែប្រធានបទ «**ផលប្រយោជន៍នៃការរៀបចំគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**» ដែលមានទីតាំងនៅផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

នៅក្នុងប្រធានបទមួយនេះ នឹងពន្យល់បង្ហាញអំពីការរៀបចំគោលនយោបាយគណនេយ្យតែប៉ុណ្ណោះទៅលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនៅក្នុងឆ្នាំ២០២៣។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវបានប្រើប្រាស់តាមវិធីសាស្ត្រគុណវិស័យដោយផ្តោតចម្បងទៅលើការវិភាគទិន្នន័យ និងឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទ ដើម្បីយកមកវិភាគ និងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់អំពីដំណើរការសវនកម្មលើអចលកម្មបី និងការរៀបចំផែនការគ្រប់គ្រងលើអចលកម្មបីរបស់ធនាគារ។

សម្រាប់សំណួរស្រាវជ្រាវទី១៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជា ការវិភាគលើរបាយការណ៍ កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័រ បណ្តាញសង្គមរបស់

ក្រុមហ៊ុនផ្ទាល់ ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗ បានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់នូវឯកសារ មេរៀនទាំងឡាយណា ដែលពាក់ព័ន្ធនឹងប្រធានបទ ការអានកម្រងឯកសារផ្សេងៗ របាយការណ៍ចាស់ៗ ដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

សម្រាប់សំណួរស្រាវជ្រាវទី២៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជា៖ ការវិភាគលើរបាយការណ៍ កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័រ បណ្ដាញសង្គមរបស់ក្រុមហ៊ុនផ្ទាល់ ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗ បានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់នូវឯកសារមេរៀនទាំងឡាយណា ដែលពាក់ព័ន្ធនឹងប្រធានបទការអានកម្រងឯកសារផ្សេងៗ របាយការណ៍ចាស់ៗ ដែលសិស្សច្បងជំនាន់មុនបានធ្វើរួចនិងធ្វើការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបានផ្ដល់សារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើនដូចជា៖

### ១.៦.១ ចំពោះក្រុមស្រាវជ្រាវ

.ជួយបង្កើននូវចំណេះដឹងជំនាញសមត្ថភាពផ្សេងៗ ដោយបានផ្សារភ្ជាប់ជាមួយនឹងទ្រឹស្ដី និងការអនុវត្តជាក់ស្ដែងតាមរយៈឯកសារពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា និងតាមរយៈWebsite។

### ១.៦.២ ចំពោះអង្គភាព(PPWSA)

.បង្កើនទំនុកចិត្ត និងភាពជឿជាក់ដល់អតិថិជនមកលើអង្គភាព។

### ១.៦.៣ ចំពោះសង្គម

.ជួយផ្សព្វផ្សាយចំណេះដឹងដល់សិស្សប្អូនជំនាន់ក្រោយបានសិក្សា និងងាយស្រួលក្នុងការស្រាវជ្រាវ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវនេះផងដែរក៏ត្រូវបានបែងចែកជា ៥ ជំពូកដូចជា៖

**ជំពូកទី១ (សេចក្ដីផ្ដើម)** បរិយាយសង្ខេបពីលំនាំបញ្ហា គោលបំណងមូលហេតុនៃការស្រាវជ្រាវចំណោទបញ្ហាដែនកំណត់និងវិសាលភាព ហេតុផលមួយចំនួនដែលបង្កើតឱ្យមានការស្រាវជ្រាវ។

**ជំពូកទី២ (រំលឹកទ្រឹស្ដី)** បង្ហាញពីនិយមន័យ ប្រវត្តិទូទៅដែលពាក់ព័ន្ធ និងទ្រឹស្ដីដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវ។

**ជំពូកទី៣ (លទ្ធផលនៃការស្រាវជ្រាវ)** បង្ហាញអំពីស្ថានភាពទូទៅ គោលដៅ ចក្ខុវិស័យ និងបេសកកម្ម។

**ជំពូលទី៤ (ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ)** បង្ហាញពីការវិភាគ និងការស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រធានបទ។

**ជំពូកទី៥ (សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍)** សន្និដ្ឋានទៅលើចំណុចទាំងអស់ដែលមាននៅក្នុងអត្ថបទ និងផ្ដល់ជាអនុសាសន៍ទៅលើចំណុចដែលមានការខ្វះខាតដើម្បីធ្វើការកែលម្អ។

# ជំពូកទី២
# ផលប្រយោជន៍នៃការរៀបចំគោលនយោបាយគណនេយ្យ

## ២.១ លក្ខណៈទូទៅរបស់គណនេយ្យ

### ២.១.១ និយមន័យរបស់គណនេយ្យ

គណនេយ្យ គឺជាដំណើរការនៃសកម្មភាពអាជីវកម្មសំខាន់ៗ៣រួមមានៈ ការកំណត់អត្តសញ្ញាណកម្មភាពអាជីវកម្មការកត់ត្រាសកម្មភាពអាជីវកម្មនិងការផ្តល់ព័ត៌មានអំពីសកម្មភាពអាជីវកម្ម ដែលទាក់ទងអាចជឿទុកចិត្តបានដើម្បីជាជំនួយដល់អ្នកប្រើប្រាស់ក្នុងការសម្រេចចិត្តការចាត់ចែងអាជីវកម្ម[1]។

គណនេយ្យ គឺជាមុខវិជ្ជាមួយដែលជាប់ទាក់ទងទៅនឹងការកត់ត្រា ការវាស់វែង ការបកស្រាយ ពិពណ៌នានូវសកម្មភាពសេដ្ឋកិច្ច ឬសកម្មភាពហិរញ្ញវត្ថុរបស់អង្គភាពអាជីវកម្មណាមួយ[2]។

គណនេយ្យ គឺជាដំណើរការនៃការកំណត់អត្តសញ្ញាណកម្ម ការវាស់វែង ការកត់ត្រា ការពិពណ៌នា និងការបកស្រាយនូវប្រតិបត្តិការសេដ្ឋកិច្ចរបស់អង្គភាពអាជីវកម្មណាមួយនៅក្នុងកំឡុងពេលវេលាមួយជាក់លាក់[3]។

គណនេយ្យ គឺជាសិល្បៈនៃការកត់ត្រាដំណើរការប្រមូលព័ត៌មានហិរញ្ញវត្ថុ និងទិន្នន័យសេដ្ឋកិច្ចផ្សេងៗទៀតដែលទាក់ទងទៅនឹងអង្គភាពអាជីវកម្ម ដើម្បីកត់ត្រាធ្វើការវាស់វែង និងចាត់ជាចំណាត់ថ្នាក់ក្នុងគោលបំណងធ្វើការបោះផ្សាយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួននៅចុងការិយបរិច្ឆេទនីមួយៗ។

គណនេយ្យ គឺជាមុខវិជ្ជាមួយបែបវិទ្យាសាស្ត្រដែលសិក្សាលម្អិតអំពីរបៀបនៃការកត់ត្រា ការរកស៊ី ឬប្រតិបត្តិការសេដ្ឋកិច្ច ក្នុងគោលបំណងសរុបតួលេខនៃបណ្តាខ្ទង់គណនីទាំងប្រាំក្រុមទៅដំឡើងរបាយការណ៍ហិរញ្ញវត្ថុ (Income Statement និង Balance Sheet)[4]។

### ២.១.២ ប្រវត្តិរបស់គណនេយ្យ

នៅក្នុងឆ្នាំ១០៦៦ ក្នុងជំនាន់ព្រះអង្គម្ចាស់ក្សត្រី Elizabeth មានមេទ័ពមួយឈ្មោះថា William គឺ ជាអ្នកចម្បាំងមួយដ៏ពូកែហើយបានប្រមូលកុលសម្ព័ន្ធពួក Anglo-Saxon បង្កើតជាចក្រភពអង់គ្លេស។ បន្ទាប់ពីវាយឈ្នះលើកុលសម្ព័ន្ធនោះរួចហើយមេទ័ពនោះត្រូវបានព្រះអង្គម្ចាស់ក្សត្រីឱ្យដើរុករានទន្ទ្រាន ដើម្បីរាប់មើល និងវាយតម្លៃទៅលើដូចជា ដី ធនធានធម្មជាតិ មនុស្ស និងសត្វពាហនៈ ទាំងអស់ទោះជារបស់រដ្ឋក្តី ឬជារបស់ប្រជាពលរដ្ឋក្តី។ បន្ទាប់មក William ក៏ចាប់ផ្តើមគណនាពីបំណុល ទាំងបំណុលក្នុងប្រទេស និងបំណុលរបស់បរទេសផងដែរ។ ពេលនោះ William រកឃើញពីភាពខុសគ្នារវាងទ្រព្យសម្បត្តិរបស់ព្រះអង្គម្ចាស់ក្សត្រីរបស់ជនជាតិអង់គ្លេស និងបំណុលរបស់ព្រះអង្គម្ចាស់ដែលជំពាក់គេវិញ។ ភាពខុសគ្នានេះ គេឱ្យឈ្មោះហៅថា ទ្រព្យសម្បត្តិពិតរបស់ព្រះអង្គម្ចាស់ក្សត្រី។ ពេល William ចេញធ្វើប្រតិបត្តិការដើររុករានទន្ទ្រានក្នុងទឹកដី Anglo-

[1] រៀបរៀងដោយនិស្សិត ឈាង ទន្សាយ, ទង គឹមស្រ៊ាន, ពុយ គៀមឡាង, វ៉ាន គា, វុន ដាណេ.(២០២៣). *អត្ថប្រយោជន៍នៃការសិក្សាជំនាញគណនេយ្យ*. សារណាបញ្ចប់ថ្នាក់បរិញ្ញាថ្នាក់បត្រ ជំនាញគណនេយ្យ. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៤. ពេញ។

[2] -ដដែល-

[3] ដដែល-

[4] រៀបរៀងដោយនិស្សិត តេន គឹមដង់, កែវ ម៉េងហេងគីមលាង, ហឿង ម៉ុក. (២០១៩). *ការគ្រប់គ្រងគណនេយ្យអាជីវកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត*. សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៦. ភ្នំពេញ។

Saxon ទាំងមូលធ្វើឱ្យប្រជាពលរដ្ឋមានការភ័យព្រួយយ៉ាងខ្លាំង។ កិច្ចការលើកនេះគឺ William ធ្វើទាល់តែសម្រេចរួចក៏ចងក្រងសៀវភៅមួយនៅក្នុងឆ្នាំ១០៨៦។ សៀវភៅនោះមានឈ្មោះថា "Domes Day Book"។ ជាមួយនឹងការមកដល់នៃយុគសម័យថ្មីនៃឧស្សាហកម្មនៅក្នុងសតវត្សទី១៩ និងបន្ទាប់មកមានការកកើតឡើងរបស់សាជីវកម្មធំ ព្រមទាំងការកកើតឡើង (Industrial Age) នៃការបែងចែកតួនាទីរវាងម្ចាស់ក្រុមហ៊ុន និងអ្នកគ្រប់គ្រងមុខជំនួញដែរ នោះធ្វើឱ្យការគ្រប់គ្រងគណនេយ្យ ក្នុងការធ្វើអាជីវកម្មកាន់តែមានសារៈសំខាន់ថែមទៀត។ លើសពីនេះទៅទៀត ប្រតិបត្តិការនៅក្នុងអាជីវកម្មមានភាពស្មុគស្មាញខ្លាំង ដែលចាំបាច់ត្រូវមានគណនេយ្យដើម្បីមកធ្វើការកែសម្រួល និងតាមដានរាល់ ចំណូល ចំណាយដែលកើតមានឡើងនៅក្នុងអង្គភាព[5]។

### ២.១.៣ ទ្រឹស្តីនៃគណនេយ្យ

ទ្រឹស្តីគណនេយ្យ (Accounting Theory) គឺជាចំណេះដឹង ឬសំណុំគំនិតដែលពន្យល់ និងបកស្រាយអំពីគោលការណ៍ មូលដ្ឋាន និងការអនុវត្តគណនេយ្យ។ សម្រាប់ធ្វើការពន្យល់ ឬទាក់ទាញការសម្រេចចិត្តក្នុងការរៀបចំ និងបកស្រាយព័ត៌មានហិរញ្ញវត្ថុ។ ដែលត្រូវបានប្រើដើម្បីពន្យល់អំពីអ្វីដែលគណនេយ្យគួរធ្វើ និងការបង្កើតស្តង់ដារបង្ហាញព័ត៌មានហិរញ្ញវត្ថុនិងធានាថាព័ត៌មានហិរញ្ញវត្ថុមានភាពច្បាស់លាស់ប្រកបដោយភាពស្របច្បាប់ និងអាចទុកចិត្តបាន។ វាជាមូលដ្ឋានសម្រាប់ការបង្កើតនូវច្បាប់ ក្រមវិធាននានា និងគោលការណ៍គណនេយ្យដែលអនុវត្តនៅក្នុងអង្គភាពសេដ្ឋកិច្ច។

គណនេយ្យ ត្រូវបានគេបែងចែកជា៣ប្រភេទរួមមាន៖ គណនេយ្យហិរញ្ញវត្ថុ គណនេយ្យគ្រប់គ្រង និង គណនេយ្យពន្ធដារ។

#### ១. គណនេយ្យហិរញ្ញវត្ថុ ( Financial Accounting)

គណនេយ្យហិរញ្ញវត្ថុ គឺជាការយកចិត្តទុកដាក់ទៅលើការរាយការណ៍ពីសកម្មភាពអាជីវកម្មទៅកាន់ អ្នកខាងក្រៅ (External User) ឬអ្នកដែលពុំបានចូលរួមដោយផ្ទាល់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់អង្គភាពអាជីវកម្ម។ ជាទូទៅរបាយការណ៍ហិរញ្ញវត្ថុរួមមាន៖ តារាងតុល្យការ (Balance Sheet) របាយការណ៍លទ្ធផល (Income Statement) ជាដើម។ គណនេយ្យហិរញ្ញវត្ថុ គឺជាការកត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុដែលធ្វើឡើងតាមរយៈគណនីប្រាក់បញ្ញើរបស់រដ្ឋបាល ស្រុក ក្រុងដែលនៅរតនាគារ ខេត្ត និងដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ និងទាន់ពេលវេលាសម្រាប់ផ្តល់ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក។

#### ២. គណនេយ្យគ្រប់គ្រង (Management Accounting)

គណនេយ្យគ្រប់គ្រង គឺត្រូវបានផ្តោតសំខាន់ជាមួយនឹងការផ្តល់នូវព័ត៌មានជាសម្ងាត់ សម្រាប់អ្នកប្រើប្រាស់ខាងក្នុងក្រុមហ៊ុនដូចជា អ្នកគ្រប់គ្រងក្រុមហ៊ុននិងនាយកប្រតិបត្តិការរបស់ក្រុមហ៊ុនឬអ្នកគ្រប់គ្រងដទៃទៀត។ គណនេយ្យគ្រប់គ្រង គឺជាសកម្មភាពបង្កើតឯកសារ (ថតប្រតិបត្តិការសេដ្ឋកិច្ច និងព្រឹត្តិការណ៍ប្រមូលផ្តុំនិងថែរក្សាទុក) កត់ត្រា និងធ្វើរបាយការណ៍ស្តីពីសកម្មភាពទាំងនោះដែលកើតក្នុងអង្គភាពទោះជា

[5] រៀបរៀងដោយនិស្សិត តេន គឹមដង់, កែវ ម៉េងហេងគីមលាង, ហឿង ម៉ុក. (២០១៩). *ការគ្រប់គ្រងគណនេយ្យអាជីវកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៧. ភ្នំពេញ។

ហិរញ្ញវត្ថុ និងមិនមែនជាហិរញ្ញវត្ថុជូនអ្នកគ្រប់គ្រងដើម្បីធ្វើផែនការចាត់ចែងដឹកនាំត្រួតពិនិត្យ និងធ្វើការសម្រេចចិត្ត[6]។

ផលប្រយោជន៍នៃគណនេយ្យគ្រប់គ្រង៖

.បង្កើនប្រសិទ្ធភាពដល់ការគ្រប់គ្រងឱ្យកាន់តែប្រសើរឡើង

.ចេះគណនា និងវិភាគរកថ្លៃដើមសរុប និងថ្លៃដើមមួយឯកតា

.ចេះកំណត់តម្លៃលក់

.ចេះធ្វើគម្រោងចំណាយ ចំណូល រួមទាំងចំណុចរួចខ្លួន(Break-Even-Point) ងាយស្រួលធ្វើផែនការការចាត់ចែងធនធាន ការដឹកនាំ ការត្រួតពិនិត្យ និងសម្រេចចិត្ត។

គណនេយ្យគ្រប់គ្រង អាចផ្ទុយពីគណនេយ្យហិរញ្ញវត្ថុពីព្រោះវាបានផ្តល់ព័ត៌មានទៅដល់ម្ចាស់បំណុល និងអ្នកប្រើប្រាស់ខាងក្រៅផ្សេងៗទៀត។ គណនេយ្យគ្រប់គ្រងវាបានផ្តល់នូវព័ត៌មានដល់អ្នកសម្រេចចិត្តខាងក្នុងក្រុមហ៊ុនក្នុងការសម្រេចគោលដៅប្រាក់ចំណេញរបស់អង្គភាព ដូចជាព័ត៌មានអំពីការធ្វើហិរញ្ញប្បទាន វិនិយោគនិងសកម្មភាពប្រតិបត្តិការផ្សេងៗ។

**៣.គណនេយ្យពន្ធដារ (Tax Accounting)**

គណនេយ្យពន្ធដារ គឺជាដំណើរការនៃការរៀបចំនូវចំណូលត្រឡប់ពីការបង់ពន្ធដោយផ្អែក ទៅលើ មូលដ្ឋានព័ត៌មានគណនេយ្យហិរញ្ញវត្ថុ។ ជាទូទៅគណនេយ្យពន្ធដារ គឺផ្តោតសំខាន់លើបញ្ហាបង់ពន្ធរួមទាំង ការដាក់លិខិតប្រកាសពន្ធ និងការធ្វើផែនការសម្រាប់ទទួលខុសត្រូវពន្ធដារនាពេលអនាគត។ បើទោះបីជា យ៉ាងណាក៏ដោយព័ត៌មានគណនេយ្យទាំងនោះគឺត្រូវបានគេធ្វើការកត់ត្រា និងធ្វើជារបាយការណ៍អំពី ចំណូលសម្រាប់បង់ពន្ធ[7]។

## ២.២ ផែនការនៃការរៀបចំគោលនយោបាយគណនេយ្យ

### ២.២.១ និយមន័យនៃផែនការ

ផែនការ គឺជាឯកសារ ឬដំណើរការដែលបង្ហាញពីគោលបំណង របៀបអនុវត្តន៍ កាលវិភាគ ធនធាន និងជំហាននានា ដើម្បីសម្រេចបាននូវគោលដៅ ឬទិសដៅជាក់លាក់ណាមួយ[8]។

ផែនការ គឺជាគ្រោងការណ៍សម្រាប់អនាគត ដែលកំណត់ថាតើត្រូវធ្វើអ្វីដោយរបៀបណា និងពេលណា។

ផែនការ គឺជាសំណុំសកម្មភាព ឬជំហានដែលមានរចនាសម្ព័ន្ធ ដើម្បីសម្រេចបាននូវគោលដៅ ឬលទ្ធផលជាក់លាក់មួយ។ វាអាចមានលក្ខណៈផ្លូវការ ឬមិនផ្លូវការ សាមញ្ញ ឬស្មុគស្មាញ អាស្រ័យលើបរិបទ។

ផែនការ គឺជាគម្រោងការងារណាមួយដែលលើកឡើងប្រកបដោយការត្រិះរិះពិចារណា មានបទដ្ឋានត្រឹមត្រូវ មានលក្ខណៈវិទ្យាសាស្ត្រហើយអាចអនុវត្តន៍បាន។

ផែនការ ជាការរៀបចំការវិភាគ និងកំណត់នូវទិសដៅច្បាស់លាស់។

---

[6] រៀបរៀងដោយនិស្សិត ឈាង ទន្សាយ, ទង គឹមស្រ៊ាន, ពុយ គៀមឡាង, ប៉ាន គា, វុន ដាណេ.(២០២៣). *អត្ថប្រយោជន៍នៃការសិក្សាជំនាញគណនេយ្យ*. សារណាបញ្ចប់ថ្នាក់បរិញ្ញាថ្នាក់បត្រ ជំនាញគណនេយ្យ. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៧. ពេញ។

[7]-ដដែល-

[8] KHsearch. គ្រប់គ្រង. (2029, March 03). *អ្វីទៅជាផែនការ?* Retrieved February, 14 2025 from https://www.khsearch.com/qna/17943

#### ២.២.២ប្រវត្តិនៃផែនការ

ប្រវត្តិផែនការត្រូវបានអភិវឌ្ឍន៍យ៉ាងយូរអង្វែងក្នុងរយៈពេលជាច្រើនពាន់ឆ្នាំដោយផ្អែកលើបំណស្វែងយល់អំពីពិភពលោក និងការបង្ហាញទីតាំងនានា។

សម័យបុរាណ (Ancient Era) ផែនទីដំបូងគេត្រូវបានរកឃើញនៅបាប៊ីឡូន (Babylon) ប្រហែល ២៥០០ ឆ្នាំមុនគ.ស។

សម័យមធ្យម (Medieval Period) ផែនទីត្រូវបានបង្កើតផ្អែកលើសាសនា និងទស្សនៈចំពោះពិភពលោក ផែនទីបង្ហាញពិភពលោកជាមួយទឹកដីទាំងបី(អឺរ៉ុប អាស៊ី អាហ្វ្រិក)។ នៅអ៊ីស្លាម និងចិនក៏មានការរីកចម្រើនផែនទីដ៏ច្រើនផងដែរ (1100–1165): បង្កើតផែនទីផ្អែកលើព័ត៌មានពីអ្នកដំណើរ។ ចំណែកចិនក៏មានផែនទីជាច្រើនពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងការដំណើរផងដែរ។

សម័យស្វែងរកទឹកដីថ្មីសតវត្សទី១៥ដល់១៧អ្នករុករកដូចជា Columbus, Magellan, និង Vasco da Gama បាននាំទិន្នន័យថ្មីៗមកធ្វើផែនទី។ ផែនទីនៅសម័យនេះឆ្ពោះទៅសមុទ្រ និងផ្លូវពាណិជ្ជកម្ម ក្រុមប្រទេសអឺរ៉ុបដូចជា Portugal និង Spain បង្កើតផែនទីសមុទ្រដែលមានតម្លៃយ៉ាងខ្ពស់ក្នុងការរុករក។

សម័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាសតវត្សទី ១៨ដល់១៩: ការវាស់វែងដីនិងការបង្កើតផែនទីស្តង់ដារត្រូវបានអភិវឌ្ឍន៍ការបង្កើតផែនទីអាចប្រើសម្រាប់ទេសចរណ៍ និងអ្នកចម្បាំង។

សម័យទំនើបកំណើតផែនទីឌីជីថលៈ ផែនទីក្លាយជាឧបករណ៍សំខាន់សម្រាប់រដ្ឋាភិបាល អាជីវកម្ម និងប្រជាជនទូទៅ និងការអភិវឌ្ឍក៏អាចចូលដល់ផែនទីបានដោយឥតគិតថ្លៃ។

នាពេលអនាគតនៃផែនទីប្រើប្រាស់បច្ចេកវិទ្យាៈ ក្នុងការវាយតម្លៃលក្ខណៈភូមិសាស្ត្រ ក្នុងការបង្កើតផែនទីនៅតំបន់សម្រាប់ការសិក្សា និងទេសចរណ៍[9]។

#### ២.២.៣ ទ្រឹស្តីនៃផែនការ

ទ្រឹស្តីផែនការ (Plan Theory) គឺជាទ្រឹស្តីមួយសំខាន់នៅក្នុងវិស័យផែនការនគរដ្ឋាន (Urban and Regional Planning) ដែលពន្យល់ពីរបៀបនៃការរៀបចំផែនការ និងអនុវត្តន៍។ ទ្រឹស្តីនេះផ្តោតលើការយល់ដឹងអំពីតួនាទី ការសម្រេចចិត្ត និងវិធីសាស្ត្រសម្រាប់ដោះស្រាយបញ្ហាផែនការមានច្រើនទ្រឹស្តីផែនការដែលត្រូវបានអភិវឌ្ឍន៍តាមបរិបទនយោបាយ សេដ្ឋកិច្ច និងសង្គមនានា[10]។

### ២.៣ ផលប្រយោជន៍នៃការរៀបចំគោលនយោបាយគណនេយ្យ

#### ២.៣.១ និយមន័យគោលនយោបាយ

គោលនយោបាយ គឺជាដំណើរឬគោលការណ៍នៃសកម្មភាពដែលបានអនុម័តឬស្នើរឡើងដោយរដ្ឋាភិបាល អង្គភាព ក្រុមហ៊ុន ឬបុគ្គលិក។

#### ២.៣.២ប្រវត្តិគោលនយោបាយ

[9] Wiktionary. (2015). *ប្រវត្តិនៃផែនការ* . Retrieved February, 15 2025 from https://en.wiktionary.org/wiki/pa%C3%B1%C3%B1%C4%81?utm_source=chatgpt.com

[10] Wiktionary. (2015). *ទ្រឹស្តីផែនការ.* Retrieved February, 15 2025 from https://georgiaplanning.org/presentations/AICP_exam_reviews/2007_AICP%20lecture%20on%20theory%20and%20history.pdf?utm_source=chatgpt.com

ប្រវត្តិគោលនយោបាយ គឺជាការសិក្សាអំពីប្រភពដើម និងការអភិវឌ្ឍនៃគោលនយោបាយសាធារណៈ តាមរយៈការវិភាគប្រវត្តិសាស្ត្រ។ វាពាក់ព័ន្ធនឹងការពិនិត្យមើលពីរបៀបដែលព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមានទម្រង់ជាគោលនយោបាយ និងរបៀបដែលគោលនយោបាយអាចត្រូវបានកែលម្អដោយការយល់ដឹងពីអតីតកាល[11]។

គឺសំដៅទៅលើការអភិវឌ្ឍនៃគំនិតនយោបាយ និងរបបគ្រប់គ្រងតាមកាលបរិច្ឆេទនានា នៅក្នុងសង្គមមនុស្ស។

. គោលនយោបាយសម័យបុរាណមានប្រទេសធំៗ ដូចជា ក្រិក និងរោមបានអភិវឌ្ឍន៍ទ្រឹស្តីនយោបាយដំបូងៗ។ អារីស្តូត (Aristotle) គេចាត់ទុកថាជាពូជកំណើតនៃទ្រឹស្តីនយោបាយគាត់បានសិក្សារបបគ្រប់គ្រងនានា ដូចជាប្រជាធិបតេយ្យ និងអាជ្ញាធរបុរាណ។

នៅក្រិកមានរបបប្រជាធិបតេយ្យដំបូងៗ (Democracy) នៅទីក្រុង Athens ដែលប្រជាជនអាចចូលរួមបោះឆ្នោតបាន។

. សម័យមជ្ឈិម (Middle Ages) ក្នុងសម័យនេះគោលនយោបាយជាចម្បងទាក់ទងនឹងសាសនា និងសេដ្ឋកិច្ចសង្គមប្រពៃណី។

. សម័យអភិវឌ្ឍន៍ (Renaissance Enlightenment)សតវត្សទី១៦-១៨ គឺជារយៈពេលនៃការបង្កើតគំនិតអភិវឌ្ឍន៍នយោបាយថ្មីៗ។

. សម័យទំនើប (Modern Politics)ក្រោយបដិវត្តន៍បារាំង និងបដិវត្តន៍អាមេរិកគំនិតប្រជាធិបតេយ្យកាន់តែរីករាលដាល។ បច្ចុប្បន្ន គោលនយោបាយមានទម្រង់ជាច្រើនដូចជា ប្រជាធិបតេយ្យ សង្គមនិយម ជំនឿបក្សនិយម និងឯកាធិកិបាល(អ្នកដឹកនាំ ឬប្រធាន) ។

ប្រវត្តិនៃគោលនយោបាយជាផ្នែកសំខាន់ក្នុងការយល់ដឹងពីរបៀបដែលសង្គមអភិវឌ្ឍន៍តាមរយៈអំណាច និងការគ្រប់គ្រង។

ប្រវត្តិគោលនយោបាយជួយអ្នកបង្កើតគោលនយោបាយយល់ពីរបៀប និងមូលហេតុដែលការសម្រេចចិត្តពីមុនត្រូវបានធ្វើឡើង។ វាអាចជួយអ្នកបង្កើតគោលនយោបាយជៀសវាងការកើតឡើងម្តងទៀតនូវកំហុសអតីតកាល និងបង្កើតឡើងវិញ។ វាអាចជួយអ្នកបង្កើតគោលនយោបាយធ្វើការសម្រេចចិត្តប្រកបដោយភាពស្ថាបនា និងជាក់ស្តែង[12]។

**២.៣.៣ ទ្រឹស្តីនៃគោលនយោបាយ**

ទ្រឹស្តីគោលនយោបាយត្រូវបានកំណត់ថាជាសរុបនៃបុព្វហេតុ និងការសន្មតផ្សេងទៀត ដែលស្ថិតនៅក្រោមគោលនយោបាយ។ វាអាចត្រូវបានសាងសង់ឡើងវិញ និងតំណាងតាមវិធីជាច្រើន ឧទាហរណ៍ តាមរយៈសម្មតិកម្មបុព្វហេតុ ក្រាហ្វិក មែកធាងគោលដៅ និងមែកធាងការសម្រេចចិត្ត។ ការរួមបញ្ចូលគ្នានៃវិធីផ្សេងគ្នានៃការកសាងឡើងវិញ នេះគឺអាចធ្វើទៅបាន។ គុណភាពនៃទ្រឹស្តីគោលនយោបាយអាចត្រូវបានវាយតម្លៃដោយផ្អែកលើលក្ខណៈវិនិច្ឆ័យជាច្រើន ឧទាហរណ៍ ភាពជាក់លាក់នៃការបង្កើតភាពខុសគ្នា ការរួមបញ្ចូល តម្លៃជាក់ស្តែង និងភាពស្របច្បាប់នៃទ្រឹស្តីគោលនយោបាយ។ ដើម្បីទទួលបានការយល់ដឹងកាន់តែច្បាស់អំពីការ

[11] TheBritishAcademy. (2029). *Policy Histories*. Retrieved February, 15 2025 from https://www.thebritishacademy.ac.uk/projects/policy-histories/

[12] Reconstructing. PolicyTheoryIn. (1990). *Evaluation and Program Planning*. Printed in the USA. All rights reserved. Retrieved February, 15 2025 from https//ris.utwente.nl/ws/files/7051421/Hoogerwerf90reconstructing

កំណត់ នៃទ្រឹស្តីគោលនយោបាយវាចាំបាច់ក្នុងការប្រៀបធៀបវានៅក្នុងការស្រាវជ្រាវ និងផ្នែកឆ្លងកាត់។ រចនាសម្ព័ន្ធ និងគុណភាពនៃទ្រឹស្តីគោលនយោបាយមានឥទ្ធិពលលើខ្លឹមសារ ដំណើរការ និងលទ្ធផលនៃគោលនយោបាយ។ វាគឺជាសម្មតិកម្មដែលអាចជឿជាក់បានដែលថា ការសម្រេចបាននូវគោលដៅនៃគោលនយោបាយនឹងខ្ពស់ជាងនេះ ដោយសារភាព ជាក់លាក់ ភាពខុសគ្នា ការដាក់បញ្ចូលគ្នា តម្លៃជាក់ស្តែង និងភាពស្របច្បាប់នៃទ្រឹស្តីគោលនយោបាយគឺខ្ពស់ជាង។

➢ **ការកំណត់បញ្ហា**

ការសន្មតស្ថិតនៅត្រង់ឫសគល់នៃសកម្មភាពរដ្ឋបាល គោលនយោបាយពឹងផ្អែកលើសំណុំនៃបុព្វហេតុ និងការសន្មតផ្សេងទៀតដែលអាចត្រូវបានគេហៅថាទ្រឹស្តីគោលនយោបាយ។

គំនិតបែបនេះច្រើនតែលេចឡើងក្នុងអក្សរសិល្ប៍អំពីនយោបាយរដ្ឋបាល និងគោលនយោបាយសាធារណៈ។ ជារឿយៗ ពួកគេត្រូវបានអមដោយការយល់ដឹងថា ការសន្មតនូវឫសគល់នៃគោលនយោបាយមិនត្រឹមតែគួរឱ្យចាប់អារម្មណ៍សម្រាប់វិទ្យាសាស្ត្រសង្គមប៉ុណ្ណោះទេ ប៉ុន្តែ វាក៏មានសារៈសំខាន់សម្រាប់ការអនុវត្តគោលនយោបាយផងដែរ។ ជារឿយៗ ភាពបរាជ័យនៃគោលនយោបាយអាចត្រូវបានរាប់បញ្ចូលដោយផ្អែកលើការពិតដែលថាគោលនយោបាយផ្អែកលើការសន្មតមិនត្រឹមត្រូវ។

សារៈសំខាន់នៃការស្រាវជ្រាវលើការសន្មត់ ដែលស្ថិតនៅឫសគល់នៃគោលនយោបាយ ត្រូវបានដាក់បញ្ចូលទៅក្នុងពាក្យដោយលោក Suchman ដូចតទៅ៖ "ដំណើរការនៃការស្វែងរកការយល់ស្របការសន្មតនៃកម្មវត្ថុ គឺស្រដៀងទៅនឹងការចោទសួរអំពីសុពលភាពនៃសម្មតិកម្មរបស់មនុស្ស។ ការជាប់ពាក់ព័ន្ធ គឺជាការព្រួយបារម្ភណ៍ជាមួយនឹងទ្រឹស្តីនៃមូលដ្ឋាននៃជំនឿរបស់មនុស្សម្នាក់ថា សកម្មភាព ការព្រួយបារម្ភនិងបង្កើតផលនៃកំណើន។ ម្យ៉ាងវិញទៀត ការស្រាវជ្រាវគឺជាការសាកល្បងនៃការសន្មតហេតុផល ដែលផ្អែកលើគោលការណ៍។ ដោយមើលឃើញពីចំណុចនេះចាំបាច់ត្រូវបង្កើតឡើងវិញជាប្រព័ន្ធ និងវិភាគការសន្មត់នៃគោលនយោបាយនោះ គឺជាទ្រឹស្តីគោលនយោបាយ។

ការស្រាវជ្រាវលើទ្រឹស្តីគោលនយោបាយមិនត្រឹមតែមានសារៈសំខាន់ ចំពោះការស្រាវជ្រាវប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់ការវាយតម្លៃខ្លឹមសារ គោលនយោបាយដំណើរការគោលនយោបាយ និងទ្រឹស្តីគោលនយោបាយខ្លួនឯងផងដែរ។ នៅពេលណាដែលពាក្យទ្រឹស្តីគោលនយោបាយត្រូវបានប្រើប្រាស់នៅក្នុងអត្ថបទនេះ ទ្រឹស្តីគោលនយោបាយមានន័យនៅទីនេះ៖ សរុបនៃបុព្វហេតុ និងការសន្មតផ្សេងទៀតដែលស្ថិតនៅក្រោមគោលនយោបាយ។

# ជំពូកទី៣
# ផលប្រយោជន៍នៃការរៀបចំគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## ៣.១ ស្ថានភាពទូទៅរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

### ៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តភ្នំពេញបានចាប់បដិសន្ធិឡើងនៅក្នុងឆ្នាំ១៩៥៩ និងមានការតែងតាំងជាផ្លូវការតាម រយៈព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាវីរៈក្សត្រ នៃព្រះរាជាណា ចក្រកម្ពុជា លេខ ១៦៤នស ចុះថ្ងៃទី២៤/ខែមីនា/ឆ្នាំ១៩៦០ ជាអង្គភាពផលិតកម្ម និងអាជីវកម្មរបស់រដ្ឋចំណុះដោយផ្ទាល់នៃសាលាក្រុងភ្នំពេញ ហើយដែលត្រូវបានដាក់ប្រសិទ្ធនាមជាផ្លូវការថា «រដ្ឋាករទឹកភ្នំពេញ» អង្គភាពនេះមានភារកិច្ចក្នុងការផលិតទឹកស្អាតនិងបានផ្គត់ផ្គង់បម្រើរាល់តម្រូវការនៃការប្រើប្រាស់របស់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញព្រមទាំងធានាឱ្យបាននូវតុល្យភាពចំណូល និង ចំណាយលើការងារផលិតកម្ម និងវិនិយោគ។

នៅក្នុងអំឡុងឆ្នាំ ១៨៩៥ ប្រព័ន្ធផ្គត់ផ្គង់ទឹកសម្រាប់ទីក្រុងភ្នំពេញត្រូវបានរៀបចំឡើងជាលើកដំបូងដោយក្រុមហ៊ុនទឹក និងអគ្គីសនីឥណ្ឌូចិនរបស់បារាំងដែលមានឈ្មោះថា (CEEI) ត្រូវបានវិនិយោគទុនសាងសង់រោងចក្រផលិតទឹកស្អាតជ្រោយចង្វារដែលមានសមត្ថភាពផលិតទឹកស្អាតជាមធ្យម១៥,០០០ម/ថ្ងៃហើយព្រមទាំងបណ្តាញចែកចាយប្រវែង៤០គីឡូម៉ែត្រហើយស្ថិតនៅក្នុងខណ្ឌដូនពេញភាគខាងកើតនៃរាជធានីភ្នំពេញនាពេលបច្ចុប្បន្ន។ នៅក្នុងអំឡុងពេលនោះ ដែរការងារផ្គត់ផ្គង់ទឹកស្អាតនៅក្នុងទីក្រុងភ្នំពេញត្រូវបានអនុញ្ញាតិឱ្យធ្វើអាជីវកម្មរកថវិកាចំណូលដើម្បីធានាដំណើរការផលិត និងវិនិយោគដោយខ្លួនឯងក្រោមលក្ខន្តិកៈដោយឡែករបស់ក្រុមហ៊ុន ឥណ្ឌូចិនបារាំង។

ចាប់តាំងពីឆ្នាំ១៩៥៧ រហូតដល់ឆ្នាំ១៩៧០ ការងារផ្គត់ផ្គង់ទឹកស្អាតរួមទាំងការធ្វើដំណើរការនៃអាជីវកម្ម របស់រដ្ឋាករទឹកស្អាតទីក្រុងភ្នំពេញត្រូវបានពង្រឹង និងពង្រីកបន្ថែមទៀតទៅលើការជួសជុលបង្កើតរោងចក្រ ផលិតទឹកស្អាតនិងបណ្តាញចែកចាយថ្មីដូចមានរៀបរាប់ខាងក្រោម៖

១. ក្នុងឆ្នាំ១៩៥៨ រោងចក្រចំការមនដែលមានសមត្ថភាពផលិត១០០០០ម$^3$/ថ្ងៃ ត្រូវបានសាងសង់ឡើងដោយក្រុមហ៊ុនដឺក្រេម៉ុង។

២. ក្នុងឆ្នាំ១៩៥៩រោងចក្រផលិតទឹកស្អាតជ្រោយចង្វារត្រូវបានជួសជុល និងពង្រីកនូវសមត្ថភាពក្នុងការផលិតបន្ថែមរហូតដល់៤៥០០០ម$^3$/ថ្ងៃ។

៣. ក្នុងឆ្នាំ១៩៦៦រោងចក្រផលិតទឹកថ្មីមួយនៅភូមិព្រែកត្រូវបានសាងសង់ឡើងដោយក្រុមហ៊ុនផលិតទឹកស្អាត ពិកចាបាលដែលមានសមត្ថភាពផលិត១០០០០០ម$^3$/ថ្ងៃ។

៤.ប្រព័ន្ធបណ្តាញចែកចាយទឹកត្រូវបានជួសជុល និងពង្រីកបន្ថែម២៤២មនៅតាមបណ្តាឆ្នាំដូចខាងក្រោម៖

ក. ក្នុងឆ្នាំ១៩៥៧បណ្តាញមេ រួមទាំងបណ្តាញចែកចាយទឹកប្រវែង៣៦គីឡូម៉ែត្រត្រូវបានដាក់បន្ថែមដោយក្រុមហ៊ុនដឺក្រេម៉ុង។

ខ.ក្នុងឆ្នាំ១៩៥៩ បណ្តាញមេរួមទាំងបណ្តាញចែកចាយទឹកប្រវែង៣២គីឡូម៉ែត្រត្រូវបានដាក់បន្ថែមដោយក្រុមហ៊ុនគូប៊ូតា។

គ.ក្នុងឆ្នាំ១៩៦០ បណ្តាញមេរួមទាំងបណ្តាញចែកចាយទឹកប្រវែង១៦៥គីឡូម៉ែត្រ ត្រូវបានដាក់បន្ថែម ដោយរដ្ឋាករទឹកភ្នំពេញ។ដោយសារមានសកម្មភាពការងារជួសជុល និងពង្រីកបន្ថែមអំពីប្រព័ន្ធផ្គត់ផ្គង់ខាងលើបានធ្វើឱ្យសមត្ថភាពផលិតទឹកស្អាតសរុបកើនឡើងដល ២៥០០០ម/ថ្ងៃ នៅក្នុងឆ្នាំ១៩៥៩ ដល់ ៥៥០០០ម/ថ្ងៃក្នុងឆ្នាំ១៩៦៣និង១៥៥០០០ម/ថ្ងៃក្នុងឆ្នាំ១៩៦៦។ ការគ្រប់គ្រងរបស់អតិថិជន គឺត្រូវបានពង្រឹង និងបានពង្រីកឱ្យកាន់តែមានភាពប្រសើរឡើងជាលំដាប់ធ្វើឱ្យការងារអាជីវកម្មអាចរកចំណូលបានច្រើន និងធានាបាននូវចំណាយសម្រាប់ដំណើរការផលិតនិងការផ្គត់ផ្គង់ទឹកដោយពុំចាំបាច់មានជំនួយពីខាងក្រៅ។

ដោយឆ្លងកាត់នៃការវិវត្តឥតឈប់ឈរពីសម័យកាលមួយទៅសម័យកាលមួយទើបនៅក្នុងឆ្នាំ ១៩៩៦ អង្គភាពនេះត្រូវបានប្រកាសតែងតាំងនិងបានធ្វើការដាក់ប្រសិទ្ធនាមជាថ្មីម្តងទៀតថា(រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ) គឺជាគ្រឹះស្ថានសាធារណៈដែលល្អប្រសើរមួយប្រកបដោយលក្ខណៈគ្រឹះស្ថានឧស្សាហកម្មតាមអនុក្រឹត្យលេខ០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនាឆ្នាំ១៩៩៦ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ។

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ រ.ទ.ស.ភ សហគ្រាសនីតិបុគ្គលមួយប្រកបដោយ**

អង្គភាពនេះមានភារកិច្ចសំខាន់ដូចខាងក្រោមៈ

១/ផលិត និងផ្គត់ផ្គង់ ទឹកស្អាតសម្រាប់បម្រើរាល់តម្រូវការនៃការប្រើប្រាស់របស់ប្រជាពលរដ្ឋនៅក្នុងទីក្រុងភ្នំពេញទាំងមូល។

២/ការធានាលើតុល្យភាពចំណូលរួមទាំងចំណាយទាំងអស់ ចំពោះដំណើរការនៃការផលិតរួមទាំង និងការវិនិយោគនៅក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួនដោយមានការប្រកាន់ខ្ជាប់ឱ្យបាននូវគោលការណ៍ និងរបៀបប្រកបកិច្ចការដូចគ្នាទៅនឹងពាណិជ្ជកម្មទូទៅ។

ក្នុងន័យនេះ រ.ទ.ស.ភ ក៏ត្រូវទទួលស្វ័យភាពយ៉ាងទូលំទូលាយដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលបំណងបំពេញបេសកកម្មឱ្យមានប្រសិទ្ធភាព និងធ្វើយ៉ាងណារក្សាទ្រព្យសម្បត្តិឱ្យបានគង់វង្ស និងលើកកម្ពស់បញ្ហាអនាម័យសុខភាពរបស់ប្រជាពលរដ្ឋព្រមទាំងមានសោភ័ណ្ឌភាពនៃរាជធានីភ្នំពេញក៏ ដូចជារក្សាឱ្យមានការអភិវឌ្ឍ និងរីកចម្រើនឈានទៀង។



## ១- ដំណាក់កាលពីឆ្នាំ១៩៧០ ដល់ឆ្នាំ ១៩៧៩

### ➢ ឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥

បន្ទាប់ពីសម័យសង្គមរាស្ត្រនិយមបានដួលរលំនៅចុងឆ្នាំ១៩៦៩ ប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងដោយរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់ ស្ថានភាពទូទៅនៅក្នុងស្រុក ព្រមទាំងសង្គមកិច្ច និងសេដ្ឋកិច្ចបាន ធ្លាក់ចុះអន់ថយរើបលែងរួចហើយក្រសួង និងស្ថាប័ននានាពោរពេញដោយភាពចម្រូងចម្រាស់ជាពិសេសសង្គ្រាមបានបន្ទុចបង្អាក់វិស័យនានាស្ទើរតែទាំងស្រុងប្រកបដោយការអស្ថេរភាពគោលនយោបាអសន្តិសុខមន្ត្រីរាជការ-កម្មករបានបោះបង់ការងាររបស់ខ្លួន ឬធ្វើការដោយភាពខ្ជីខ្ជា។ ដំណើរការផលិតកម្ម និងអាជីវកម្មរបស់រដ្ឋាករទឹកក្រុងភ្នំពេញក៏បានថយចុះដោយពុំអាចបន្តសម្រេចនូវផែនការនិងកម្មវិធីនានាដែលបានគ្រោងទុក។

ម្យ៉ាងវិញទៀតក្នុងគម្រោងដែលមានការរៀបចំបានប្រែក្លាយរដ្ឋាករទឹកភ្នំពេញឱ្យទៅជាសហគ្រាសជាតិមានស្វ័យភាពពេញលេញក៏ត្រូវផ្អាកផងដែរ។ ការអាក់ខានទាំងអស់នេះហើយ គឺបណ្តាលមកពីឥទ្ធិពលដ៏អាក្រក់នៃការ កើតឡើងនៅសង្គ្រាមស៊ីវិលដណ្តើមអំណាចគ្នា ដែលធ្វើឱ្យប្រទេសជាតិទាំងមូលត្រូវបានធ្លាក់ចុះទៅក្នុងវិបត្តិផ្សេងយ៉ាងធ្ងន់ធ្ងរពិបាកនឹងធ្វើការស្រោចស្រង់វិញបាន។

### ➢ ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩

ដោយសោកនាដកម្មឥតឈប់ឈរនៅមុនពេល និងក្រោយពីការដួលរលំរបបលោក លន់នល់ រួចមកសភាពការនៅក្នុងប្រទេសកម្ពុជា ក៏រឹតតែបន្ថែមទម្ងន់យ៉ាងខ្លាំងក្លាឡើងថែមទៀត ជាពិសេសក្នុងការបោសសម្អាតទីក្រុងភ្នំពេញដោយពួកខ្មែរកុំម្មុយនីស្ត។ ពួកខ្មែរក្រហម ក៏បានកាន់កាប់ទាំងស្រុងទៅលើទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដោយមានការកាប់សម្លាប់យ៉ាងរង្គាលមិនថាចាស់ ក្មេង ព្រះសង្ឃ

ព្រមទាំងមន្ត្រីរាជការ រួមទាំងប្រជាពលរដ្ឋដែលស្លូតត្រង់ក្នុងរាជរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ មិនតែប៉ុណ្ណោះ ពួកគេបានបង្ខំជម្លៀសប្រជាជនទាំងអស់ឱ្យចាកចេញពីទីក្រុងភ្នំពេញដោយគ្មានគោលដៅ។

ហេតុផលទាំងនេះហើយ ទើបធ្វើឱ្យទីក្រុងទាំងមូលត្រូវបានប្រែក្លាយទៅជាការគ្របដណ្ដប់ ដោយមានសភាពស្ងាត់ជ្រងំ និងសោកនាដកម្មគ្មានទីបញ្ចប់។ អ្វីៗគ្រប់យ៉ាង ក៏ត្រូវបានបិទទ្វារចោលមិនថាតែក្រសួង ឬស្ថាប័ននានា សាលារៀន មន្ទីរពេទ្យ វត្តអារាម ជាពិសេសរដ្ឋាករទឹកភ្នំពេញ ក៏ត្រូវរងនូវការខូចខាតដោយការបាញ់ និងការដុតបំផ្លាញយ៉ាងដំណំពីសំណាក់ពួកខ្មែរក្រហម ។

នៅក្នុងការអនុវត្តការងារចែកចាយទឹកស្អាតនៅតែបន្តិចបន្តួចប៉ុណ្ណោះ គឺត្រូវបានបង្រួបបង្រួមមកត្រឹមតែសម្រាប់ការប្រើប្រាស់នៃកងទាហាន និងគណៈកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានចំនួនតិចតួចក្នុងទីក្រុងខ្មោចនេះ។ សកម្មភាពអាជីវកម្ម ត្រូវបានឱ្យប្រានចោលទាំងស្រុង ហើយប្រការដែលគួរឱ្យចាប់អារម្មណ៍ គឺក្នុងចន្លោះជិត៤ឆ្នាំនៃរបបខ្មែរក្រហមនេះ រោងចក្រផលិតទឹកស្អាតទាំងបីទាំងប្រព័ន្ធផលិតកម្ម និងប្រព័ន្ធចែកចាយ ការថែទាំត្រូវបានគេបំភ្លេចចោលទាំងស្រុង ហើយផលវិបាកបានធ្វើឱ្យមានភាពស្មុគស្មាញរហូតដល់ឆ្នាំ១៩៧៩។

## ២. ដំណាក់កាលពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣

ក្រោយពីពន្លឺសន្តិភាពបានកើតមានឡើង ដោយសារកិច្ចចរចារនៅទីក្រុងប៉ារីសប្រទេសបារាំង ភាគីជម្លោះទាំងកុំម្មុយនីស្ត និងមិនមែនកុំម្មុយនីស្ត បានធ្វើការគាំទ្រដល់ផែនការស្វែងរកសន្តិភាពរបស់អង្គការសហប្រជាជាតិ ។

ឧត្តមក្រុមប្រឹក្សាជាតិក្រោមព្រះរាជកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់នៃសម្ដេចព្រះនរោត្តមសីហនុ ដែលជាប្រធាន បានរៀបចំឱ្យមានការបោះឆ្នោតជាសកលមួយនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៣ ដែលឈានទៅរកការបញ្ចប់នូវភ្លើងសង្គ្រាមមួយដ៏រ៉ាំរ៉ៃដើម្បីឱ្យកម្ពុជាអាចស្តារ និងមានការអភិវឌ្ឍប្រទេសជាតិ ទៅតាមមាគ៌ាលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងទទួលបានការគាំទ្រពីអន្តរជាតិ។ ដូច្នេះហើយ គ្រប់រចនាសម្ព័ន្ធរបស់សង្គមរដ្ឋាភិបាល និងហេដ្ឋារចនាសម្ព័ន្ធត្រូវបានធ្វើការកែទម្រង់ពេលនោះដែរ។ នៅក្នុងពេលនោះដែរ រដ្ឋាករទឹកភ្នំពេញក៏ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ផ្ដោតទៅលើការយកចិត្តទុកដាក់ជាចម្បង ដោយមានការគិតគូឱ្យចូលរួមទាំងវិស័យបច្ចេកទេស និងមូលធនពីរាជរដ្ឋាភិបាលនិងទទួលបានជំនួយពីបណ្តាប្រទេសជាមិត្តជាច្រើន ដូចជាព្រះរាជាណាចក្រជប៉ុន ប្រទេសបារាំង សហភាពសូវៀត។ ឥណទានពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីបុព្វហេតុក្នុងការជួយទ្រទ្រង់នូវវិស័យសុខាភិបាលអនាម័យ ក៏ដូចជាវិស័យទឹកស្អាតនៅកម្ពុជាផងដែរ។

ទោះបីជាក្នុងរយៈពេលនោះទ្រព្យសម្ភារៈ និងឯកសារបច្ចេកទេសទាំងអស់ត្រូវបានខូចខាត និងកម្ទេចបំផ្លាញ ក៏ដោយក៏រដ្ឋាករទឹកភ្នំពេញបានរៀបចំឱ្យមានដំណើរការឡើងវិញ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៩ ក្នុងស្ថានភាពដ៏លំបាកក្រៃលែង ពីព្រោះថាមន្ត្រីរាជការ អ្នកបច្ចេកទេសមួយចំនួនធំបានបាត់បង់ជីវិតក្នុងរបបប៉ុលពត ហើយដែលនៅមាននិយោជិតមួយចំនួនតូចប៉ុណ្ណោះ ដែលក្នុងនោះភាគច្រើនគ្រាន់តែជាអ្នកដែលធ្លាប់ធ្វើការតែមិនមែនជាអ្នកជំនាញការផងនោះត្រូវបានប្រមូលគៀងគរឱ្យមកបម្រើកិច្ចការឡើងវិញ ។

➢ គោលនយោបាយ

ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ(រ.ទ.ស.ភ) បានបង្ហាញរបាយការណ៍ហិរញ្ញវត្ថុសវនកម្មរបស់ខ្លួនរៀងរាល់ប្រចាំឆ្នាំសេវាសវនកម្ម ដើម្បីឆ្លើយតបទៅ និងតម្រូវការជាច្រើនរបស់អតិថិជន ដើម្បីធានានៅភាពរឹងមាំផ្នែកហិរញ្ញវត្ថុ។ សេវាកម្មនេះគឺធានាគុណភាពខ្ពស់បំផុតរបស់ CPA ដែលសវនកម្មត្រូវបានអនុវត្តន៍ស្របតាមស្តង់ដាសវនកម្មដែលគេទទួលយក។

ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)ក៏បានផ្តល់ជូនសេចក្តីថ្លែងការណ៍ ដែលបានពិនិត្យមើលថាការពិនិត្យមើលឡើងវិញ ត្រូវបានអនុវត្តន៍ស្របតាមបទដ្ឋានវិជ្ជាជីវៈសម្រាប់ការខ្ចីលុយពីធានាគារការវិនិយោគខាងក្រៅ និងម្ចាស់បំណុលពាណិជ្ជកម្មដែលមិនត្រូវការរបាយការណ៍ហិរញ្ញវត្ថុ។ ការស៊ើបអង្កេតភាគច្រើនត្រូវបានធ្វើឡើងក្រៅពីការចងក្រងខាងលើ។ ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ(រ.ទ.ស.ភ)បានរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាមួយ និងការប្រើប្រាស់បុគ្គលិក និងអ្នកគ្រប់គ្រងទៅតាមតួនាទីជំនាញរៀងៗខ្លួន និងប្រព័ន្ធគណនេយ្យរួមបញ្ចូលគ្នាតាមកុំព្យូទ័រ។ លើសពីនេះទៅទៀត អាចដំណើរការបញ្ជីប្រាក់បៀវត្សការគណនាទៅលើការកាត់ពន្ធប្រាក់ខែរបស់បុគ្គលិក និងកំណត់ត្រាពន្ធ។ អាចកំណត់ត្រា និងចំនួននៃសារពើពន្ធទាំងអស់ ដើម្បីរៀបចំការតភ្ជាប់គណនីផ្សេងៗ ឱ្យដូចទៅនិងប្រព័ន្ធនៃការតភ្ជាប់របស់ធនាគារនិងសេវាកម្មគណនេយ្យផ្សេងទៀត ដែលចាត់ទុកជាការចាំបាច់សម្រាប់អតិថិជន។ ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) ត្រូវស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្ម វិស័យពន្ធដារនិងអាករ ដូចនេះរ.ទ.ស.ភមានកាតព្វកិច្ចត្រូវបង់ពន្ធលើប្រាក់ចំណេញ២០%។

### ៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

#### ក. ចក្ខុវិស័យ

រ.ទ.ស.ភ បានប្តេជ្ញាចិត្តបន្តធ្វើឱ្យសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនមានការរីកចម្រើនប្រកប ដោយចីរភាពព្រមទាំងធ្វើជាអ្នកផ្តល់ប្រឹក្សា ជាអ្នកសម្របសម្រួលដើម្បីឱ្យប្រជាពលរដ្ឋរស់នៅក្នុងទីប្រជុំជនខេត្ត-ក្រុងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងពិភពលោកមានទឹកស្អាតប្រើប្រាស់ទាំងអស់គ្នា។

#### ខ. បេសកកម្ម

បេសកកម្មរបស់ រ.ទ.ស.ភ គឺធានាផ្គត់ផ្គង់ទឹកស្អាតគ្មានមេរោគ២៤ម៉ោង លើ២៤ម៉ោង ក្នុងមួយសប្តាហ៍មានសម្ពាធគ្រប់គ្រាន់ និងក្នុងតម្លៃមួយសមស្របជូនប្រជាពលរដ្ឋទូទាំងរាជធានីភ្នំពេញ និងទីប្រជុំជនរបស់ខេត្តកណ្តាលដែលជាប់នឹងរាជធានីភ្នំពេញ ដោយមិនមើលរំលងប្រជាពលរដ្ឋក្រីក្រ។ ក្រៅពីនេះ រ.ទ.ស.ភ បាននឹងកំពុងចែករំលែកបទពិសោធន៍ការងាររបស់ខ្លួនដល់បណ្តារដ្ឋាករទឹកខេត្ត-ក្រុងមួយចំនួន នៅក្នុងព្រះរាជាណាចក្រកម្ពុជាព្រមទាំងបណ្តាអង្គភាពទឹកស្អាតក្នុងតំបន់ និងក្នុងពិភពលោកតាមសំណូមពរសំដៅដល់ការសម្រេចចិត្តឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។

#### គ. គោលដៅ

ពង្រីកការផ្គត់ផ្គង់ទឹកទៅតំបន់ជុំវិញរាជធានីភ្នំពេញដោយរក្សាអត្រា និងស្តង់ដាដូចគ្នានៅក្នុងរាជធានីភ្នំពេញ។ វិភាគថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទដើម្បីកាត់បន្ថយថ្លៃដើមទឹកបង្កើនប្រសិទ្ធភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស។ តាំងចិត្តខ្ពស់ ចំពោះការទទួលខុសត្រូវដល់សង្គម និង

បរិស្ថាន។ ប្រៀបធៀបបែបយុទ្ធសាស្ត្រជាមួយបណ្តាអង្គភាពទឹកស្អាតនានា ដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក ។

### ៣.១.៣រចនាសម្ព័ន្ធគ្រប់គ្រងតួនាទីនិងភារកិច្ចរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ




## ៣.២ ផែនការនៃការរៀបចំគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ការរៀបចំផែនការគោលនយោបាយគណនេយ្យ សម្រាប់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គឺជាការដាក់ស្ថាបនាប្រព័ន្ធគណនេយ្យដែលមានតុល្យភាពស្របតាមស្តង់ដារដ្ឋ និងអាជីវកម្ម។ ការរៀបចំនេះត្រូវធ្វើតាមផែនការ និងនីតិវិធីដូចខាងក្រោម៖

- ផែនការនៃការរៀបចំគោលនយោបាយគណនេយ្យ ការកំណត់គោលបំណង និងវឌ្ឍនភាពបង្កើតគោលនយោបាយគណនេយ្យដើម្បីធានាបាននូវភាពច្បាស់លាស់ក្នុងការកត់ត្រា ការរាយការណ៍ និងការវិភាគហិរញ្ញវត្ថុ។ តម្រូវឱ្យមានភាពស្របតាម IPSAS (International Public Sector Accounting Standards) ឬស្តង់ដារដ្ឋកំណត់។
- ការវិភាគបរិបទ និងសកម្មភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន វិភាគប្រភពចំណូលចម្បង (លក់ទឹក សេវាទឹកស្អាត) ចំណាយប្រតិបត្តិការ និងបំណុលប្រាក់បញ្ញើ និងទ្រព្យសកម្មជាសាធារណៈ។
- ការជ្រើសរើសគោលនយោបាយគណនេយ្យមានភាពសមស្រប ការជ្រើសរើសមធ្យោបាយសមស្របដើម្បីគ្រប់គ្រងឯកសារហិរញ្ញវត្ថុកំណត់វិធីវាយតម្លៃសារពើភណ្ឌ (FIFO, Weighted Average) ការកំណត់ វិធីកំណត់ថ្លៃចំណាយ និងដំណើរការចំណាយពាក់ព័ន្ធ។

- នីតិវិធីនៃការរៀបចំគោលនយោបាយគណនេយ្យ បង្កើតគណៈកម្មការផ្នែកហិរញ្ញវត្ថុមមានអ្នកជំនាញផ្នែកគណនេយ្យនិងអគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុធ្វើការវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ។
- សម្របសម្រួលគណនេយ្យជាតិ និងច្បាប់ពាក់ព័ន្ធ ប្រែប្រួលឯកសារឱ្យស្របតាមច្បាប់គណនេយ្យ និងសវនកម្មជាតិស្របតាមអនុក្រឹត្យរដ្ឋាភិបាលពាក់ព័ន្ធនិងអង្គភាពសាធារណៈ។
- ការរៀបចំឯកសារបញ្ជាក់គោលនយោបាយគណនេយ្យ កំណត់បែបបទ និងឯកសារដែលត្រូវមាន (accounting manual)កំណត់ប្រភេទចំណូល ចំណាយ និងវិធីកត់ត្រា។
- ការចេញផ្សាយនិងអនុវត្តន៍ ការអនុវត្តន៍ជាផ្លូវការជាមួយបុគ្គលិកបណ្តុះបណ្តាលដល់អ្នកធ្វើគណនេយ្យ ការត្រួតពិនិត្យ និងកែប្រែប្រព័ន្ធត្រួតពិនិត្យខាងក្នុងដោយធ្វើការពិនិត្យឡើងវិញជាប្រចាំឆ្នាំ។

**៣.២.១ តួនាទីនៃការរៀបចំគោលនយោបាយរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

នៅក្នុងការបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវធ្វើឱ្យមានភាពស្មើគ្នា ក្នុងទំនាក់ទំនងរវាងគ្នា និងជាមួយអតិថិជន អ្នកផ្គត់ផ្គង់ គូប្រជែង អ្នកម៉ៅការ និងនិយោជិត រ.ទ.ស.ភ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់មិនត្រូវទាញយកប្រយោជន៍ពីបុគ្គលណាម្នាក់ដោយមិនស្មោះត្រង់ ដោយប្រើប្រាស់ឧបាយកល ការលាក់បាំង ការបំភ័ន្តព័ត៌មានសំខាន់ការបង្ហាញហេតុការណ៍ដែលខុសពីការពិត ឬដោយអំពើមិនស្មោះត្រង់ផ្សេងទៀតក្នុងអាជីវកម្ម។

ការប្រើប្រាស់ព័ត៌មានអំពីសិទ្ធិព័ត៌មានសម្ងាត់នៃអាជីវកម្មរបស់ រ.ទ.ស.ភ ឬការបញ្ចុះបញ្ចូលអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់ រ.ទ.ស.ភ ទាំងអតីត និងបច្ចុប្បន្នឱ្យទម្លាយនូវព័ត៌មានទាំងនោះត្រូវបានហាមឃាត់ដាច់ខាត។

អភិបាលអ្នកគ្រប់គ្រង និងបុគ្គលិកមានការទទួលខុសត្រូវរបស់ខ្លួនដោយសុចរិតព្រមទាំងធ្វើសកម្មភាពតាមគោលនយោបាយ និងនីតិវិធីគណនេយ្យក្នុងគោលបំណងមួយសម្រេចឱ្យបាននូវរបាយការណ៍ហិរញ្ញវត្ថុដែលបន្ថែមនូវការទុកចិត្តជូនសាធារណជន ដោយក្នុងមួយឆ្នាំក្រុមព្រឹក្សានេះត្រូវប្រជុំយ៉ាងហោចណាស់ ក៏មួយដងដែរដើម្បីផលប្រយោជន៍របស់ រ.ទ.ស.ភ និងភាគហ៊ុនិកទាំងអស់របស់ រ.ទ.ស.ភ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវទាញយកផលប្រយោជន៍ពីមុខតំណែងរបស់ខ្លួនជាអភិបាល ឬជាបុគ្គលិកជាន់ខ្ពស់ និងមិនត្រូវទទួលអំណោយណាមួយពីតតិយជនដោយសារមុខតំណែងជាអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

ការការពារ និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ រ.ទ.ស.ភ នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនអភិបាលនិងបុគ្គលិកជាន់ខ្ពស់ត្រូវជំរុញឱ្យមានការត្រួតពិនិត្យ និងការប្រើប្រាស់ឱ្យបានត្រឹមត្រូវដោយមានការទទួលខុសត្រូវនូវទ្រព្យសម្បត្តិរបស់ រ.ទ.ស.ភ រួមទាំង ទ្រព្យរូបី និងទ្រព្យអរូបី។

ទ្រព្យសម្បត្តិរបស់ រ.ទ.ស.ភ មានដូចជា ព័ត៌មាន សម្ភារៈ គ្រឿងបរិក្ខារ កម្មសិទ្ធិបញ្ញា ឧបករណ៍ ប្រភពធនធាន ប្រព័ន្ធព័ត៌មានវិទ្យា និងទ្រព្យដទៃទៀត ដែលជាកម្មសិទ្ធិរបស់ រ.ទ.ស.ភ ឬ ទ្រព្យដែល រ.ទ.ស.ភ ជួលពីគេ ឬ ទ្រព្យដែលស្ថិតក្រោមការកាន់កាប់របស់ រ.ទ.ស.ភ ត្រូវបានប្រើប្រាស់សម្រាប់តែគោលដៅអាជីវកម្មស្របច្បាប់របស់ រ.ទ.ស.ភ តែប៉ុណ្ណោះ។

## បណ្តឹងពាក់ព័ន្ធនឹងគណនេយ្យ

គណៈកម្មាធិការសវនកម្ម ឬសវនករផ្ទៃក្នុងរបស់ រ.ទ.ស.ភ ត្រូវទទួលខុសត្រូវក្នុងការរៀបចំនីតិវិធីសមស្របមួយ សម្រាប់ទទួលពាក្យបណ្តឹង រក្សាទុកនូវពាក្យបណ្តឹង និងពិនិត្យលើពាក្យបណ្តឹងទាក់ទងនឹងគណនេយ្យ ការត្រួតពិនិត្យគណនេយ្យផ្ទៃក្នុង ឬបញ្ហាផ្សេងទៀតដែលទាក់ទងទៅនឹងសវនកម្ម។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ អាចដាក់ពាក្យបណ្តឹងពីបញ្ហាខាងលើទៅគណៈកម្មាធិការសវនកម្ម ឬសវនករផ្ទៃក្នុងរបស់ រ.ទ.ស.ភ។ ការស្នើសុំឱ្យពិនិត្យបណ្តឹងជាសម្ងាត់អាចធ្វើឡើងបានតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ការលើកទឹកចិត្តឱ្យរាយការណ៍ពីទង្វើខុសច្បាប់ ឬអសីលធម៌របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវខិតខំជម្រុញឱ្យ រ.ទ.ស.ភ ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងលើកទឹកចិត្តនិយោជិតឱ្យរាយការណ៍ពីភស្តុតាងនៃទង្វើខុសច្បាប់ ឬអសីលធម៌ទៅនាយកដ្ឋាន ឬបុគ្គលដែលមានសមត្ថកិច្ចនៅក្នុង រ.ទ.ស.ភ ។

## ការជួញដូរផ្ទៃក្នុង

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តន៍ និងប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវច្បាប់និងបទប្បញ្ញត្តិជាធរមានបទបញ្ជាផ្ទៃក្នុង និងគោលនយោបាយរបស់ រ.ទ.ស.ភ ពាក់ព័ន្ធនឹងការលក់ ទិញភាគហ៊ុន របស់ រ.ទ.ស.ភ ។

អភិបាលនិងបុគ្គលិកជាន់ខ្ពស់ ត្រូវរក្សាការសម្ងាត់នៃព័ត៌មានសម្ងាត់របស់ រ.ទ.ស.ភ ដែលខ្លួនបានដឹងលើកលែងតែក្នុងករណីដែល រ.ទ.ស.ភ អនុញ្ញាតឱ្យផ្តល់ព័ត៌មាន ឬការផ្តល់ព័ត៌មាននេះត្រូវបានតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន ឬមានការតម្រូវពីអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

ពាក្យថា "ព័ត៌មានសម្ងាត់" រួមមានជាអាទិ៍ ព័ត៌មានមិនមែនសាធារណៈដែលអាចត្រូវបានប្រើដោយគូប្រកួតប្រជែងរបស់ រ.ទ.ស.ភ ឬព័ត៌មានមិនមែនសាធារណៈដែលធ្វើឱ្យប៉ះពាល់ដល់ រ.ទ.ស.ភ ឬអតិថិជនរបស់ រ.ទ.ស.ភ ប្រសិនបើព័ត៌មាននោះត្រូវបានបង្ហាញ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ត្រូវពិភាក្សាជាមុនជាមួយអគ្គនាយក ឬប្រធានក្រុមប្រឹក្សាភិបាលប្រសិនបើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះគិតថាខ្លួនមានកាតព្វកិច្ចតាមច្បាប់ក្នុងការបង្ហាញព័ត៌មានសម្ងាត់នោះ។

## ការផ្តល់ព័ត៌មាន

អភិបាល និងបុគ្គលិកជាន់ខ្ពស់តម្រូវឱ្យយល់ច្បាស់ពីនីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ ដើម្បីឱ្យសេចក្តីប្រកាសជាសាធារណៈ របាយការណ៍ និងឯកសារផ្តល់ព័ត៌មាន ដែលត្រូវចុះបញ្ជីជាមួយអាជ្ញាធររដ្ឋ រួមបញ្ចូលទាំងនិយ័តករមូលបត្រកម្ពុជាអាចរៀបចំធ្វើឡើង ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន រួមទាំងគោលការណ៍ណែនាំរបស់និយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា។

ម្យ៉ាងវិញទៀត ក្នុងទំហំនៃតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ដែលមានអំណាចដឹកនាំ ឬគ្រប់គ្រងការចុះបញ្ជីឯកសារជាមួយនិយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា ឬការជូនដំណឹងជាសាធារណៈផ្សេងទៀតរបស់ រ.ទ.ស.ភ ពាក់ព័ន្ធអាជីវកម្មទូទៅលទ្ធផលលក្ខខណ្ឌ និងលទ្ធភាពហិរញ្ញវត្ថុត្រូវពិភាក្សាជាមួយនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ផ្សេងទៀត និងជាមួយនិយោជិតពាក់ព័ន្ធ ហើយចាត់វិធានការសមស្របសម្រាប់នីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មាន ដើម្បីឱ្យការផ្តល់ព័ត៌មានធ្វើបានពេញលេញ ច្បាស់លាស់ ត្រឹមត្រូវទាន់ពេល និងអាចយល់បាន។

ក្នុងទំហំដែលពាក់ព័ន្ធនឹងនីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ អភិបាល និងបុគ្គលិកជាន់ខ្ពស់ម្នាក់ៗ៖

- ត្រូវយល់ច្បាស់អំពីលក្ខខណ្ឌតម្រូវនៃការផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ ក៏ដូចជាប្រតិបត្តិការអាជីវកម្ម និងហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ។
- មិនត្រូវធ្វើសេចក្តីថ្លែងខុសពីការពិត ឬធ្វើឱ្យអ្នកដទៃថ្លែងខុសពីការពិតទាក់ទងអំពីព័ត៌មានរបស់ រ.ទ.ស.ភ ប្រាប់អ្នកដទៃទោះបីជាអ្នកនោះនៅក្នុង ឬនៅក្រៅ រ.ទ.ស.ភ រួមទាំងសវនករឯករាជ្យ និយ័តកររបស់រាជរដ្ឋាភិបាល និងស្ថាប័នផ្សេងទៀត។

**វិសោធនកម្ម និងការលើកលែង**

ក្រុមសីលធម៌នេះ អាចត្រូវបានធ្វើវិសោធនកម្ម ឬលើកលែងមិនអនុវត្តន៍ ដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ដោយគោរពតាមលក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាន ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ជាវិធានទូទៅក្រុមប្រឹក្សាភិបាល និងមិនផ្តល់ការលើកលែងមិនអនុវត្តន៍ប្រការណាមួយនៃក្រមសីលធម៌នេះឡើយ ប្រសិនបើគ្មានមូលហេតុសមស្រប និងចាំបាច់ទេនោះ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តន៍ឱ្យបានខ្ជាប់ខ្ជួនតាមស្មារតី និងខ្លឹមសារនៃក្រមសីលធម៌នេះ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់មានកាតព្វកិច្ចយល់ដឹងពីក្រមសីលធម៌នេះ និងស្វែងរកការពន្យល់ និងការផ្តល់ប្រឹក្សាបន្ថែមទាក់ទងនឹងការបកស្រាយខ្លឹមសារ និងលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌នេះ ជាពិសេសនៅពេលមានហេតុការណ៍ណាមួយដែលអាចមានទំនាស់ជាមួយនឹងក្រមសីលធម៌នេះ។

ក្រុមប្រឹក្សាភិបាល ត្រូវបានចាត់វិធានការសមស្របក្នុងករណីដែលមានការបំពានក្រមសីលធម៌នេះ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់អាចសាកសួរដោយផ្ទាល់ទៅអគ្គនាយកទាក់ទងនឹងការអនុវត្ត ឬ ការបកស្រាយក្រមសីលធម៌នេះ។ ក្រមសីលធម៌នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ និងមានអានុភាពអនុវត្តន៍ចាប់ពី រ.ទ.ស.ភ ទទួលបានការយល់ព្រមឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយនិយ័តករមូលបត្រកម្ពុជា និងត្រូវបានចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា។ ក្រមសីលធម៌ នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ និងមានអានុភាពអនុវត្តន៍ចាប់ពី រ.ទ.ស.ភ ទទួលបានការយល់ព្រមឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដោយនិយ័តករមូលបត្រកម្ពុជា និងត្រូវបានចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា។

**ក.** ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តន៍ធុរកិច្ចដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និង និយោជិតក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ បានអនុម័តក្រមសីលធម៌សម្រាប់អនុវត្តន៍ធុរកិច្ច ដោយត្រូវបានផ្សព្វផ្សាយ និងមានបង្ហាញក្នុងរបាយការណ៍ប្រចាំឆ្នាំជូនដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និយោជិត ភាគហ៊ុនិករបស់ រ.ទ.ស.ភ និងសាធារណជន។

**ខ.** យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តន៍ធុរកិច្ចពុំមាន

**គ.** ប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

១. គោលនយោបាយរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ សម្រាប់គ្រប់គ្រងលើប្រតិបត្តិការ ជាមួយភាគីជាប់ពាក់ព័ន្ធ

| ល.រ | ភាគីជាប់ពាក់ព័ន្ធ | គោលនយោបាយ |
|---|---|---|
| ១ | ក្រុមហ៊ុនហូលឌីង | គ្មាន |
| ២ | កិច្ចព្រមព្រៀងវិយោគចម្រុះ | គ្មាន |
| ៣ | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | គ្មាន |
| ៤ | ភាគហ៊ុននិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតមានចំនួនច្រើននិងច្រើនលើសលប់ | គ្មាន |
| ៥ | អភិបាល និងសមាជិកគ្រួសារផ្ទាល់របស់អភិបាល | គ្មាន |
| ៦ | បុគ្គលិកនិងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលិក | គ្មាន |
| ៧ | ផ្សេងៗ | គ្មាន |

**១.១ ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធ**

ក្នុងពេលបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ ត្រូវតែអនុវត្តន៍ និងព្យាយាមធ្វើឱ្យ រ.ទ.ស.ភ អនុវត្តន៍តាមច្បាប់ និងបទបញ្ញត្តិជាធរមាន។ ប្រសិនបើអភិបាល ឬ បុគ្គលិកជាន់ខ្ពស់ណាមួយបានដឹងពីព័ត៌មានដែលខ្លួនជឿជាក់ថា រ.ទ.ស.ភ អភិបាល ឬ បុគ្គលិកជាន់ខ្ពស់ ឬ និយោជិតណាមួយបានបំពានច្បាប់ និងបទបញ្ញត្តិជាធរមាន អភិបាល ឬបុគ្គលិកជាន់ខ្ពស់ដែលបានដឹងត្រូវផ្តល់ព័ត៌មាននេះជូនអគ្គនាយក ប្រធានក្រុមប្រឹក្សាភិបាល ប្រធានគណកម្មាធិការសវនកម្ម ឬសវនករផ្ទៃក្នុង។

**អំពើទំនាស់ផលប្រយោជន៍**

បន្ថែមលើបទបញ្ញត្តិទាំងឡាយនៃមាត្រា១៣៤ ១៣៥ ១៣៦ និងមាត្រា១៣៨ នៃច្បាប់ស្តីពីសហគ្រាស ពាណិជ្ជកម្ម អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាងនូវរាល់អំពើទំនាស់ផលប្រយោជន៍ដែលអាចកើតមាន ជាមួយ រ.ទ.ស.ភ។

ជាទូទៅទំនាស់ផលប្រយោជន៍កើតឡើងនៅពេលដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់អភិបាលឬ បុគ្គលិកជាន់ខ្ពស់ ឬ ផលប្រយោជន៍របស់សមាជិកគ្រួសារផ្ទាល់របស់អភិបាល ឬ បុគ្គលិកជាន់ខ្ពស់នោះ បានជ្រៀតចូលក្នុង ឬ អាចនឹងជះឥទ្ធិពលធ្ងន់ធ្ងរដល់៖

(ក) ផលប្រយោជន៍ទូទៅ ឬអាជីវកម្មរបស់ រ.ទ.ស.ភ

(ខ) លទ្ធភាពរបស់អភិបាល ឬ បុគ្គលិកជាន់ខ្ពស់ផ្សេងទៀតក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវផ្តល់ព័ត៌មានទៅក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ហើយត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈនូវប្រតិបត្តិការ ឬទំនាក់ទំនងណាមួយ ដែលខ្លួនគិតថានឹងនាំឱ្យកើតមានទំនាស់ផលប្រយោជន៍ជាមួយ រ.ទ.ស.ភ តាមការកំណត់របស់និយ័តករមូលបត្រកម្ពុជា ឬក៏ជាផ្សារមូល

បត្រកម្ពុជា។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ រ.ទ.ស.ភ ត្រូវបង្ហាញនូវផលប្រយោជន៍របស់ខ្លួនជាលាយលក្ខណ៍អក្សរទៅ រ.ទ.ស.ភ ឬ ស្នើឱ្យមានសេចក្តីប្រកាសដែលបានដាក់ចូលទៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលក្នុងករណីដែល៖

(ក) អភិបាល ឬ បុគ្គលិកជាន់ខ្ពស់នោះ ជាភាគីនៃកិច្ចសន្យា ឬ ជាអ្នកស្នើធ្វើកិច្ចសន្យាជាមួយនឹង រ.ទ.ស.ភ

(ខ) អភិបាល ឬ បុគ្គលិកជាន់ខ្ពស់នោះមានផលប្រយោជន៍សំខាន់ជាមួយនឹងបុគ្គល ឬ នីតិបុគ្គលដែលជាភាគីក្នុងកិច្ចសន្យា ឬ ភាគីដែលស្នើធ្វើកិច្ចសន្យាជាមួយ រ.ទ.ស.ភ ។

ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន អភិបាលឯករាជ្យមិនត្រូវមានផលប្រយោជន៍ណាមួយនៅក្នុង រ.ទ.ស.ភ ដែលធ្វើឱ្យប៉ះពាល់ឯករាជ្យភាពរបស់ខ្លួន និងមិនត្រូវកាន់កាប់ភាគហ៊ុនលើសពីមួយ (១) ភាគរយនៃភាគហ៊ុនសរុបរបស់ រ.ទ.ស.ភឡើយ។

**កាលានុវត្តភាពអាជីវកម្ម**

នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវយកចិត្តទុកដាក់ជាអាទិភាពដល់ផលប្រយោជន៍ស្របច្បាប់របស់ រ.ទ.ស.ភ នៅពេលសមស្រប។

**អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាង៖**

(ក) ឆ្លៀតឱកាសធ្វើកិច្ចការដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនដែលខ្លួនបានដឹងក្នុងពេលអនុវត្តន៍តួនាទី និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុង រ.ទ.ស.ភ ។

(ខ) ប្រើប្រាស់ទ្រព្យសម្បត្តិ ឬព័ត៌មានរបស់ រ.ទ.ស.ភ ឬឋានៈ និងមុខតំណែងរបស់ខ្លួនដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។

(គ) ប្រកួតប្រជែងជាមួយ រ.ទ.ស.ភ ។

- **ផែនការនៃក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

នៅពេលក្រុមហ៊ុន រ.ទ.ស.ភ មានផែនការយុត្តិសាស្រ្តត្រូវបានបង្កើតឡើងសម្រាប់ផ្តល់ឱកាសល្អ ដើម្បីប្រើប្រាស់ការអភិវឌ្ឍប្រកបដោយចីរភាពទី៦ ដែលមានសារៈសំខាន់ធ្វើឱ្យកាន់តែងាយស្រួល ក្នុងការសម្រេចបាននូវចំណុចអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្សេងទៀត។ នេះរួមបញ្ចូលដោយចីរភាពនានា រួមមាន កាត់បន្ថយភាពក្រីក្រ យេនឌ័រនិងក្រុមងាយរងគ្រោះ។ សម្រាប់ការធ្វើផែនការយុត្តិសាស្រ្តអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៦ មាន២ចំណុចរួមមាន៖

កម្រិតដែលរដ្ឋាភិបាលអាចទទួលបានការគាំទ្រពីសហគមន៍អន្តរជាតិ ដើម្បីជួយដោះស្រាយបញ្ហាកង្វះខាតនៃហិរញ្ញវត្ថុ និងបច្ចេកទេសដែលបញ្ឈប់ប្រទេសកម្ពុជាពីការលម្អប្រព័ន្ធទឹកស្អាត និងអនាម័យ ប្រសិទ្ធភាពទឹកស្អាត ប្រតិកម្មទឹកកខ្វក់ និងវិធីសាស្រ្តផ្សេងៗទៀត ដើម្បីកាត់បន្ថយការខ្វះខាតទឹក។

កម្រិតដែលរដ្ឋាភិបាល មានភាពងាយស្រួលសម្រាប់ប្រជាជន និងអាជ្ញាធរមូលដ្ឋានក្នុងការចូលរួមគ្រប់គ្រង រួមទាំងការថែទាំទឹក និងអនាម័យ។

- **ផែនការសកម្មភាពនៃក្រុមហ៊ុនរដ្ឋាទឹកស្វយ័តក្រុងភ្នំពេញ**

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គឺជាសហគ្រាសសាធារណៈមួយរបស់ប្រទេសកម្ពុជា ដែលផ្តល់សេវាកម្មទឹកស្អាត ការផ្គត់ផ្គង់ទឹកស្អាត និងចែកចាយទឹកស្អាត។ សកម្មភាពចម្បង គឺជាការកែច្នៃ នឹងផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានីភ្នំពេញ និងតំបន់នានាជុំវិញរាជធានី រួមមានអ្នករស់នៅតំបន់តាខ្មៅជាដើម និងការធ្វើសកម្មភាពការងារផ្សេងៗទៀតទាក់ទងទៅនឹងការផ្គត់ផ្គង់ប្រព័ន្ធទឹកស្អាត។

**ផែនការនិងសកម្មភាពនាពេលអនាគតរបស់ក្រុមហ៊ុន រ.ទ.ស.ភ រួមមាន៖**

- ប្តេជ្ញាចិត្តចំពោះការអភិវឌ្ឍនៃសេវាកម្មផ្គត់ផ្គង់ទឹកស្អាតប្រកបដោយនិរន្តភាព
- ការផ្តល់សេវាកម្មជាអ្នកពិគ្រោះយោបល់ និងសម្របសម្រួលដើម្បីធានាថា ប្រជាជននៅតាមបណ្តាទីក្រុង និងខេត្តនានានៃប្រទេសកម្ពុជាមានលទ្ធភាពប្រើប្រាស់ទឹកស្អាត។
- ប្តេជ្ញាចិត្តជួយប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតដើម្បីផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជនរបស់ខ្លួនក្នុងការប្រតិបត្តិការអាជីវកម្ម។

**៣.២.២ មុខងារនៃការរៀបចំគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

៣. ប្រព័ន្ធគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ

**នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ**

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុបានអនុវត្តន៍ការងារលើការគ្រប់គ្រងបញ្ជីការគណនេយ្យ គ្រប់គ្រងហិរញ្ញវត្ថុ និងគ្រប់គ្រងសន្និធិស្តុកបានល្អប្រសើរ និងមានការសហការគ្នាល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយដែលត្រូវធ្វើការ៖

**តាមដាន និងកែលម្អ៖**

ការងារទូទាត់ចំណាយលើការងារដាក់បំពង់ចែកចាយទឹកថ្មីក្នុងកំណត់ហេតុរបស់គណកម្មការស្តីពីការចុះពិនិត្យលើការងារជីកដាក់បំពង់ពុំបានបញ្ជាក់ពីគម្រោងបានអនុវត្តន៍រួច និងគម្រោងកំពុងអនុវត្តន៍បន្ត ។

**ការងារទូទាត់ចំណាយ៖**

- ឆ្នាំ២០២២ ចំនួន ៣៨៧ សំណើ (ខែកុម្ភៈ, ខែវិច្ឆិកា និងខែធ្នូ)
- ឆ្នាំ២០២៣ ចំនួន ៣២៧ សំណើ (ខែឧសភា និងខែមិថុនា)

សវនកម្មផ្ទៃក្នុងពិនិត្យឃើញថា ក្នុងឆ្នាំ ២០២២ ការងារទូទាត់ចំណាយលើការងារដាក់បំពង់ចែកចាយទឹកថ្មី និងការងារដាក់បំពង់មេនាំទឹកក្នុងកំណត់ហេតុរបស់គណៈកម្មការស្តីពីការចុះពិនិត្យការងារជីកដាក់បំពង់ពុំមានភ្ជាប់គម្រោងបានអនុវត្តន៍រួច មានចំនួន ១៩ គម្រោង ស្មើនឹង ១០០% ដោយមានភ្ជាប់តែតារាងដាក់បំពង់ ទឹកប្រចាំសប្តាហ៍របស់សាខាសេវាកម្មទឹកស្អាត និងអនាម័យ។ មន្ត្រីទទួលបន្ទុក រៀបចំពុំទាន់សមស្របតាម បែបបទរដ្ឋបាល។ ករណីនេះ ការកត់ត្រាគម្រោងដែលបានអនុវត្តន៍ ពុំមានភាពច្បាស់លាស់ឬអាចមានស្ទួនគ្នា។ មន្ត្រីទទួលបន្ទុកការងារខាងលើត្រូវធ្វើការសហការជាមួយនាយកដ្ឋានពាក់ព័ន្ធក្នុងការកត់ត្រាលើគម្រោងបានអនុវត្តន៍បញ្ចប់ និងគម្រោងកំពុងអនុវត្តន៍បន្តដោយធ្វើជាតារាងរួមភ្ជាប់ជាឧបសម្ព័ន្ធកម្រិតហានិភ័យទាប។

ជាការឆ្លើយតប ដោយមន្ត្រីទទួលបន្ទុកបានតាមដានតារាងការអនុវត្តគម្រោងរួមទើបមិនញែកឱ្យតាមផ្នែកនូវការអនុវត្តរួចនិងកំពុងអនុវត្តន៍ដោយគ្រាន់តែដាក់កំណត់សម្គាល់ប៉ុណ្ណោះ ដូច្នេះនាយកដ្ឋានគណនេយ្យ និង

ហិរញ្ញវត្ថុនឹងណែនាំមន្ត្រីទទួលបន្ទុកការងារខាងលើត្រូវធ្វើការសហការជាមួយនាយកដ្ឋានពាក់ព័ន្ធក្នុងការកត់ត្រាលើគម្រោងដែលបានអនុវត្តន៍បញ្ចប់ និងគម្រោងដែលកំពុងបន្តអនុវត្តន៍ដោយធ្វើជាតារាងរួមភ្ជាប់ដើម្បីជាឧបសម្ព័ន្ធកំណត់ហេតុនៅដើមឆ្នាំ២០២៤។

- **សន្និដ្ឋាន**

ការធ្វើសវនកម្មដែលបានធ្វើឡើងខាងលើនេះបង្ហាញថាដំណើរការនៃប្រតិបត្តិការខាងលើអនុវត្តន៍បានល្អអនុលោមតាមសេចក្តីកំណត់ស្តង់ដាការងារ ព្រមទាំងបទដ្ឋានគតិយុត្តិនានា។ មន្ត្រីនិយោជិតនៅតាមបណ្តានាយកដ្ឋាន/អង្គភាព បានខិតខំប្រឹងប្រែងសហការអនុវត្តការងារតាមតួនាទីភារកិច្ច និងសម្រេចបានលទ្ធផលល្អ។ សវនដ្ឋានមានការឯកភាព និងកែលម្អតាមអនុសាសន៍ណែនាំនូវរាល់ចំណុចខ្វះចន្លោះខាងលើព្រមទាំងធ្វើរបាយការណ៍បំភ្លឺតបចំណុចដែលបានកែលម្អ និងពុំទាន់បានធ្វើការកែលម្អក្នុងរយៈពេល ០៣ខែបន្ទាប់ពីចេញរបាយការណ៍។

សវនកម្មផ្ទៃក្នុងនឹងធ្វើការតាមដានរាល់អនុសាសន៍ដែលបានពិនិត្យឃើញនូវបណ្តាចំណុចខ្វះចន្លោះរបស់សវនករក្នុងកំឡុងពេលចុះត្រួតពិនិត្យតាមការកំណត់ក្នុងផែនការប្រចាំឆ្នាំ។

**៤. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ**

**ក របាយការណ៍តុល្យការ**

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | **កំណត់សម្គាល់** | **២០២៣ គិតជាពាន់រៀល** | **២០២២ គិតជាពាន់រៀល** |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យសកម្ម រោងចក្រ និងបរិក្ខា | ៥ | ២.៤៩៤.៩៧៩.២៩០ | ២.២០៣.០៤១.៩១៤ |
| ទ្រព្យសកម្មអរូបី | | ១០.៤៦៣.០៧៤ | ១២.០៨៩.៥៨៧ |
| ទ្រព្យសកម្មរយៈពេលវែងសរុប | | ២.៥០៥.៤៤២.៣៦៤ | ២.២១៥.១៣១.៥០២ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | ៦ | ៣១៨.៧៤៦.៥៩២ | ១៥២.៧៣៧.០៨៧ |
| គណនីអតិថិជនពាណិជ្ជកម្មនិងគណនីត្រូវទទួល | ៧ | ២៧.៩៨០.២៦៣ | ៣២.៧០៧.៤១៦ |
| ទ្រព្យសកម្មកិច្ចសន្យា | ៨ | ១៥៥.៥០១.២៥៥ | ៩២.៧៦៨.៣៧៤ |
| ឥណទានផ្តល់ឱ្យនិយោជិត | ៩ | ៧.៩៥៦.៦៥១ | ៧.៩៥៦.៦៥១ |
| ការវិនិយោគរយៈពេលខ្លី | ១០ | ១២៧.៣១៦.០០៣ | ១២៦.១១៨.៤១៦ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១១ | ១៦.១១៧.២២២ | ៥៦.៧១៦.៤៣៩ |
| ទ្រព្យសកម្មរយៈពេលខ្លីសរុប | | ៦៥៣.៦១៧.៩៥៩ | ៤៦៩.០០៤.៧៣៤ |
| ទ្រព្យសកម្មសរុប | | **៣.១៥៩.០៦០.៣២៣** | **២.៦៨៤.១៣៥.៨៧៥** |

| | | | |
|---|---|---|---|
| **មូលធន និងបំណុល** | | | |
| **មូលធនរបស់ភាគហ៊ុននិករបស់ រ.ទ.ស.ភ** | | | |
| ដើមទុន និងបុព្វលាភភាគហ៊ុន | ១២ | ៦២០.៧៥៩.១០៧ | ៦២០.៧៥៩.១០៧ |
| ទុនបម្រុង | ១៣ | ៦៤៧.១៤៨.៧៨២ | ៥៤៣.២៦៨.០៧៥ |
| ចំណេញរក្សាទុក | | ១២៦.៦០៩.៥៨២ | ១០៨.១៨៥.៨៦៥ |
| មូលធនសរុប | | **១.៣៩៤.៥១៧.៤៧** | **១.២៧២.២១៣.០៤** |
| **បំណុលរយៈពេលវែង** | | | |
| ប្រាក់កម្ចី | ១៤ | ២.២៩៦.៩២៤.៦៨ | ៩៨៦.៤៩៥.៧១៧ |
| ជំនួយពន្យាពីរដ្ឋាភិបាលនិងជំនួយផ្សេង | ១៥ | ៧៤.១៦២.៧៤៦ | ៩៨៦.២៣៨.៤៧៧ |
| បំណុលពន្ធពន្យារ | ២០ | ៨១.៩៤៦.៨៥៨ | ៧៧.០១៦.៧១៦ |
| គណនីត្រូវទទួលផ្សេងៗ | ១៦ | ៨២.៩០៣.៧៣២ | ៧៦.៨០១.៧០៥ |
| បំណុលរយៈពេលវែងសរុប | | **១.៥ ៣៥.៩៣៨.០២០** | **២.២០៩.៥៥២.៦១៥** |
| **បំណុលរយៈពេលខ្លី** | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនី | | | |
| ត្រូវទូទាត់ផ្សេងៗ | ១៦ | ១៧៩.៩៤៤.៦២១ | ១៥៤.៦៦១.១៥២ |
| ប្រាក់កម្ចី | ១៤ | ២៣.៦៧៧.៤០១ | ២៣.៤៩៩.១៥៨ |
| កិច្ចសន្យាបំណុល | ៨ | ៤.២៥៤.១៣៨ | ៤.៤៥៦.៧៥៦ |
| បំណុលពន្ធលើប្រាក់ចំណូល | | ២០.៧២៨.៦៧២ | ១៩.៧៥៣.១៤៧ |
| **បំណុលរយៈពេលខ្លីសរុប** | | ២២៨.៦០៤.៨២៣ | ២០២.៣៧០.២១៣ |
| **បំណុលសរុប** | | **១.៧៦៤.៥៤២.៨៥២** | **១.៤១១.៩២២.៨២៨** |
| **មូលធន និងបំណុលសរុប** | | **៣.១៥៩.០៦០.៣២៣** | **២.៦៨៤.១៣៥.៨៧៥** |

**ខ របាយការណ៍លទ្ធផល**

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | ២០២៣ គិតជាពាន់ពាន់រៀល | ២០២២ គិតជាពាន់ពាន់រៀល |
|---|---|---|---|
| **ចំណូល៖** | | | |
| ចំណូលពីការផ្គត់ផ្គង់ទឹក | ១៧ | ៣៤៩.៦៤០.០៧៣ | ២៩៩.៧២៣.៥០៧ |
| កម្រៃពីការសាងសង់ | | ១៦.៦៦៥.៦១៧ | ២៤.៩៧៦.៣១៦ |
| ចំណេញពីការប្តូររូបិយបណ្ណ-សុទ្ធ | | ៤.១១១.០៣៩ | ១.១០៥.៧០០ |
| ចំណូលផ្សេងៗ | | ២១.៦៣៧.៦៣៦ | ២១.៤៧៨.៣៣៣ |
| | | ៣៩២.០៥៤.៣៦៥ | ៣៤៧.៣៨៣.៨៥៦ |
| **ចំណាយ៖** | | | |
| ចំណាយអត្ថប្រយោជន៍និយោជិត | ១៨ | (៨០.២៩២.៤៣៨) | (៧០.១៧៥.៤២២) |
| ចំណាយរំលស់ទ្រព្យរូបី-អរូបី | | (៦១.៩៧៨.១៣៥) | (៥៩.៤៥៥.០៧៤) |
| ចំណាយថ្លៃភ្លើង | | (៤២.២៩១.៤៤៦) | (៣៥.២១៨.៧៤៣) |
| ចំណាយវត្ថុធាតុដើមផលិតទឹកស្អាត | | (១៥.៨៧៥.៣១៣) | (១២.១៤០.៧៤០) |
| ចំណាយជួសជុលនិងថែទាំ | | (១១.៦៥១.០៥៨) | (៨.០០៩.៣៥៨) |
| ចំណាយសេវាសាងសង់ | | (៩.៧៣១.៥១៨) | (១៦.៦១៨.០២៤) |
| ចំណាយវត្ថុធាតុដើមសម្រាប់តភ្ជាប់បណ្តាញទឹកតាមគេហដ្ឋាន | | (៤.៨១៦.៥១៤) | (៤.៩៥៣.៣៧១) |
| ចំណាយប្រតិបត្តិការ | | (១៥.១៥៥.៤៣៦) | (១១.២៤៣.៤១៦) |
| | | (២៤១.៧៩១.៨៥៨) | (២១៧.៨១៤.១៤៨) |
| | | **១៥០.២៦២.៥០៧** | **១២៩.៤៦៩.៧០៨** |
| **ចំណាយប្រតិបត្តិការ** | | | |
| **ចំណាយប្រតិបត្តិការ** | | | |
| ចំណូលហិរញ្ញប្បទាន | | ៦.៧៣៧.៧៦៦ | ៤.៦៥៦.៦១៨ |
| ចំណាយហិរញ្ញប្បទាន | ១៩ | (៣.៥២៧.៧៣០) | (៣.៦១០.៤៣៤) |
| **ចំណេញមុនបង់ពន្ធ** | | **១៥៧.៤៧២.៥៤៣** | **១៥៧.៤៧២.៥៤៣** |
| ពន្ធលើប្រាក់ចំណូល | ២០ | (២៦.៨៦២.៩៦១) | (២២.៣៣០.០២៧) |
| **ចំណេញក្នុងឆ្នាំ តំណាងឱ្យលទ្ធផលលម្អិតក្នុងឆ្នាំ** | | | |
| ចំណេញក្នុងមួយភាគហ៊ុនរបស់ភាគហ៊ុនិក | | ១២៦.៦០៩.៥៨២ | ១០៨.១៨៥.៨៦៥ |
| ចំណេញគោលក្នុងមួយភាគហ៊ុន | ២២ | ១.៤៥៥.៧៣ | ១.២៤៣.៩០ |
| ចំណេញថយចុះក្នុងមួយភាគហ៊ុន | ២២ | ១.៤៥៥.៧៣ | ១.២៤៣.៩០ |

គ. របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | ២០២៣ គិតជាពាន់រៀល | ២០២២ គិតជាពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| **ចំណេញមុនបង់ពន្ធ** | | **១៥៣.៤៧២.៥៤៣** | **១៣០.៥១៥.៨៩២** |
| និយ័តកម្មលើ៖ | | | |
| រំលស់ទ្រព្យសម្បត្តិ រោងចក្រ បរិក្ខារ | ៥ | ៦០.១១៥.៣៩៦ | ៥៧.៤៦០.៩២៧ |
| ចំណាយហិរញ្ញប្បទាន | ១៩ | ៣.៥២៧.៧៣០ | ៣.៦១០.៤៣៤ |
| ចំណេញសុទ្ធពីការប្តូររូបិយប័ណ្ណមិនមែនជាសាច់ប្រាក់លើគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម | | ២.១៤២.៩៤៤ | ៦.១៤០.៦០៦ |
| រំលស់ទ្រព្យសកម្មអរូបី | | ១.៨៥៦.៤៥០ | ១.៩៩៤.១៤៧ |
| ការជម្រះបញ្ជីទ្រព្យសម្បត្តិ រោងចក្រ បរិក្ខារ | ៥ | ១.៦២៨.៤៥៥ | ១៣៦.៨៣៩ |
| ការជម្រះបញ្ជីទ្រព្យសកម្មអរូបី | | ៦.៣១៥ | - |
| ចំណេញពីការប្តូររូបិយប័ណ្ណមិនមែនជាសាច់ប្រាក់លើប្រាក់កម្ចី | | (៩.៩៦៧.៩៥៨) | (៤.៥៨៦.៨៦៦) |
| ចំណូលហិរញ្ញប្បទាន | | (៦.៧៣៧.៧៦៦) | (៤.៦៥៦.៦១៨) |
| រំលស់ជំនួយពន្យាពីរដ្ឋាភិបាល ជំនួយផ្សេងៗ | ១៥ | (២.០០៩.៩០៨) | (២.០០៩.៩០៨) |
| **ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | **២០៤.០៣៤.១៧៤** | **១៨៨.៦០៥.៤៥៣** |
| **បម្រែបម្រួលទុនបង្វិល៖** | | | |
| សន្និធិ | | (២៣៨.១៥២.៩៣៨) | (៨៩.៨១៩.២០១) |
| គណនីអតិថិជនពាណិជ្ជកម្ម គណនីត្រូវទទួលផ្សេងៗ | | ៦.១១២.៧០៣ | (៦.១១០.៥២៥) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្មនិងគណនីត្រូវទូទាត់ផ្សេងៗ | | ២៣.១៤០.៥២៥ | ៨.៥០៩.៦៩៤ |
| កិច្ចសន្យាទ្រព្យសកម្ម | | (៦២.៧៣២.៩៨១) | (២៦.៧៤៣.៧៩៤) |
| កិច្ចសន្យាបំណុល | | (២០២.៦១៨) | ២.៦៦៧.៨៦២ |
| ប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ | | ៦.១០២.០២៧ | ៧.៣៥៥.៦៣២ |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/បានពីប្រតិបត្តិការ** | | **(៦១.៦៩៩.០០៨)** | **៨៤.៤៦៥.១២១** |
| ពន្ធលើប្រាក់ចំណូលបានបង់ | | (២០.៩៥៧.២៩៤) | (២២.២៣៣.១៥៧) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង/បានពីសកម្មភាពប្រតិបត្តិកា** | | **(៨២.៦៥៦.៣០២)** | **៦២.២៣១.៩៦៤** |

| | | | |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | |
| ការប្រាក់ទទួលបាន | | ៥.៣៥២.២៤៣ | ២.៩៣៤.៨៩៤ |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ បរិក្ខារ | ៥ | (២៦៩.៨៨៦.៩៤៦) | (២៨១.៦១៩.៧១៦) |
| កំណើននៃការវិនិយោគរយៈពេលខ្លី | | (១.១៩៧.៥៨៧) | (៥៧.៩៥៤.៥៨៣) |
| ការទិញទ្រព្យសកម្មអរូបី | | (២៣៦.២៥២) | (៣៩០.០៧៥) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(២៦៥.៩៦៨.៥៤២)** | **(៣៣៧.០២៩.៤៨០)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | | ៣៤១.៩៨៧.៥៣៧ | ២១៨.២៨០.៤៣៩ |
| ជំនួយទទួលបានពីរដ្ឋាភិបាល ជំនួយផ្សេងៗ | ១៥ | ៦.៩៣៤.១៧៧ | ៥៤.៤៣៦.១៩៩ |
| ការបន្ថែមដើមទុនពីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ | | ១.៤៤៣.២២១ | |
| ការទូទាត់សងប្រាក់កម្ចី | | (២១.៤៧៩.៤៥៤) | (២០.៧៦៩.៣៨៦) |
| ការប្រាក់បានទូទាត់ | | (១៥.១១១.៤៧៥) | (៧.៤៩១.៨០៤) |
| ភាគលាភបានទូទាត់ | ២៣ | (៤.៣០៥.១៥៨) | (៤.០៤៤.២៥២) |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន** | | **៣០៨.០២៥.៦២៧** | **២៤១.៨៥៤.៤១៧** |
| **តំហយចុះនៃសាច់ប្រាក់ សាច់ប្រាក់សមមូលសុទ្ធ** | | **(៤០.៥៩៩.២១៧)** | **(៣២.៩៤៣.០៩៩)** |
| | | | |
| **សាច់ប្រាក់និងសាច់ប្រាក់សមមូលនៅដើមឆ្នាំ** | | **៥៦.៧១៦.៤៣៩** | **៨៩.៦៥៩.៥៣៨** |
| **សាច់ប្រាក់និងសាច់ប្រាក់សមមូលនៅចុងឆ្នាំបញ្ចប់** | **១១** | **១៦.១១៧.២២២** | **៥៦.៧១៦.៤៣៩** |

ឃ របាយការណ៍បម្រែបម្រួលមូលធន

| | កំណត់ សម្គាល់ | បុព្វលាភភាគហ៊ុន គិតជាពាន់រៀល | ទុនបម្រុងទុក គិតជាពាន់រៀល | មូលធនបម្រុងទុក គិតជាពាន់រៀល | មូលធនសរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | | **៦១៩,៣១៥,៨៨៦** | **៤១៨,០៣៨,៤១០** | **១២៩,២៧៣,៩១៧** | **១,១៦៦,៦២៨,២១៣** |
| ចំណេញក្នុងឆ្នាំ តំណាងឱ្យ លទ្ធផលលម្អិតសរុបក្នុងឆ្នាំ | | | | ១០៨,១៨៥,៨៦៥ | ១០៨,១៨៥,៨៦៥ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | |
| ការបន្ថែមដើមទុន | ១២ | | | ១,៤៤៣,២២១ | ១,៤៤៣,២២១ |
| ការផ្ទេរទៅគណនីទុនបម្រុង | ១៣ | | | ១២៥,២២៩,៦៦៥ | (១២៥,២២៩,៦៦៥) |
| ភាគលាភ | ២៣ | | | (៤.០០.៤២៥២) | (៤.០៤៤.២៥២) |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក សរុប** | | ១,៤៤៣,២២១ | ១២៥,២២៩,៦៦៥ | (១២៩,២៧៣,៩១៧) | (២,៦០១,០៣១) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២/ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | | **៦០២,៧៥៩,១០៧** | **៥៤៣,២៦៨.០៧៥** | **១០៨,១៨៥,៨៦៥** | **១,២៧២,២១៣,០៤៧** |
| ចំណេញក្នុងឆ្នាំ តំណាងឱ្យ លទ្ធផលលម្អិតសរុបក្នុងឆ្នាំ | | | | ១២៦,៦០៩,៥៨២ | ១,២៧២,២១៣,០៤៧ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | |
| ការផ្ទេរទៅគណនីទុនបម្រុង | ១៣ | | | ១០៣,៨៨០,៧០៧ | (១០៣,៨៨០,៧០៧) |
| ភាគលាភ | ២៣ | | | (៤,៣០៥,១៥៥) | (៤,៣០៥,១៥៥) |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក សរុប** | | | ១០៣,៨៨០,៧០៧ | (១០៨,១៨៥,៨៦៥) | (៤,៣០៥,១៥) |
| **នាថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០២៣** | | **៦២០,៧៥៩,១០៧** | **៦៤៧,១៤៨,៧៨២** | **១២៦,៦០៩,៥៨២** | **១,៣៩៤,៥១៧,៤៧១** |

ង កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុមាន ៤ដូចខាងក្រោមៈ

១. របាយការណ៍លទ្ធផល(Income Statement) ជារបាយការណ៍ដែលបានផ្តល់ឱ្យអ្នកវិនិយោគ និងម្ចាស់បំណុលនូវព័ត៌មានដែលជួយឱ្យពួកគេធ្វើការព្យាករណ៍ស្ថានភាពទឹកប្រាក់ពេលវេលា និងភាពប្រាកដនៃលំហូរសាច់ប្រាក់ក្នុងអង្គភាពនាពេលអនាគត។

២. របាយការណ៍តុល្យការ(Balance Sheet) ជារបាយការណ៍ដែលរាយការណ៍ពីទ្រព្យសកម្ម បំណុល និងមូលធនម្ចាស់ទ្រព្យនៃអង្គភាពអាជីវកម្ម មិនត្រឹមតែប៉ុណ្ណោះវាគឺជារបាយការណ៍ហិរញ្ញវត្ថុ ដែលផ្តល់នូវអ្វីដែលក្រុមហ៊ុនកាន់កាប់ និងជំពាក់ក៏ដូចជាចំនួនទឹកប្រាក់ដែលវិនិយោគដោយម្ចាស់ភាគហ៊ុន។

៣. របាយការណ៍លំហូរសាច់ប្រាក់(Cash Flow Statement) ជារបាយការណ៍សំខាន់មួយដែលផ្តល់ព័ត៌មានដែលពាក់ព័ន្ធអំពីសាច់ប្រាក់ដែលបានទទួល និងសាច់ប្រាក់ដែលចំណាយរបស់សហគ្រាសក្នុងមួយកំឡុងកាលបរិច្ឆេទមួយ។

៤ . របាយការណ៍ប្រាក់ចំណេញរក្សាទុក(Statement of Retain Earning) ជារបាយការណ៍ដែលបង្ហាញពីម្ចាស់ទ្រព្យដែលបានមកពីប្រាក់ចំណេញនៃប្រតិបត្តិការក្រុមហ៊ុនក្នុងពេលជាក់លាក់។ របាយការណ៍នេះត្រូវបានគណនាដោយរបាយការណ៍ប្រាក់ចំណេញរក្សាទុបូកបន្ថែមជាមួយនឹងប្រាក់ចំណេញសុទ្ធ (Net Income) កើនឡើង គឺធ្វើឱ្យប្រាក់ចំណេញរក្សាទុកមានការកើនឡើងដែរ។

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ហៅកាត់ថា រ.ទ.ស.ភ ស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងអនុវត្តន៍ និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ហៅកាត់ថា "ក.ស.ហ.វ) ហើយមានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ។ រ.ទ.ស.ភត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្មថាជាសហគ្រាសសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចក្រោមលេខចុះបញ្ជីពាណិជ្ជកម្ម Co. ០៨៣៩ E៤/២០១២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០១២។ ការិយាល័យចុះបញ្ជីរបស់ រ.ទ.ស.ភ មានទីតាំងស្ថិតនៅអគារលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ សកម្មភាពចម្បងរបស់រ.ទ.ស.ភ គឺការផលិត និងចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ទូទៅរបស់សាធារណជននៅរាជធានីភ្នំពេញ និងតំបន់ក្បែរដែលរួមមានក្រុងតាខ្មៅ ខេត្តត្បូងឃ្មុំ និងម្តេចក្នុងខេត្តកំពត ព្រមទាំងផ្តល់សេវាផ្សេងៗ។ គោលដៅរបស់ រ.ទ.ស.ភ គឺៈ

- វិនិយោគ កសាង ពង្រីក ដំណើរការ ជួសជុល និងថែទាំមធ្យោបាយសម្រាប់ផលិត និងចែកចាយទឹកស្អាត
- គ្រប់គ្រងបរិក្ខារដើម្បីបង្កើនផលិតកម្មទឹក ដោយបង្កើនសេវាកម្ម និងគុណភាពទឹកស្អាតដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់
- ដំណើរការអាជីវកម្ម សេវាកម្ម និងភារកិច្ចពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកស្អាត ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ធ្វើសហប្រតិបត្តិការលើផ្នែកបច្ចេកវិទ្យា ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុងស្រុក និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍន៍ រ.ទ.ស.ភ ទៅតាមគោលការណ៍របស់រដ្ឋាភិបាល និងធានាឱ្យបាននូវចិរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុសម្រាប់ផលប្រយោជន៍សាធារណៈ។

## ២. មូលដ្ឋាននៃការរៀបចំ

### ២.១ របាយការណ៍អនុលោមភាព

ព័ត៌មានហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "ស.រ.ទ.ហ.អ.ក)។

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ហៅកាត់ថា រ.ទ.ស.ភ ស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួង ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ហៅកាត់ថា ក.ស.ហ.វ) ហើយមានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ។ រ.ទ.ស.ភ ត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្មថាជាសហគ្រាសសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចក្រោមលេខចុះបញ្ជីពាណិជ្ជកម្ម Co. ០៨៣៩ E៤/២០១២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២។

**(ក)** ការធ្វើវិសោធនកម្ម ឬការកែសម្រួលស្តង់ដាដែលបានអនុវត្តន៍ក្នុងឆ្នាំ

- ការបង្ហាញគោលការណ៍គណនេយ្យ - វិសោធនកម្មលើ ស.គ.អ.ក ១ និងស.រ.ទ.ហ.អ.ក សេចក្តីថ្លែងការណ៍ស្តីពីការអនុវត្ត **២**

វិសោធនកម្មនេះតម្រូវឱ្យអង្គភាពបង្ហាញនូវព័ត៌មានគោលការណ៍គណនេយ្យជាសារវន្តរបស់ខ្លួនជាជាងគោលការណ៍គណនេយ្យសំខាន់ៗ។ វិសោធនកម្មនេះក្នុងចំណោមវិសោធនកម្មផ្សេងទៀតរួមទាំង ឧទាហរណ៍នៃកាលៈទេសៈណាមួយ ដែលអង្គភាពពិចារណាចាត់ជាព័ត៌មានគោលការណ៍គណនេយ្យមានភាពជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។ ដើម្បីជាជំនួយដល់ការធ្វើវិសោធនកម្មនេះ ស.រ.ទ.ហ. ទស្សនៈនៃភាពជាសារវន្តចំពោះការបង្ហាញព័ត៌មានគោលការណ៍គណនេយ្យ។ ការណែនាំនិងឧទាហរណ៍ដែលបានផ្តល់នៅ ស.រ.ទ.ហ.អ.ក សេចក្តីថ្លែងការណ៍ស្តីពីការអនុវត្ត២ បានសង្កត់ធ្ងន់ពីតម្រូវការក្នុងការផ្តោតលើព័ត៌មានជាក់លាក់របស់អង្គភាព និងបង្ហាញពីរបៀបដែលដំណើរការនៃភាពជាសារវន្ត៤ជំហានអាចកំណត់បាននូវព័ត៌មានស្តង់ដា ឬ (Boilerplate) និងការចម្លងតាមតម្រូវការរបស់ស.រ.ទ.ហ.អ.ក នៅក្នុងការបង្ហាញព័ត៌មានគោលការណ៍គណនេយ្យ។ ទោះបីជាវិសោធនកម្មទាំងនេះមិនបានប៉ះពាល់ដល់ការផ្លាស់ប្តូរគោលការណ៍គណនេយ្យក៏ដោយប៉ុន្តែវាមានផលប៉ះពាល់ដល់ព័ត៌មានគោលការណ៍គណនេយ្យដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការធ្វើវិសោធនកម្ម ឬការកែសម្រួលស្តង់ដាខាងក្រោមនេះ ត្រូវបានអនុវត្តន៍ដោយ រ.ទ.ស.ភ ប៉ុន្តែមិនមានផលប៉ះពាល់ជាសារវន្តទៅលើការិយបរិច្ឆេទបច្ចុប្បន្ន ឬលើការិយបរិច្ឆេទមុនៗឡើយ ហើយក៏មិនមានផលប៉ះពាល់ដល់ការិយបរិច្ឆេទនាពេលអនាគតឡើយ។

- និយមន័យនៃការប៉ាន់ស្មានគណនេយ្យ - វិសោធនកម្ម ស.គ.អ.ក៨
- ពន្ធពន្យាទាក់ទងនឹងទ្រព្យសកម្ម និងបំណុលដែលកើតឡើងពីប្រតិបត្តិការតែមួយ-វិសោធនកម្មលើ ស.គ.អ.ក ១២ ។

(ខ) ស្តង់ដា និងការធ្វើវិសោធនកម្ម/ការកែសម្រួលដែលបានចេញផ្សាយតែមិនទាន់ចូលជាធរមាន

| | | ថ្ងៃចូលជាធរមានអំឡុងការិយបរិច្ឆេទចាប់ផ្តើម ឬការិយបរិច្ឆេទបន្ទាប់ពី |
|---|---|---|
| ស.គ.អ.ក ១ | ចំណាត់ថ្នាក់នៃបំណុលជាបំណុលរយៈពេលខ្លី ឬរយៈពេលវែង | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |
| ស.គ.អ.ក ១ | បំណុលរយៈពេលវែងដែលមានកិច្ចព្រមព្រៀង | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |
| ស.រ.ទ.ហ.អ.ក ១៦ | បំណុលភតិសន្យាក្នុងការលក់ ហើយជួលត្រឡប់វិញ | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |
| ស.គ.អ.ក ៧ និង ស.រ.ទ.ហ.អ.ក.៧ | កិច្ចព្រមព្រៀងអ្នកផ្គត់ផ្គង់ហិរញ្ញវត្ថុ | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |
| ស.គ.អ.ក ១៧ | ការអនុវត្តដំបូងនៃ ស.រ.ទ.ហ.អ.ក ១៧ និង ស.រ.ទ.ហ.អ.ក ៩ – ព័ត៌មានប្រៀបធៀប | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |
| ស.រ.ទ.ហ.អ.ក ១០ និង ស.គ.អ.ក ២៨ | ការលក់ ឬបន្ថែមទ្រព្យសកម្មរវាងវិនិយោគិន និងញាតិសម្ព័ន្ធ ឬការបណ្តាក់ទុនរួម | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |

ស្តង់ដា និងវិសោធនកម្មពិពណ៌នាខាងលើនេះត្រូវបានចេញផ្សាយ ប៉ុន្តែមិនទាន់ចូលជាធរមានអំឡុងការិយបរិច្ឆេទចាប់ផ្តើម ឬការិយបរិច្ឆេទបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ និងមិនទាន់ត្រូវបានអនុវត្តន៍ដោយ រ.ទ.ស.ភ ជាមុននៅឡើយទេ។ ស្តង់ដាវិសោធនកម្ម ឬបំណកស្រាយទាំងនេះមិនត្រូវបានរំពឹងថាមានផលប៉ះពាល់ជាសារវន្តដល់អង្គភាពក្នុងការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ន ឬអនាគត និងប្រតិបត្តិការដែលរំពឹងទុកថានឹងអាចកើតមាននាពេលខាងមុខឡើយ។

**២.២ រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ**

របាយការណ៍ហិរញ្ញវត្ថុ គឺត្រូវបានបង្ហាញជាប្រាក់រៀលដែលជារូបិយប័ណ្ណមុខងាររបស់ រ.ទ.ស.ភ ហើយត្រូវបានបង្គត់ទៅខ្ទង់ពាន់លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

**២.៣ មូលដ្ឋាននៃការវាស់វែង**

របាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ បានរៀបចំតាមវិធីសាស្រ្តថ្លៃដើមប្រវត្តិសាស្រ្តលើកលែងតែមានបង្ហាញផ្សេងពីនេះនៅក្នុងកំណត់សម្គាល់៣នៃរបាយការណ៍ហិរញ្ញវត្ថុ។

**២.៤ ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ**

ផ្នែកដែលទាក់ទងទៅនឹងការវិនិច្ឆ័យ ឬមានភាពភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត់ និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ គឺត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់៤នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត

លើកលែងតែមានការចែងផ្សេងពីនេះ គោលការណ៍គណនេយ្យខាងក្រោមត្រូវបានអនុវត្តន៍ដោយសង្គតិភាពគ្រប់ការិយបរិច្ឆេទដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ។

**៣.១ ការប្តូររូបិយប័ណ្ណបរទេស**

ការប្តូររូបិយប័ណ្ណបរទេសនៅក្នុងឆ្នាំ ត្រូវបានប្តូរតាមអត្រាប្តូរប្រាក់បរទេសនាកាលបរិច្ឆេទនៃប្រតិបត្តិការ។ ទ្រព្យសកម្ម និង បំណុលរូបិយវត្ថុ ត្រូវបានកំណត់ជារូបិយប័ណ្ណបរទេស ដោយប្តូរតាមអត្រាប្តូរប្រាក់បរទេសនាចុងការិយបរិច្ឆេទរាយការណ៍។ ចំណេញ និង ខាតពីការប្តូររូបិយប័ណ្ណត្រូវបានកត់ត្រាក្នុងចំណេញ ឬខាត។ ទ្រព្យសកម្ម និង បំណុលមិនមែនរូបិយវត្ថុ ត្រូវបានវាស់វែងតាមថ្លៃវិធីសាស្រ្តថ្លៃដើមប្រវត្តិសាស្រ្តជារូបិយប័ណ្ណ បរទេសដែលត្រូវបានប្តូរតាមអត្រាប្តូរប្រាក់បរទេសនាកាលបរិច្ឆេទនៃប្រតិបត្តិការ។

**៣.២ ឧបករណ៍ហិរញ្ញវត្ថុ**

ឧបករណ៍ហិរញ្ញវត្ថុ ត្រូវបានកត់ត្រាក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅពេល និងខណៈពេលដែល រ.ទ.ស.ភ ក្លាយជាភាគីនៃបទបញ្ញត្តិកិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុប៉ុណ្ណោះ។

លើកលែងតែគណនីអតិថិជនពាណិជ្ជកម្ម ដែលមិនមានសមាសធាតុជាហិរញ្ញប្បទានគួរឱ្យកត់សម្គាល់ ឬដែលរ.ទ.ស.ភបានអនុវត្តន៍តាមតម្រូវការជាក់ស្តែង ឧបករណ៍ហិរញ្ញវត្ថុ គឺត្រូវបានទទួលស្គាល់ដំបូងនៅតម្លៃសមស្រ បូក ឬដក ថ្លៃដើមប្រតិបត្តិការដែលត្រូវបានកើតឡើងដោយផ្ទាល់ពីការទិញ ឬបោះផ្សាយនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ។ គណនីអតិថិជនពាណិជ្ជកម្មដែលមិនមានសមាសធាតុហិរញ្ញប្បទានសំខាន់ ឬដែល រ.ទ.ស.ភ បានអនុវត្តន៍តាមតម្រូវការជាក់ស្តែង ត្រូវបានវាស់វែងនៅតម្លៃប្រតិបត្តិការដែលបានកំណត់ដោយ ស.រ.ទ.ហ.អ.ក ១៥ ។

**(១) ទ្រព្យសកម្មហិរញ្ញវត្ថុ**

រ.ទ.ស.ភ ចាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម៖

ការវាស់វែងជាបន្តបន្ទាប់នៃឧបករណ៍បំណុលអាស្រ័យលើ គំរូអាជីវកម្មរបស់ រ.ទ.ស.ភ សម្រាប់ការគ្រប់គ្រងទ្រព្យសកម្ម និង លក្ខណៈលំហូរសាច់ប្រាក់នៃទ្រព្យសកម្មនោះ។ រ.ទ.ស.ភ បានចាត់ថ្នាក់ឧបករណ៍បំណុលរបស់ខ្លួនជាទ្រព្យសកម្មហិរញ្ញវត្ថុដោយវិធីសាស្រ្តរំលស់ថ្លៃដើម។ ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានរក្សាទុកសម្រាប់ប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា ហើយលំហូរសាច់ប្រាក់ទាំងនោះតំណាងឱ្យការទូទាត់នៃប្រាក់ដើមនិងការប្រាក់ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម។ ទ្រព្យសកម្មហិរញ្ញវត្ថុតាមរំលស់ថ្លៃដើមត្រូវបានវាស់វែងបន្ទាប់ដោយប្រើប្រាស់វិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព ហើយជា កម្មវត្ថុនៃឱនភាពតម្លៃ។ ចំណេញ ឬខាតត្រូវបានកត់ត្រាក្នុងចំណេញ ឬខាត នៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់កែតម្រូវ ឬធ្វើឱនភាពតម្លៃ។

**(២) បំណុលហិរញ្ញវត្ថុ**

រ.ទ.ស.ភ បានចាត់ថ្នាក់ឧបករណ៍បំណុលរបស់ខ្លួន ជាបំណុលហិរញ្ញវត្ថុក្នុងវិធីសាស្រ្តរំលស់ថ្លៃដើម។ បន្ទាប់ពីការទទួលស្គាល់ជាដំបូង បំណុលហិរញ្ញវត្ថុផ្សេងៗត្រូវបានវាស់វែងតាមវិធីសាស្រ្តរំលស់ថ្លៃដើម ដោយប្រើ វិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព។ ចំណេញ និងខាត ត្រូវបានកត់ត្រាក្នុងចំណេញ ឬ ខាត នៅពេលដែលបំណុល ហិរញ្ញវត្ថុត្រូវបានឈប់ទទួលស្គាល់ និងតាមរយៈដំណើរការរំលស់។

**៣.៣ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ**

ធាតុទាំងអស់នៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានទទួលស្គាល់ជាដំបូងនៅថ្លៃដើម ហើយបន្ទាប់មកទទួលស្គាល់នៅថ្លៃដើមដករំលស់បង្គរ និងឱនភាពក្នុងតម្លៃណាមួយ។ ថ្លៃដើមដំបូងនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានទទួលស្គាល់រួមទាំងតម្លៃនៃទ្រព្យសកម្ម និងចំណាយពាក់ព័ន្ធផ្សេងៗ ដែលបានកើតឡើង ដោយផ្ទាល់ក្នុងការនាំយកទ្រព្យសកម្មនោះទៅកាន់ទីតាំង និងស្ថិតក្នុងលក្ខខណ្ឌចាំបាច់សម្រាប់ប្រើប្រាស់ក្នុង ប្រតិបត្តិការដែលបានគ្រោងទុកដោយគណៈគ្រប់គ្រង។

គ្មានការកំណត់អាយុកាលលើការប្រើប្រាស់ដីធ្លីនោះទេ ដូច្នេះហើយវាមិនត្រូវបានយកមកធ្វើការរំលស់។ ទ្រព្យ សកម្មកំពុងសាងសង់ ដែលបានកត់ត្រាក្នុងទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ក៏មិនត្រូវបានយកមកធ្វើការរំលស់ដែរដោយសារតែទ្រព្យសកម្មទាំងនោះនៅមិនទាន់អាចប្រើប្រាស់បាននៅឡើយ។

ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារទាំងអស់ ក្រៅពីដីធ្លី និងទ្រព្យសកម្មកំពុងសាងសង់ត្រូវបានធ្វើការរំលស់ដោយ ប្រើប្រាស់វិធីសាស្ត្ររំលស់ថេរដោយបែងចែកតម្លៃរំលស់ទៅតាមអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មទាំងនោះ។

| | អាយុកាលប្រើប្រាស់ (ឆ្នាំ) |
|---|---|
| អគារ | ៣០-៥០ |
| គ្រឿងចក្រ | ៣ - ២០ |
| បំពង់បង្ហូរទឹក | ៦-៥០ |
| បរិក្ខារមន្ទីរពិសោធន៍ | ៦-៧ |
| គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ | ២-៧ |
| បរិក្ខារអគ្គិសនី | ២-២០ |
| យានយន្ត | ២-៧ |
| វ៉ាន និងឧបករណ៍ | ៣-១៥ |
| នាឡិកាទឹក | ៥-២០ |
| បណ្តាញតចូលផ្ទះ | ១២ |

### ៣.៤ សន្និធិ

សន្និធិត្រូវបានវាស់វែងតាមតម្លៃទាបជាងរវាងថ្លៃដើម និងតម្លៃដែលអាចទទួលបានមកវិញ។ ថ្លៃដើមត្រូវបានកំណត់ដោយមូលដ្ឋានថ្លៃដើមគិតជាមធ្យម។ ថ្លៃដើមរួមមាន ថ្លៃទិញបូកបញ្ចូលចំណាយផ្សេងៗ ដែលកើតឡើងក្នុងការនាំសន្និធិនោះមកកាន់ទីតាំង និងតាមលក្ខខណ្ឌព្រមព្រៀង។ សន្និធិរួមមានវត្ថុធាតុដើម វត្ថុប្រើប្រាស់ គ្រឿងបន្លាស់ដ៏ទៃទៀតដែលទាក់ទងនឹងការផ្គត់ផ្គង់ទឹក ហើយត្រូវកំណត់តម្លៃទៅតាមថ្លៃដើមពិតប្រាកដក្នុងការនាំយកសន្និធិដកនឹងចំណាយសំវិធានធនលើសន្និធិបាក់បែក សម្រាប់ការខូចខាត និងសន្និធិដែលមានចលនាប្រើប្រាស់ក្នុងប្រតិបត្តិការយឺតដោយប្រើប្រាស់មូលដ្ឋានថ្លៃដើមគិតជាមធ្យម។ គ្រឿងបន្លាស់ និងសន្និធិដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកដែលមានអាយុកាលលើសពីមួយឆ្នាំត្រូវទទួលស្គាល់ជាទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ នៅពេលដាក់ចូលទៅក្នុងការប្រើប្រាស់។

៣.៥ កិច្ចសន្យាទ្រព្យសកម្ម(បំណុល)

គឺជាសិទ្ធិក្នុងការទទួលបានផលប្រយោជន៍ជាថ្នូរនឹងការផ្ទេរទំនិញឬសេវាកម្មទៅឱ្យអតិថិជននៅពេលដែលសិទ្ធិនោះត្រូវបានបំពេញស្ថិតតាមក្នុងលក្ខខណ្ឌជាជាងពេលវេលា ដែលបានកន្លងផុតទៅ (ឧទាហរណ៍៖ ការបំពេញកាតព្វកិច្ចនាពេលអនាគតរបស់ រ.ទ.ស.ភ)។ កិច្ចសន្យាទ្រព្យសកម្ម ត្រូវបានផ្ទេរទៅជាគណនីត្រូវទទួលនៅពេលដែលសិទ្ធិមិនស្ថិតក្រោមលក្ខខណ្ឌ ពេលដែល រ.ទ.ស.ភ បានចេញវិក្កយបត្រទៅឱ្យអតិថិជន។

កិច្ចសន្យាបំណុល គឺជាកាតព្វកិច្ចផ្ទេរទំនិញ ឬសេវាកម្មជូនអតិថិជនដែល រ.ទ.ស.ភ បានទទួលផលតបស្នង ឬ ការទូទាត់ពីអតិថិជន។

**ចំណូលពីកិច្ចសន្យាជាមួយអតិថិជន**

ត្រូវបានទទួលស្គាល់ដោយយោងតាមកាតព្វកិច្ចត្រូវបំពេញផ្សេងគ្នាក្នុងកិច្ចសន្យាជាមួយអតិថិជនពោលគឺ នៅពេលកាតព្វកិច្ចត្រូវបំពេញក្នុងកិច្ចសន្យាជាមួយអតិថិជនត្រូវបានបំពេញ។ កាតព្វកិច្ចត្រូវបានបំពេញនៅពេលដែលអតិថិជនទទួលបានការគ្រប់គ្រងទំនិញ ឬសេវានោះ ក្រោម កាតព្វកិច្ចត្រូវអនុវត្តន៍ជាក់លាក់ ដែលកាតព្វកិច្ចត្រូវអនុវត្តន៍ជាក់លាក់នោះអាចត្រូវបានបំពេញនៅពេលជាក់លាក់ណាមួយ ឬតាមពេល។

៣.៦ ចំណូល និងចំណូលផ្សេងៗ

រ.ទ.ស.ភ ទទួលស្គាល់ចំណូលនៅពេលដែលទំនិញ ឬសេវាត្រូវបានផ្ទេរទៅអតិថិជនក្នុងទឹកប្រាក់ដែលឆ្លុះបញ្ចាំងការតបស្នងដែលរ.ទ.ស.ភ រំពឹងថានឹងទទួលបានក្នុងការដោះដូរទំនិញ ឬសេវានោះ។

ការទទួលស្គាល់ចំណូលរបស់ រ.ទ.ស.ភ ត្រូវបានអនុវត្តសម្រាប់កិច្ចសន្យានីមួយៗ ជាមួយនឹងអតិថិជន ឬការបញ្ចូលគ្នានៃកិច្ចសន្យាជាមួយនឹងអតិថិជនដូចគ្នា (ឬភាគីពាក់ព័ន្ធរបស់អតិថិជន)។ ជាការអនុវត្តជាក់ស្តែង រ.ទ.ស.ភ បានអនុវត្តការទទួលស្គាល់ចំណូលចំពោះផលវិបត្តិនៃកិច្ចសន្យា (ឬកាតព្វកិច្ចដែលត្រូវបំពេញ) ជាមួយនឹងលក្ខណៈស្រដៀងគ្នា ប្រសិន រ.ទ.ស.ភ រំពឹងថា ផលប៉ះពាល់លើរបាយការណ៍ហិរញ្ញវត្ថុមិនខុសគ្នា ខ្លាំងពីការទទួលស្គាល់ចំណូលលើកិច្ចសន្យានីមួយៗ (ឬកាតព្វកិច្ចដែលត្រូវបំពេញ) ជាមួយនឹងផលវិបត្តិនោះ។

រ.ទ.ស.ភ វាស់វែងចំណូលពីការលក់ទំនិញ ឬផ្តល់សេវាកម្មនៅថ្លៃប្រតិបត្តិការ គឺជាការតបស្នង ដែល រ.ទ.ស.ភ រំពឹងទុកថានឹងទទួលបាននៅពេលដោះដូរទំនិញ ឬផ្តល់សេវាតាមការព្រមព្រៀងទៅឱ្យអតិថិជនដែលមិនរាប់បញ្ចូលទឹកប្រាក់ដែលប្រមូលបានជំនួសភាគីទីបី ដូចជាពន្ធលើសេវាកម្ម និយ័តកម្មលើផលប៉ះពាល់ការតបស្នង អថេរ ការប៉ាន់ស្មានការតបស្នងអថេរ ជាតុហិរញ្ញប្បទានសំខាន់ៗ ការតបស្នងលើជាតុមិនមែនសាច់ប្រាក់ និង ការតបស្នងត្រូវទូទាត់ឱ្យអតិថិជន។ ប្រសិនបើថ្លៃប្រតិបត្តិការ រួមទាំងការតបស្នងអថេរ រ.ទ.ស.ភ ប្រើប្រាស់ វិធីសាស្ត្រតម្លៃរំពឹងទុក ដោយការប៉ាន់ស្មានសមតុល្យសរុប ប្រូបាប៊ីលីតេគិតជាមធ្យមចំនួនក្នុងចន្លោះ ឬចំនួនទឹក ប្រាក់តបស្នង ឬតាមវិធីសាស្ត្រលទ្ធផល ដោយផ្អែកលើវិធីសាស្ត្រណាដែល រ.ទ.ស.ភ រំពឹងទុកថាការព្យាករណ៍ ដែលល្អប្រសើរជាងគេសម្រាប់ទឹកប្រាក់តបស្នងអាចទទួលបានដែលត្រូវបានទទួល។ សម្រាប់កិច្ចសន្យាដែលមានកាតព្វកិច្ចត្រូវបំពេញដាច់ដោយឡែក ថ្លៃប្រតិបត្តិការត្រូវបានធ្វើការបែងចែកដោយឡែកទៅតាមការបែងចែកកាតព្វកិច្ចត្រូវបំពេញនោះដោយផ្អែកលើមូលដ្ឋានថ្លៃលក់ទោល។

ប្រសិនបើថ្លៃលក់ទោល នោះមិនអាចអង្កេតដោយផ្ទាល់បាន រ.ទ.ស.ភ ត្រូវធ្វើការប៉ាន់ស្មានដោយប្រើប្រាស់ថ្លៃដើមរំពឹងទុកបូកនឹងគម្លាត ចំណេញ។

ចំណូលពីកិច្ចសន្យាជាមួយអតិថិជន ត្រូវបានទទួលស្គាល់ដោយយោងតាមកាតព្វកិច្ចត្រូវបំពេញផ្សេងគ្នាក្នុងកិច្ចសន្យាជាមួយអតិថិជន ពោលគឺ នៅពេលកាតព្វកិច្ចត្រូវបំពេញក្នុងកិច្ចសន្យាជាមួយអតិថិជនត្រូវបានបំពេញ។ កាព្វកិច្ចត្រូវបំពេញត្រូវបានបំពេញនៅពេលដែលអតិថិជនទទួលបានការគ្រប់គ្រងទំនិញ ឬសេវានោះក្រោមកាតព្វកិច្ចត្រូវអនុវត្តន៍ជាក់លាក់ ដែលកាតព្វកិច្ចត្រូវអនុវត្តន៍ជាក់លាក់នោះអាចត្រូវបានបំពេញនៅពេលជាក់លាក់ណាមួយ ឬតាមពេល។ ការកែប្រែកិច្ចសន្យាជាការផ្លាស់ប្តូរនៅវិសាលភាព ឬថ្លៃ (ឬទាំងពីរ) នៃកិច្ចសន្យាដែលត្រូវបានអនុម័តដោយភាគីនៅក្នុងកិច្ចសន្យា។ ការកែប្រែកើតមាននៅពេលដែលមានការផ្លាស់ប្តូរថ្មី ឬការផ្លាស់ប្តូរសិទ្ធិ និងកាតព្វកិច្ច របស់ភាគីក្នុងកិច្ចសន្យា។ រ.ទ.ស.ភ បានវាយតម្លៃប្រភេទនៃការកែប្រែ និងចាត់ទុកជាការរៀបចំកិច្ចសន្យាថ្មីដាច់ដោយឡែកបញ្ចប់កិច្ចសន្យាដែលមានស្រាប់ និងបង្កើតកិច្ចសន្យាថ្មី ឬរៀបចំផ្នែកណាមួយនៃកិច្ចសន្យាដែលមានស្រាប់។

**ចំណូលបានមកពីការផ្គត់ផ្គង់ទឹក**

ចំណូលពីការផ្គត់ផ្គង់ទឹកត្រូវបានទទួលស្គាល់ក្នុងពេលជាក់លាក់មួយនៅពេលដែល រ.ទ.ស.ភ បានបំពេញកាតព្វកិច្ចរបស់ខ្លួនដោយផ្អែកលើការប្រើប្រាស់ទឹករបស់អតិថិជន រ.ទ.ស.ភ។ ប្រើប្រាស់ទឹករបស់អតិថិជន និងនៅពេលដែលទឹកត្រូវបានផ្គត់ផ្គង់ដោយ រ.ទ.ស.ភ ។

**៣.៧ ជំនួយពីរដ្ឋាភិបាល**

ជំនួយពីរដ្ឋាភិបាលនិងភ្នាក់ងារអភិវឌ្ឍន៍ផ្សេងទៀតត្រូវបានទទួលស្គាល់នៅពេលដែលមានអំណះអំណាងដែលសមហេតុផលថាជំនួយនឹងត្រូវទទួលបានហើយរ.ទ.ស.ភនឹងអនុលោមទៅតាមលក្ខខណ្ឌទាំងអស់ដែលមានភ្ជាប់នឹងជំនួយនោះ។ ជំនួយនឹងត្រូវបានពន្យា និងទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ ចាំបាច់ ដើម្បីធ្វើឱ្យមានសមាមាត្រទៅនឹងថ្លៃដើមដែលត្រូវបានទូទាត់។ ជំនួយពន្យាត្រូវបានចាត់ថ្នាក់ជាបំណុលរយៈវែង និងត្រូវកត់ត្រាជាចំណូលនៅក្នុងរបាយការណ៍លទ្ធផលលម្អិត តាមវិធីសាស្ត្ររំលស់ថេរ ដើម្បីផ្គូផ្គងនឹងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មនោះ។

**៣.៨ បន្ទុកលើប្រាក់កម្ចី**

បន្ទុកលើប្រាក់កម្ចីដែលចូលរួមដោយផ្ទាល់ក្នុងការទិញ ការសាងសង់ ឬការផលិតនៃទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាតដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ បន្ទុកលើប្រាក់កម្ចីដែលមិនចូលរួមដោយផ្ទាល់ក្នុងការទិញ ការសាងសង់ ឬការផលិតនៃទ្រព្យសកម្មដែលមានលក្ខណៈគ្រប់គ្រាន់ គឺទ្រព្យសកម្មដែលត្រូវការពេលវេលាច្រើន ដើម្បីរួចរាល់សម្រាប់ប្រើប្រាស់ ឬលក់ ត្រូវធ្វើមូលធនីយកម្មដែលជាផ្នែកមួយនៃថ្លៃដើមនៃទ្រព្យសកម្មទាំងនោះ រហូតដល់ពេលដែលទ្រព្យសកម្មនោះរួចរាល់សម្រាប់គោលបំណងប្រើប្រាស់។

រ.ទ.ស.ភ ចាប់ផ្តើមធ្វើមូលធនីយកម្មលើប្រាក់កម្ចី នៅពេលដែល រ.ទ.ស.ភ កើតមានចំណាយសម្រាប់ទ្រព្យសកម្ម បន្ទុកលើប្រាក់កម្ចីពាក់ព័ន្ធនឹងអនុវត្តន៍សកម្មទាំងឡាយដែលចាំបាច់ ដើម្បីរៀបចំទ្រព្យសកម្ម សម្រាប់គោលបំណងប្រើប្រាស់ ។

**៣.៩ ចំណេញក្នុងមួយភាគហ៊ុន**

រ.ទ.ស.ភ បង្ហាញព័ត៌មានចំណេញគោលក្នុងមួយភាគហ៊ុនសម្រាប់ភាគហ៊ុនធម្មតារបស់ខ្លួន។ ចំណេញគោលក្នុងមួយភាគហ៊ុនត្រូវបានគណនាដោយបែងចែកប្រាក់ចំណេញ ឬខាតទៅឱ្យភាគហ៊ុនិកធម្មតារបស់ រ.ទ.ស.ភ តាមវិធីសាស្ត្រគិតជាមធ្យមនៃចំនួនភាគហ៊ុនធម្មតាដែលមានក្នុងគ្រា។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង ឆ្នាំ២០២២ ពុំមានសក្តានុពលចំណេញថយចុះក្នុងមួយភាគហ៊ុនទេ។ ដូច្នេះហើយទើបចំណេញថយចុះក្នុង មួយភាគហ៊ុនស្មើនឹងចំណេញគោលក្នុងមួយភាគហ៊ុន។

**៣.១០ ចំណែកនៃប្រតិបត្តិការ**

ចំណែកនៃប្រតិបត្តិការត្រូវបានរាយការណ៍ក្នុងលក្ខណៈមួយដោយសមស្របជាមួយនឹងការរាយការណ៍ផ្ទៃក្នុង ដែលបានផ្តល់ដោយប្រធានផ្នែកប្រតិបត្តិការដែលមានសិទ្ធិក្នុងការសម្រេចចិត្ត។ អគ្គនាយក រ.ទ.ស.ភ ដែល ជាអ្នកទទួលខុសត្រូវក្នុងការបែងចែកធនធាន និងវាយតម្លៃការអនុវត្តចំណែកនៃប្រតិបត្តិការ ត្រូវបានគេ កំណត់ថាជាអ្នកធ្វើការសម្រេចចិត្តលើប្រតិបត្តិការយុទ្ធសាស្ត្រនានា។

**៤. ការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតគណនេយ្យសំខាន់ៗ**

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស.រ.ទ.ហ.អ.ក ដែលតម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មាន និងការសន្មតគណនេយ្យជាក់លាក់មួយចំនួនដែលជះឥទ្ធិពលដល់ចំនួនទឹកប្រាក់ដែលត្រូវបានរាយការណ៍នៃទ្រព្យសកម្ម និងបំណុល និងការបង្ហាញពីទ្រព្យសកម្ម និងបំណុលយថាហេតុនាកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងទឹកប្រាក់ដែលត្រូវបានរាយការណ៍នៃចំណូលនិងចំណាយរាយការណ៍ក្នុងគ្រា។ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការពិនិត្យវិនិច្ឆ័យលើការវិនិច្ឆ័យក្នុងដំណើរការអនុវត្តគោលការណ៍គណនេយ្យនេះផងដែរ។ ទោះបីជាការប៉ាន់ស្មាន និងការវិនិច្ឆ័យដោយផ្អែកលើចំណេះដឹង និងព្រឹត្តិការណ៍នាពេលបច្ចុប្បន្នរបស់ក្រុមប្រឹក្សាភិបាលក៏ដោយក៏លទ្ធផលជាក់ស្តែងអាចនឹងមានភាពខុសគ្នា។ផ្នែកសំខាន់ៗនៃការប៉ាន់ស្មាន ភាពមិនប្រកដប្រជា និងការវិនិច្ឆ័យសំខាន់ក្នុងការអនុវត្តតាមគោលការណ៍គណនេយ្យដែលមានផលប៉ះពាល់ជាសារវន្តក្នុងការកំណត់ចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម៖

**៤.១ ការកំណត់រូបិយប័ណ្ណមុខងារ**

រ.ទ.ស.ភ ដំណើរការប្រតិបត្តិការក្នុងប្រទេសកម្ពុជា និងធ្វើប្រតិបត្តិការទិញ និងប្រតិបត្តិការផ្សេងៗជារូបិយប័ណ្ណ ជាច្រើន។ ការវិនិច្ឆ័យត្រូវបានអនុវត្តន៍ក្នុងការកំណត់រូបិយប័ណ្ណមុខងារ នៅពេលដែលមានសូចនាកររួម។ រ.ទ.ស.ភ ប្រើឋានុក្រមសូចនាករនៃការលក់ជាមូលដ្ឋានចម្បង បន្ទាប់មកដោយការទិញ និងសូចនាករនៃចំណាយ ប្រតិបត្តិការ និងករណីដែលសូចនាករទាំងនោះ ពុំមានការសន្និដ្ឋានទេ រូបិយប័ណ្ណកម្ចី និងមូលនិធិផ្សេងទៀត ត្រូវបានលើកឡើងសម្រាប់ផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិការ ។

**៤.២ រំលស់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ**

រ.ទ.ស.ភបានពិនិត្យតម្លៃកាកសំណល់ អាយុកាលប្រើប្រាស់និងវិធីសាស្ត្ររំលសរាល់ចុងគ្រារាយការណ៍នីមួយៗ។ ការប៉ាន់ស្មានត្រូវបានប្រើប្រាស់ក្នុងការជ្រើសរើសវិធីសាស្ត្ររំលស់អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់។ ការប្រើប្រាស់ជាក់ស្តែងនៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារអាចខុសគ្នាពីការប៉ាន់ស្មានដែលបានប្រើប្រាស់ ដូចនេះរំលស់នាពេលអនាគតអាចត្រូវបានកែតម្រូវឡើងវិញ។

តម្លៃយោងរបស់ទ្រព្យសម្បត្តិរោងចក្រ និងបរិក្ខាររបស់ រ.ទ.ស.ភ ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ ៥ នៃរបាយការណ៍ហិរញ្ញវត្ថុ។

**៤.៣ ឱនភាពតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងកិច្ចសន្យាទ្រព្យសកម្ម**

សំវិធានធនឱនភាពតម្លៃសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ និងកិច្ចសន្យាទ្រព្យសកម្ម គឺផ្អែកលើការសន្មតពីហានិភ័យ នៃការខកខានមិនបានសង និងអត្រាការខាតបង់ឥណទានរំពឹងទុក។ រ.ទ.ស.ភ ប្រើប្រាស់ការវិនិច្ឆ័យក្នុងការធ្វើការសន្មត និងជ្រើសរើសធាតុចូលក្នុងការគណនាឱនភាពតម្លៃ ដោយផ្អែកលើប្រវត្តិរបស់ រ.ទ.ស.ភ ស្ថានភាពទីផ្សារបច្ចុប្បន្ន ក៏ដូចជាការប៉ាន់ស្មានពេលខាងមុខនៅចុងបញ្ចប់នៃគ្រារបាយការណ៍នីមួយៗ។ ពត៌មានអំពីការខាតបង់នៃឱនភាពតម្លៃលើទ្រព្យសកម្មហិរញ្ញវត្ថុ និងកិច្ចសន្យាទ្រព្យសកម្មរបស់ រ.ទ.ស.ភ ត្រូវ បានបង្ហាញក្នុងកំណត់សម្គាល់ ២៥(ក) នៃរបាយការណ៍ហិរញ្ញវត្ថុ។

**៤.៤ ការទទួលស្គាល់ចំណូលទាក់ទងនឹងចំណូលពីថ្លៃទឹកបង្ករ**

ចំណូលថ្លៃទឹកបង្ករ ត្រូវបានទទួលស្គាល់ដោយផ្អែកលើបរិមាណទឹកផលិត បរិមាណទឹកដែលបានចេញវិកយបត្រ បរិមាណទឹកបាត់បង់ជាមធ្យម និងតារាងតម្លៃជាមធ្យមតាមប្រភេទអតិថិជន។ ក្រុមប្រឹក្សាភិបាលប្រើប្រាស់ស្ថិតិ នៃអត្រាបរិមាណទឹកបាត់បង់ និងតារាងតម្លៃជាមធ្យមដោយផ្អែកលើបទពិសោធន៍កន្លងមកដែលមិនអាចឆ្លុះបញ្ចាំងពីអត្រាពិតប្រាកដ និងស្ថានភាពនាពេលបច្ចុប្បន្នឱ្យបានត្រឹមត្រូវនោះឡើយ។

**៤.៥ ការវាស់វែងពន្ធលើប្រាក់ចំណូល**

ការវិនិច្ឆ័យសំខាន់ គឺចាំបាច់ក្នុងការកំណត់ការប៉ាន់ស្មានសម្រាប់ពន្ធក្នុងគ្រា និងពន្ធពន្យា ដោយ រ.ទ.ស.ភ ព្រោះបំណុលពន្ធចុងក្រោយសម្រាប់ រ.ទ.ស.ភ មិនមានភាពប្រាកដប្រជា។ នៅពេលដែលលទ្ធផលចុងក្រោយនៃពន្ធ ដែលត្រូវបានកំណត់ដោយអាជ្ញាធរពន្ធដារ ទឹកប្រាក់ទូទាត់ពន្ធនេះអាចខុសគ្នាពីការប៉ាន់ស្មានដំបូងនៃប្រាក់ពន្ធ ដែលត្រូវទូទាត់។ ចំនួនដែលខុសគ្នានោះអាចមានផលប៉ះពាល់លើពន្ធក្នុងគ្រាពន្ធពន្យា និងពន្ធប្រយោលនានា ក្នុងគ្រាដែលបានកំណត់។ រ.ទ.ស.ភ នឹងធ្វើនិយ័តកម្មពន្ធក្នុងគ្រា ឬពន្ធពន្យាដែលពាក់ព័ន្ធនឹងឆ្នាំមុនក្នុងគ្រា បច្ចុប្បន្នលើភាពខុសគ្នាទាំងនោះ។ ចំណាយពន្ធលើប្រាក់ចំណូលរបស់ រ.ទ.ស.ភ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់២០នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ៣.៣ ការរៀបចំគោលនយោបាយគណនេយ្យផ្ដល់ផលប្រយោជន៍ដល់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ការរៀបចំគោលនយោបាយគណនេយ្យ សម្រាប់ក្រុមហ៊ុនត្រូវបានធ្វើដោយការត្រួតពិនិត្យ និងអនុវត្តន៍គោលនយោបាយគណនេយ្យដែលមានប្រសិទ្ធភាព។ គោលនយោបាយនេះ គួរតែគោរពនឹងគោលការណ៍គណនេយ្យដែលបានទទួលស្គាល់និងផ្ដល់ប្រយោជន៍ដល់ក្រុមហ៊ុនតាមរយៈការអនុវត្តបច្ចេកទេសគណនេយ្យដែលមានប្រសិទ្ធភាពសម្រាប់ក្រុមហ៊ុន។

**១. ការបង្កើនតម្លាភាព និងភាពជឿជាក់៖** ការរៀបចំគោលនយោបាយគណនេយ្យល្អបានជួយឱ្យ PPWSA បង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុមានភាពត្រឹមត្រូវ និងតម្លាភាព។

**២. ការដឹកនាំការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុមានភាពប្រសើរ៖** គោលនយោបាយគណនេយ្យជួយឱ្យក្រុមហ៊ុនមានគន្លងច្បាស់លាស់ក្នុងការបង្កើត កត់ត្រា និងបង្ហាញព័ត៌មានហិរញ្ញវត្ថុហើយវាជួយឱ្យការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុមានមូលដ្ឋានលើទិន្នន័យត្រឹមត្រូវ។

៣. **គណនេយ្យ និងហិរញ្ញវត្ថុ៖** ជួយសម្រួលដល់ការរៀបចំផែនការប្រកបដោយវិជ្ជាជីវៈ និងគុណភាព។

៤. **ការស្របតាមច្បាប់ និងបទបញ្ញា៖** សម្រាប់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញដែលស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋ ឬមានកិច្ចព្រមព្រៀងជាមួយអង្គភាពជាតិ និងអន្តរជាតិធ្វើឱ្យមានគោលនយោបាយគណនេយ្យល្អជួយឱ្យស្របច្បាប់ និងជៀសវាងការពិន័យ។

៥. **ជំនួយក្នុងការទាក់ទាញការវិនិយោគ និងឥណទាន៖** បើរបាយការណ៍ហិរញ្ញវត្ថុមានភាពជាក់លាក់ និងការជឿជាក់ គឺបានជួយក្រុមហ៊ុនឱ្យមានភាពទាក់ទាញអ្នកវិនិយោគ ឬស្ថាប័នហិរញ្ញវត្ថុដែលផ្ដល់ឥណទាន។

៦. **ការគ្រប់គ្រងចំណាយ និងប្រាក់ចំណេញបានប្រសើរ៖** គោលនយោបាយគណនេយ្យដែលល្អអាចជួយកំណត់ថាចំណាយណាអាចកាត់បន្ថយបាន និងផ្តល់ឱកាសសម្រាប់កែលម្អលើប្រសិទ្ធភាពក្នុងការបម្រើអតិថិជន។

### ៣.៣.១ មូលដ្ឋាននៃការរៀបចំគោលនយោបាយគណនេយ្យ

គណនេយ្យរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញឆ្នាំ ២០២៣ មានន័យថាគោលនយោបាយនេះនឹងផ្តោតទៅលើការកំណត់ និងរៀបចំវិធានការអំពីវិស័យគណនេយ្យនៃក្រុងភ្នំពេញដែលមានចំណុចសំខាន់ដូចជា៖

១ **ការប្រើប្រាស់ធនធានសាធារណៈ៖** គោលនយោបាយនេះនឹងកំណត់ពីរបៀបដែលធនធានរបស់រដ្ឋាភិបាលត្រូវបានប្រើប្រាស់ក្នុងការរក្សា និងធ្វើការផ្គត់ផ្គង់សេវាកម្មដល់ប្រជាជន។

២ **ការបញ្ចុះបញ្ចូលប្រព័ន្ធគណនេយ្យ៖** នេះជាការត្រូវបានប្រើប្រាស់ប្រព័ន្ធគណនេយ្យសម្រាប់ការសម្រេចចិត្តលើការចំណាយ និងការប្រមូលប្រាក់ពន្ធ។

៣ **ការជ្រៀតជ្រែកលើការអភិវឌ្ឍន៍៖** គោលនយោបាយនេះអាចមានការផ្តោតលើការចំណាយក្នុងវិស័យសុខាភិបាល សិក្សា បច្ចេកវិទ្យា និងការអភិវឌ្ឍន៍បណ្តាប្រជាជន។វាគឺជាការគ្រប់គ្រងប្រព័ន្ធគណនេយ្យ ដែលមានគោលបំណងធ្វើឱ្យប្រសើរឡើងការប្រើប្រាស់ធនធានសាធារណៈ និងធានាឱ្យមានការត្រួតពិនិត្យ និងអត្រាដែលត្រឹមត្រូវក្នុងការចំណាយរបស់រដ្ឋាភិបាល។

### ៣.៣.២ វិធីសាស្រ្តក្នុងការរៀបចំគោលនយោបាយគណនេយ្យ

គោលនយោបាយគណនេយ្យរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញក្នុងឆ្នាំ ២០២៣ អាចមានវិធីសាស្រ្តដូចតទៅ៖

១ **កំណត់គោលបំណង និងគោលនយោបាយសំខាន់៖** ត្រូវកំណត់គោលបំណងអំពីការប្រើប្រាស់ថវិកាជាពិសេសសម្រាប់ការជួយសង្គ្រោះនិងការកែលម្អបរិស្ថាននៅក្រុងភ្នំពេញ និងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទឹកស្វយ័ត។

២ **បរិច្ឆាគថវិកាសម្រាប់គម្រោងពាក់ព័ន្ធ៖** ការពិនិត្យអំពីថវិកាដែលត្រូវការដើម្បីគាំទ្រគម្រោង និងសកម្មភាពនានា ដូចជាការកែលម្អប្រព័ន្ធទឹកស្វយ័ត និងការបង្កើនសេវាកម្មទឹកស្អាតសម្រាប់ប្រជាជន។

៣ **ការពិនិត្យស្ថានភាពហិរញ្ញវត្ថុ៖** ការវិភាគប្រតិបត្តិការអំពីចំណូល និងចំណាយរបស់អាជ្ញាធរទឹកស្វយ័តក្នុងឆ្នាំកន្លងមក ដើម្បីបញ្ជាក់ថាគោលនយោបាយមានភាពអាចទុកចិត្ត និងមានប្រសិទ្ធភាព។

៤ **ការចុះបញ្ជី និងគ្រប់គ្រងប្រាក់ចំណូល៖** រៀបចំប្រព័ន្ធគ្រប់គ្រងប្រាក់ចំណូលពីការលក់ទឹក និងសេវាកម្មទឹកស្វយ័តដែលអាចប្រើប្រាស់បានក្នុងការលើកកម្ពស់នូវគម្រោងផ្សេងៗ។

**៥ គាំទ្រការកែសម្រួលបញ្ហាផ្សេងៗ៖** ដូចជាបញ្ហាការប្រាក់អាក្រក់, ការប្រកួតប្រជែងគ្នា និងការគ្រប់គ្រងទឹកស្វយ័តឱ្យមានប្រសិទ្ធភាព។

**៦ ការបង្ហោះនូវកំណត់ត្រាអំពីការចំណាយ៖** ត្រូវកំណត់ប្រភេទការចំណាយដែលមានសារៈសំខាន់ សម្រាប់ប្រើប្រាស់ប្រាក់ចំណូលក្នុងសកម្មភាពដើម្បីជានា ជូនប្រជាជនទទួលបានសេវាកម្មល្អ។

**៧ វិធីសាស្ត្របង្ក្រាប និងវាយតម្លៃផលប៉ះពាល់៖** មានការអនុវត្តប្រព័ន្ធវាយតម្លៃប្រសិទ្ធភាពគោលនយោបាយ និងគម្រោងផ្សេងៗ ដើម្បីប្រើប្រាស់ប្រាក់ និងធនធានបានយ៉ាងមានប្រសិទ្ធភាព។

**៨ ការពិភាក្សា និងការចូលរួមពីសមាជិកសាធារណៈ៖** ត្រូវមានកន្លែងសម្រាប់ស្វាគមន៍មតិពិភាក្សា និងការបញ្ចូលគំនិតពីសមាជិកក្នុងសហគមន៍ ដើម្បីធ្វើឱ្យគោលនយោបាយនេះមានប្រសិទ្ធភាព និងការគាំទ្រច្រើន។

**៩ ការកំណត់គោលការណ៍នៃការបញ្ជូន និងប្រើប្រាស់ថវិកា៖** វិធីសាស្ត្រនេះគឺជាការពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យតាមស្តង់ដាអន្តរជាតិនិងការអនុវត្តគោលការណ៍នៃការប្រើប្រាស់ថវិកា។

ការរៀបចំគោលនយោបាយគណនេយ្យនេះមានសារសំខាន់ក្នុងការធានាថាប្រព័ន្ធទឹកស្វយ័តក្រុងភ្នំពេញអាចផ្តល់សេវាកម្មដល់ប្រជាជនក្នុងលទ្ធភាពល្អបំផុត។

### ៣.៣.៣ លទ្ធផលនៃការរៀបចំគោលនយោបាយគណនេយ្យ

លទ្ធផលនៃការរៀបចំគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានបែងចែកជាផ្នែកសំខាន់ៗដូចខាងក្រោម៖

**១. ការបង្កើនភាពជឿជាក់នៃរបាយការណ៍ហិរញ្ញវត្ថុ៖** ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញអាចបង្ហាញពីស្ថានភាពហិរញ្ញវត្ថុពិតប្រាកដទៅដល់អតិថិជន អ្នកវិនិយោគ និងអាជ្ញាធរ ហើយថែមទាំងមានឯកសារត្រឹមត្រូវដោយគ្មានការបញ្ចេញព័ត៌មានខុសឬលាក់លៀម។

**២. ការគ្រប់គ្រងធនធានហិរញ្ញវត្ថុមានភាពប្រសើរឡើង៖** អាចវាស់វែងពីចំណូល ចំណាយបានច្បាស់លាស់ និងគ្រប់គ្រងថវិកាឱ្យមានប្រសិទ្ធភាពព្រមទាំងជួយសម្រេចគោលដៅសេដ្ឋកិច្ចក្នុងរយៈពេលខ្លី និងវែង។

**៣. ការស្របច្បាប់ និងជៀសវាងបញ្ហាផ្នែកសារពើពន្ធ៖** គោលនយោបាយគណនេយ្យដែលបានរៀបចំស្របតាមស្តង់ដា នឹងជួយក្រុមហ៊ុនចៀសវាងពីការពិន័យ ឬក៏ការស៊ើបអង្កេតពីអាជ្ញាធរ។

**៤. ការកែលម្អប្រព័ន្ធគ្រប់គ្រងក្នុងអង្គភាព៖** បុគ្គលិកផ្នែកហិរញ្ញវត្ថុដឹងច្បាស់ពីនីតិវិធីក្នុងការកត់ត្រា និងរាយការណ៍ ជួយកាត់បន្ថយនូវកំហុស និងការលំបាកក្នុងការអធិប្បាយអំពីទិន្នន័យហិរញ្ញវត្ថុ។

**៥. ការទាក់ទាញវិនិយោគ និងគាំទ្រពីស្ថាប័នហិរញ្ញវត្ថុ៖** ព័ត៌មានហិរញ្ញវត្ថុដែលជាក់លាក់ និងមានស្តង់ដាធ្វើឱ្យស្ថាប័ន ឬអ្នកវិនិយោគមានទំនុកចិត្តច្រើនក្នុងការផ្តល់ធនធាន ឬរួមភាគហ៊ុន។

**៦. ជំនួយក្នុងការសម្រេចចិត្តយុទ្ធសាស្ត្រអាជីវកម្ម៖** ព័ត៌មានហិរញ្ញវត្ថុស្របនិងគោលនយោបាយគណនេយ្យនិងជួយឱ្យអ្នកគ្រប់គ្រងធ្វើការសម្រេចចិត្តឱ្យបាននូវយុទ្ធសាស្ត្រច្បាស់លាស់ សម្រាប់ការពង្រីកទីផ្សារ ឬការវិនិយោគបន្ថែម។

# ជំពូកទី៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគចំណុចខ្លាំង

ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញអស់រយៈពេលជាច្រើនខែកន្លងមកយើងទទួលបាននូវចំណេះដឹងជាច្រើនពីក្រុមហ៊ុនក្នុងការរៀបចំគោលនយោបាយគណនេយ្យ និងវិធីសាស្រ្តផ្សេងៗជាច្រើនទៀតដែលទាក់ទងនឹងក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។ ទន្ទឹមនិងនេះផងដែរយើងបានសង្កេតឃើញនៅចំណុចខ្លាំងរបស់ក្រុមហ៊ុនមានដូចជា ៖

- មានផែនការយុទ្ធសាស្រ្តគណនេយ្យច្បាស់លាស់៖ ក្នុងការវាយតម្លៃហានិភ័យគណនេយ្យ ការធ្វើសវនកម្មការកំណត់បច្ចេកទេសការចំណាយ
- ការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធាន៖ ការរៀបចំគោលនយោបាយគណនេយ្យអនុញ្ញាតឱ្យមានការតាមដានចំណាយ និងចំណូលយ៉ាងប្រសើរជួយឱ្យអង្គភាពអាចគ្រប់គ្រងធនធានដោយមានផែនការ និងស្ថិរភាព
- ការអនុវត្តតាមច្បាប់និងស្តង់ដាគណនេយ្យ៖ គោលនយោបាយគណនេយ្យជួយអង្គភាពឱ្យអនុវត្តន៍តាមបទប្បញ្ញត្តិច្បាប់ និងស្តង់ដាគណនេយ្យជាតិ ឬអន្តរជាតិ ដើម្បីជៀសវាងការផាកពិន័យ និងបញ្ហាផ្លូវច្បាប់។
- ទទួលបានការឧបត្ថម្ភ ឬអភិវឌ្ឍន៍បច្ចេកទេសពីអង្គការផ្សេងៗ៖ ជួយឱ្យអង្គភាពដឹងច្បាស់ពីនីតិវិធីក្នុងការកត់ត្រា និងរាយការណ៍ជួយកាត់បន្ថយនូវកំហុសនិងការលំបាកក្នុងការអធិប្បាយអំពីទិន្នន័ហិរញ្ញវត្ថុ
- ការទាក់ទាញអ្នកវិនិយោគ៖ ព័ត៌មានហិរញ្ញវត្ថុដែលជាក់លាក់ និងមានស្តង់ដាធ្វើឱ្យអ្នកវិនិយោគមានទំនុកចិត្តច្រើនក្នុងការផ្តល់ធនធាន ឬរួមភាគហ៊ុន
- ជំនួយក្នុងការសម្រេចចិត្តយុទ្ធសាស្រ្តអាជីវកម្ម៖ ព័ត៌មានហិរញ្ញវត្ថុស្របនិងគោលនយោបាយគណនេយ្យនិងជួយឱ្យអ្នកគ្រប់គ្រងធ្វើការសម្រេចចិត្តឱ្យបាននូវយុទ្ធសាស្រ្តច្បាស់លាស់សម្រាប់ការពង្រីកទីផ្សារ ឬ ការវិនិយោគបន្ថែម។

## ៤.២ ការវិភាគចំណុចខ្សោយ

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញដែលទាក់ទងទៅនិងការរៀបចំគោលនយោបាយគណនេយ្យរួចមក ក្រុមនាងខ្ញុំក៏បានរកឃើញមាននូវចំណុចខ្សោយមួយចំនួនដូចខាងក្រោម៖

- ភាពចំរូងចំរាសរវាងគោលការណ៍ជាតិ និងអន្តរជាតិ អាចមានការមិនសមរម្យក្នុងការសម្របសម្រួលនិងស្តង់ដាអន្តរជាតិ បណ្តាលឱ្យមានភាពស្មុកស្មាញក្នុងការអនុវត្ត
- គោលនយោបាយគណនេយ្យមានគោលបំណងល្អ ប៉ុន្តែការបង្ហាញព័ត៌មាន ឬការបញ្ចេញរបាយការណ៍មិនមានភាពបើកចំហ
- ភាពស្មុគស្មាញ និងបច្ចេកទេសខ្ពស់នៃគោលនយោបាយគណនេយ្យធ្វើឱ្យបុគ្គលិកមិនងាយយល់ និងពិបាកអនុវត្តន៍តាមឱ្យបានត្រឹមត្រូវ

- មានការផ្តោតលើអត្ថប្រយោជន៍ ប៉ុន្តែខ្វះការពិភាក្សាអំពីបញ្ហាប្រឈម៖ ដោយផ្តោតលើភាពវិជ្ជមានជាចម្បង ដោយមិនសូវរំលឹកពីបញ្ហាផ្នែកបច្ចេកទេស ឬការអនុវត្តដែលអាចជាបញ្ហាប្រឈមក្នុងការរៀបចំគោលនយោបាយ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

នៅក្នុងការរៀបចំគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពិតជាមានសារៈសំខាន់ដែលបង្ហាញពីចក្ខុវិស័យ របៀបអនុវត្តន៍ និងការរៀបចំផែនការគណនេយ្យដើម្បីធានាថា ការបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុ គឺមានភាពត្រឹមត្រូវ និងស្របតាមបច្ចេកទេសវិជ្ជាជីវៈសវនកម្ម។ ដូចនេះយើងអាចសន្និដ្ឋានបានថា ការរៀបចំគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គឺមានគោលបំណងធានាថាការបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន គឺមានស្តង់ដាជាធរមាន ដោយស្របតាមស្តង់ដាគណនេយ្យជាតិ ឬអន្តរជាតិ ដើម្បីឱ្យអ្នកពាក់ព័ន្ធមានទំនុកចិត្ត។ បើទោះបីជាពេលខ្លះក្រុមហ៊ុន រ.ទ.ស.ភ មានបញ្ហាក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុយ៉ាងណា ក៏ដោយក៏ក្រុមហ៊ុននៅមានលទ្ធភាពស្វែងរកនូវនីតិវិធីដើម្បីដោះស្រាយបានយ៉ាងសមហេតុផល ដោយក្រុមហ៊ុនបានរៀបចំនូវផែនការមួយយ៉ាងច្បាស់លាស់សម្រាប់ក្រុមហ៊ុន ដោយបានប្រើប្រាស់គោលនយោបាយគណនេយ្យមួយច្បាស់លាស់ គឺអាចជួយធ្វើអោយក្រុមហ៊ុនទទួលបាននៅការជឿទុកចិត្ត និងការវិនិយោគពីដៃគូរបានកាន់តែច្រើន និងព្រមទាំងទទួលបាននូវចំណូលកើនឡើងខ្ពស់ជារៀងរាល់ឆ្នាំថែមទៀតផង។ ការសន្និដ្ឋានជាចុងក្រោយក្រុមហ៊ុនជឿជាក់ថា គោលនយោបាយគណនេយ្យដែលបានរៀបចំ និងអនុវត្តន៍នោះមានភាពសមស្របនឹងសកម្មភាពអាជីវកម្មពិតប្រាកដ ហើយវាជួយសម្រួលការសម្រេចចិត្តសម្រាប់អ្នកគ្រប់គ្រងអ្នកវិនិយោគ និងអង្គភាពពាក់ព័ន្ធនានា។

## ៥.២ ការផ្តល់អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើការរៀបចំគោលនយោបាយគណនេយ្យ និងការស្វែងយល់អំពីការអនុវត្តការងារទៅលើការរៀបចំគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។ យើងឃើញថា ក្រុមហ៊ុនពិតជាមានរចនាសម្ព័ន្ធ និងផែនការនៃការរៀបចំគោលនយោបាយគណនេយ្យបានយ៉ាងល្អប្រសើរ ប៉ុន្តែក្រុមហ៊ុនក៏នៅមានចំណុចចន្លោះខ្វះខាតមួយចំនួនផងដែរ ដែលត្រូវលើកយកមកគិតពិចារណា និងធ្វើឱ្យប្រសើរឡើងវិញថែមទៀត។ ទន្ទឹមនឹងនេះផងដែរ ក្រុមរបស់នាងខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

- ភាពចំរូងចំរាសរវាងគោលការណ៍ជាតិ និងអន្តរជាតិ អាចមានការមិនសមរម្យក្នុងការសម្របសម្រួលនិងស្តង់ដារអន្តរជាតិ បណ្តាលឱ្យមានភាពស្មុកស្មាញក្នុងការអនុវត្ត
- គោលនយោបាយគណនេយ្យមានគោលបំណងល្អ ប៉ុន្តែការបង្ហាញព័ត៌មាន ឬការបញ្ចេញរបាយការណ៍មិនមានភាពបើកចំហ
- ភាពស្មុគស្មាញ និងបច្ចេកទេសខ្ពស់នៃគោលនយោបាយគណនេយ្យធ្វើឱ្យបុគ្គលិកមិនងាយយល់ និងពិបាកអនុវត្តន៍តាមឱ្យបានត្រឹមត្រូវ

- មានការផ្តោតលើអត្ថប្រយោជន៍ ប៉ុន្តែខ្វះការពិភាក្សាអំពីបញ្ហាប្រឈម៖ ដោយផ្តោតលើភាពវិជ្ជមានជាចម្បង ដោយមិនសូវរំលឹកពីបញ្ហាផ្នែកបច្ចេកទេស ឬការអនុវត្តដែលអាចជាបញ្ហាប្រឈមក្នុងការរៀបចំគោលនយោបាយ។

ជាចុងបញ្ចប់ ក្រុមនាងខ្ញុំសូមអធ្យាស្រ័យពីសំណាក់ លោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តអ្នកអាន ឬអ្នកស្រាវជ្រាវទាំងអស់ផងដែរ ប្រសិនបើមានកំហុសខុសឆ្គង ខ្វះខាត លើសលួសដោយប្រការណាមួយនោះ ក្រុមនាងខ្ញុំសូមធ្វើការខន្តីអភ័យទោសពីព្រោះនេះគ្រាន់តែជាការលើកបង្ហាញពីការរៀបចំគោលនយោបាយគណនេយ្យលើរបាយការណ៍ហិរញ្ញវត្ថុ ដែលទាំងនេះគ្រាន់តែជាការយល់ដឹងបន្ថែមទៅលើការរៀបចំគោលនយោបាយ និងការធ្វើផែនការតែប៉ុណ្ណោះ វាមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយនោះទេ ប៉ុន្តែវាអាចជាឯកសារសំខាន់មួយដែរ ដើម្បីមានភាពងាយស្រួលសម្រាប់និស្សិតជំនាន់ក្រោយបានសិក្សា និងស្រាវជ្រាវបន្ថែមបន្តពីការរៀបចំគោលនយោបាយរបស់ក្រុមហ៊ុនផ្សេងៗទៀត និងជាមូលដ្ឋានគ្រឹះសម្រាប់ការកែលម្អក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្ររបស់ខ្លួន។ ក្រុមនាងខ្ញុំសូមទទួលនូវការរិះគន់ដើម្បីស្ថាបនានូវរាល់ចំណុចខ្វះខាត និងការយោគយល់អធ្យាស្រ័យពីលោកគ្រូ អ្នកគ្រូដែលបានកែតម្រូវទាំងអស់។

# ឯកសារយោង

# ឯកសារយោង

សៀវភៅសារណារបស់រៀមច្បងយកពីបណ្ណាល័យរបស់ **សាកលវិទ្យាល័យវ៉ាន់ដា**


1. រៀបរៀងដោយនិស្សិត ឈាង ទន្សាយ, ទង គឹមស្រ៊ាន, ពុយ គៀមឡាង, ប៉ាន គា, វុនដាណេ. (២០២៣). *អត្ថប្រយោជន៍នៃការសិក្សាជំនាញគណនេយ្យ*. សារណាបញ្ចប់ថ្នាក់បរិញ្ញាថ្នាក់បត្រ ជំនាញគណនេយ្យ. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៤-៧ ៣៥ទំព័រ។
2. រៀបរៀងដោយនិស្សិត តេន គឹមដង់, កែវ ម៉េងហេងគឹមលាង, ហឿងម៉ុក. (២០១៩). *ការគ្រប់គ្រងគណនេយ្យអាជីវកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត*. សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៦-៧ ៣៧ទំព័រ។
3. KHsearch.com. គ្រប់គ្រង. (2029, March 03). *អ្វីទៅជាផែនការ ?* Retrieved February, 14 2025 from https://www.khsearch.com/qna/17943
4. Wiktionary. (2015). *ប្រវត្តិនៃផែនការ* . Retrieved February, 15 2025 from https://en.wiktionary.org/wiki/pa%C3%B1%C3%B1%C4%81?utm_source=chatgpt.com
5. Wiktionary. (2015). *ទ្រឹស្ដីផែនការ.* Retrieved February, 15 2025 from https://georgiaplanning.org/presentations/AICP_exam_reviews/2007_AICP%20lecture%20on%20theory%20and%20history.pdf?utm_source=chatgpt.com
6. TheBritishAcademy. (2029). *Policy Histories*. Retrieved February, 15 2025 from
7. https://www.thebritishacademy.ac.uk/projects/policy-histories/
8. Reconstructing. PolicyTheoryIn. (1990). *Evaluation and Program Planning*. Printed in the USA. All rights reserved. Page 285-291. Retrieved February, 15 2025 from https//ris.utwente.nl/ws/files/7051421/Hoogerwerf90reconstructing

# ឧបសម្ព័ន្ធ

- Financial Statement
    1. Non-to financial statement



Financial Statement

ក. របាយការណ៍តុល្យការ

# FINANCIAL HIGHLIGHTS

| Financial Position | Fourth Quarter of 2023 | 2022 | 2021 |
|---|---|---|---|
| Total assets (KHR'000) | 3,159,060,323 | 2,684,135,875 | 2,306,806,174 |
| Total liabilities (KHR'000) | 1,764,542,852 | 1,411,922,828 | 1,140,177,961 |
| Total shareholders'equity (KHR'000) | 1,394,517,471 | 1,272,213,047 | 1,166,628,213 |
| **Profit/(Loss)** | **Fourth Quarter of 2023** | **Fourth Quarter of 2022** | **Fourth Quarter of 2021** |
| Total Revenue(KHR'000) | 104,892,531 | 92,266,465 | 92,676,362 |
| Profit/(Loss) before tax (KHR'000) | 40,111,562 | 24,540,708 | 33,065,356 |
| Profit/(Loss) after tax (KHR'000) | 35,194,084 | 22,090,605 | 21,952,861 |
| Total comprehensive income (KHR'000) | 35,194,084 | 22,090,605 | 21,952,861 |

| Financial Ratios | | Fourth Quarter of 2023 | 2022 | 2021 |
|---|---|---|---|---|
| Solvency ratio | | | | |
| Liquidity Ratio | Current Ratio (Times) | 2.67 | 2.21 | 1.65 |
| | Quick Ratio(Times) | 1.45 | 1.46 | 1.11 |
| | | **Fourth Quarter of 2023** | **Fourth Quarter of 2022** | **Fourth Quarter of 2021** |
| Profitabilities Ratio | Return on Assets (%) | 1.14 | 0.84 | 0.97 |
| | Return on Equity (%) | 2.56 | 1.75 | 1.90 |
| | Gross Profit margin (%) | 37.39 | 25.88 | 31.31 |
| | Profit Margin (%) | 33.55 | 23.94 | 23.69 |
| | Earning Per Share (KHR) | 404.65 | 253.99 | 252.41 |
| Interest Coverage Rario (Times) | | 44.98 | 24.25 | 30.04 |

## ខ. របាយការណ៍លទ្ធផល

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**របាយការណ៍លទ្ធផលលម្អិត**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

| | កំណត់សម្គាល់ | ២០២៣ គិតជាពាន់រៀល | ២០២២ គិតជាពាន់រៀល |
|---|---|---|---|
| **ចំណូល៖** | | | |
| ចំណូលពីការផ្គត់ផ្គង់ទឹក | ១៧ | ៣៤៩.៦៤០.០៧៣ | ២៩៩.៧២៣.៥០៧ |
| កម្រៃពីការសាងសង់ | | ១៦.៦៦៥.៦១៧ | ២៤.៩៧៦.៣១៦ |
| ចំណេញពីការប្តូររូបិយប័ណ្ណ - សុទ្ធ | | ៤.១១១.០៣៩ | ១.១០៥.៧០០ |
| ចំណូលផ្សេងៗ | | ២១.៦៣៧.៦៣៦ | ២១.៤៧៨.៣៣៣ |
| | | ៣៩២.០៥៤.៣៦៥ | ៣៤៧.២៨៣.៨៥៦ |
| **ចំណាយ៖** | | | |
| ចំណាយអត្ថប្រយោជន៍របស់និយោជិត | ១៨ | (៨០.២៩២.៤៣៨) | (៧០.១៧៥.៤២២) |
| ចំណាយរំលស់ទ្រព្យសកម្មរូបី និងទ្រព្យសកម្មអរូបី | | (៦១.៩៧៨.១៣៥) | (៥៩.៤៥៥.០៧៤) |
| ចំណាយថ្លៃភ្លើង | | (៤២.២៩១.៤៤៦) | (៣៥.២១៨.៧៤៣) |
| ចំណាយវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត | | (១៥.៨៧៥.៣១៣) | (១២.១៤០.៧៤០) |
| ចំណាយជួសជុល និងថែទាំ | | (១១.៦៥១.០៥៨) | (៨.០០៩.៣៥៨) |
| ចំណាយសេវាសាងសង់ | | (៩.៧៣១.៥១៨) | (១៦.៦១៨.០២៤) |
| ចំណាយវត្ថុធាតុដើមសម្រាប់តភ្ជាប់បណ្តាញទឹកតាមគេហដ្ឋាន | | (៤.៨១៦.៥១៤) | (៤.៩៥៣.៣៧១) |
| ចំណាយប្រតិបត្តិការផ្សេងៗ | | (១៥.១៥៥.៤៣៦) | (១១.២៤៣.៤១៦) |
| | | (២៤១.៧៩១.៨៥៨) | (២១៧.៨១៤.១៤៨) |
| **ចំណេញប្រតិបត្តិការ** | | **១៥០.២៦២.៥០៧** | **១២៩.៤៦៩.៧០៨** |
| ចំណូលហិរញ្ញប្បទាន | | ៦.៧៣៧.៧៦៦ | ៤.៦៥៦.៦១៨ |
| ចំណាយហិរញ្ញប្បទាន | ១៩ | (៣.៥២៧.៧៣០) | (៣.៦១០.៤៣៤) |
| **ចំណេញមុនបង់ពន្ធ** | | **១៥៣.៤៧២.៥៤៣** | **១៣០.៥១៥.៨៩២** |
| ពន្ធលើប្រាក់ចំណូល | ២០ | (២៦.៨៦២.៩៦១) | (២២.៣៣០.០២៧) |
| **ចំណេញក្នុងឆ្នាំ តំណាងឱ្យលទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | | **១២៦.៦០៩.៥៨២** | **១០៨.១៨៥.៨៦៥** |
| | | | |
| ចំណេញក្នុងមួយភាគហ៊ុនរបស់ភាគហ៊ុនិក៖ | | | |
| ចំណេញគោលក្នុងមួយភាគហ៊ុន (គិតជាប្រាក់រៀល) | ២២ | ១.៤៥៥,៧៣ | ១.២៤៣,៩០ |
| ចំណេញថយចុះក្នុងមួយភាគហ៊ុន (គិតជាប្រាក់រៀល) | ២២ | ១.៤៥៥,៧៣ | ១.២៤៣,៩០ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## គ. របាយការណ៍លំហូរសាច់ប្រាក់

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**របាយការណ៍លំហូរសាច់ប្រាក់**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

| | កំណត់សម្គាល់ | ២០២៣ គិតជាពាន់រៀល | ២០២២ គិតជាពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| **ចំណេញមុនបង់ពន្ធ** | | **១៥៣.៤៧២.៥៤៣** | **១៣០.៥១៥.៨៩២** |
| និយ័តកម្មលើ៖ | | | |
| រំលស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | ៦០.១១៥.៣៦៩ | ៥៧.៤៦០.៩២៧ |
| ចំណាយហិរញ្ញប្បទាន | ១៩ | ៣.៥២៧.៧៣០ | ៣.៦១០.៤៣៤ |
| ចំណេញសុទ្ធពីការប្តូររូបិយប័ណ្ណមិនមែនជាសាច់ប្រាក់លើ គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម | | ២.១៤២.៩៤៤ | ៦.១៤០.៦០៦ |
| រំលស់ទ្រព្យសកម្មអរូបី | | ១.៨៥៦.៤៥០ | ១.៩៩៤.១៤៧ |
| ការជម្រះបញ្ជីទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | ១.៦២៨.៤៥៥ | ១៣៦.៨៣៩ |
| ការជម្រះបញ្ជីទ្រព្យសកម្មអរូបី | | ៦.៣១៥ | - |
| ចំណេញសុទ្ធពីការប្តូររូបិយប័ណ្ណមិនមែនជាសាច់ប្រាក់លើ ប្រាក់កម្ចី | | (៩.៩៦៧.៩៥៨) | (៤.៥៨៦.៨៦៦) |
| ចំណូលហិរញ្ញប្បទាន | | (៦.៧៣៧.៧៦៦) | (៤.៦៥៦.៦១៨) |
| រំលស់ជំនួយពន្យាពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | ១៥ | (២.០០៩.៩០៨) | (២.០០៩.៩០៨) |
| **ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | **២០៤.០៣៤.១៧៤** | **១៨៨.៦០៥.៤៥៣** |
| **បម្រែបម្រួលទុនបង្វិល៖** | | | |
| សន្និធិ | | (២៣៨.១៥២.៩៣៨) | (៨៩.៨១៩.២០១) |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | | ៦.១១២.៧០៣ | (៦.១១០.៥២៥) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវទូទាត់ផ្សេងៗ | | ២៣.១៤០.៥២៥ | ៨.៥០៩.៦៩៤ |
| កិច្ចសន្យាទ្រព្យសកម្ម | | (៦២.៧៣២.៨៨១) | (២៦.៧៤៣.៧៩៤) |
| កិច្ចសន្យាបំណុល | | (២០២.៦១៨) | ២.៦៦៧.៨៦២ |
| ប្រាក់កក់ថ្លៃទឹកដែលត្រូវបង្វិលសងវិញ | | ៦.១០២.០២៧ | ៧.៣៥៥.៦៣២ |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ បានពីប្រតិបត្តិការ** | | **(៦១.៦៩៩.០០៨)** | **៨៤.៤៦៥.១២១** |
| ពន្ធលើប្រាក់ចំណូលបានបង់ | | (២០.៩៥៧.២៩៤) | (២២.២៣៣.១៥៧) |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ បានពីសកម្មភាព ប្រតិបត្តិការ** | | **(៨២.៦៥៦.៣០២)** | **៦២.២៣១.៩៦៤** |

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | ២០២៣<br>គិតជាពាន់រៀល | ២០២២<br>គិតជាពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | |
| ការប្រាក់បានទទួល | | ៥.៣៥២.២៤៣ | ២.៩៣៤.៨៩៤ |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | (២៦៩.៨៨៦.៩៤៦) | (២៨១.៦១៩.៧១៦) |
| កំណើនក្នុងការវិនិយោគរយៈពេលខ្លី | | (១.១៩៧.៥៨៧) | (៥៧.៩៥៤.៥៨៣) |
| ការទិញទ្រព្យសកម្មអរូបី | | (២៣៦.២៥២) | (៣៩០.០៧៥) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(២៦៥.៩៦៨.៥៤២)** | **(៣៣៧.០២៩.៤៨០)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | | ៣៤១.៩៨៧.៥៣៧ | ២១៨.២៨០.៤៣៩ |
| ជំនួយទទួលបានពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | ១៥ | ៦.៩៣៤.១៧៧ | ៥៤.៤៣៦.១៩៩ |
| ការបន្ថែមដើមទុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | - | ១.៤៤៣.២២១ |
| ការទូទាត់សងប្រាក់កម្ចី | | (២១.៤៧៩.៤៥៤) | (២០.៧៦៩.៣៨៦) |
| ការប្រាក់បានទូទាត់ | | (១៥.១១១.៤៧៥) | (៧.៤៩១.៨០៤) |
| ភាគលាភបានទូទាត់ | ២៣ | (៤.៣០៥.១៥៨) | (៤.០៤៤.២៥២) |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន** | | **៣០៨.០២៥.៦២៧** | **២៤១.៨៥៤.៤១៧** |
| **ការថយចុះនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | **(៤០.៥៩៩.២១៧)** | **(៣២.៩៤៣.០៩៩)** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមឆ្នាំ** | | **៥៦.៧១៦.៤៣៩** | **៨៩.៦៥៩.៥៣៨** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងឆ្នាំបញ្ចប់** | ១១ | **១៦.១១៧.២២២** | **៥៦.៧១៦.៤៣៩** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ឃ. របាយការណ៍បម្រែបម្រួលមូលធន

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**របាយការណ៍បម្រែបម្រួលមូលធន**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

| | កំណត់សម្គាល់ | ដើមទុន និង បុព្វលាភភាគហ៊ុន គិតជាពាន់រៀល | ទុនបម្រុង គិតជាពាន់រៀល | ចំណេញរក្សាទុក គិតជាពាន់រៀល | មូលធនសរុប គិតជាពាន់រៀល |
|---|---|---|---|---|---|
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | | **៦១៩.៣១៥.៨៨៦** | **៤១៨.០៣៨.៤១០** | **១២៩.២៧៣.៩១៧** | **១.១៦៦.៦២៨.២១៣** |
| ចំណេញក្នុងឆ្នាំ តំណាងឱ្យ លទ្ធផលលម្អិតសរុបក្នុងឆ្នាំ | | - | - | ១០៨.១៨៥.៨៦៥ | ១០៨.១៨៥.៨៦៥ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | |
| ការបន្ថែមដើមទុន | ១២ | ១.៤៤៣.២២១ | - | - | ១.៤៤៣.២២១ |
| ការផ្ទេរទៅគណនីទុនបម្រុង | ១៣ | - | ១២៥.២២៩.៦៦៥ | (១២៥.២២៩.៦៦៥) | - |
| ភាគលាភ | ២៣ | - | - | (៤.០៤៤.២៥២) | (៤.០៤៤.២៥២) |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក សរុប** | | ១.៤៤៣.២២១ | ១២៥.២២៩.៦៦៥ | (១២៩.២៧៣.៩១៧) | (២.៦០១.០៣១) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២/ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | | ៦២០.៧៥៩.១០៧ | ៥៤៣.២៦៨.០៧៥ | ១០៨.១៨៥.៨៦៥ | ១.២៧២.២១៣.០៤៧ |
| ចំណេញក្នុងឆ្នាំ តំណាងឱ្យ លទ្ធផលលម្អិតសរុបក្នុងឆ្នាំ | | - | - | ១២៦.៦០៩.៥៨២ | ១២៦.៦០៩.៥៨២ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | |
| ការផ្ទេរទៅគណនីទុនបម្រុង | ១៣ | - | ១០៣.៨៨០.៧០៧ | (១០៣.៨៨០.៧០៧) | - |
| ភាគលាភ | ២៣ | - | - | (៤.៣០៥.១៥៨) | (៤.៣០៥.១៥៨) |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក សរុប** | | - | ១០៣.៨៨០.៧០៧ | (១០៨.១៨៥.៨៦៥) | (៤.៣០៥.១៥៨) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | **៦២០.៧៥៩.១០៧** | **៦៤៧.១៤៨.៧៨២** | **១២៦.៦០៩.៥៨២** | **១.៣៩៤.៥១៧.៤៧១** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ង. កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុ**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

### ១. ព័ត៌មានអំពី រ.ទ.ស.ភ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ហៅកាត់ថា "រ.ទ.ស.ភ") ស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ហៅកាត់ថា "ក.ស.ហ.វ") ហើយមានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ។ រ.ទ.ស.ភ ត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្មថាជា សហគ្រាសសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រោមលេខចុះបញ្ជីពាណិជ្ជកម្ម Co. ០៨៣៩ Et/២០១២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២។

ការិយាល័យចុះបញ្ជីរបស់ រ.ទ.ស.ភ មានទីតាំងស្ថិតនៅអគារលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពចម្បងរបស់ រ.ទ.ស.ភ គឺការផលិត និងចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ទូទៅរបស់សាធារណជននៅរាជធានីភ្នំពេញ និងតំបន់ក្បែរដែលរួមមានក្រុងតាខ្មៅ ខេត្តត្បូងឃ្មុំ និងមួយចំនួនក្នុងខេត្តកំពត ព្រមទាំងផ្តល់ សេវាផ្សេងៗ។ គោលដៅរបស់ រ.ទ.ស.ភ គឺ៖

- វិនិយោគ កសាង ពង្រីក ដំណើរការ ជួសជុល និងថែទាំមធ្យោបាយសម្រាប់ផលិត និងចែកចាយទឹកស្អាត
- គ្រប់គ្រងបរិក្ខារដើម្បីបង្កើនផលិតកម្មទឹក និងបង្កើនសេវាកម្ម និងគុណភាពទឹកស្អាតដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់
- ដំណើរការអាជីវកម្ម សេវាកម្ម និងភារកិច្ចពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកស្អាត ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ធ្វើសហប្រតិបត្តិការលើផ្នែកបច្ចេកវិទ្យា ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុងស្រុក និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលការណ៍របស់រដ្ឋាភិបាល និង
- ធានាឱ្យបាននូវចីរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុ សម្រាប់ផលប្រយោជន៍សាធារណៈ។

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## កំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ១. ព័ត៌មានអំពី រ.ទ.ស.ភ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ហៅកាត់ថា "រ.ទ.ស.ភ") ស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ហៅកាត់ថា "ក.ស.ហ.វ") ហើយមានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ។ រ.ទ.ស.ភ ត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្មថាជា សហគ្រាសសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រោមលេខចុះបញ្ជីពាណិជ្ជកម្ម Co. ០៨៣៩ Et/២០១២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២។

ការិយាល័យចុះបញ្ជីរបស់ រ.ទ.ស.ភ មានទីតាំងស្ថិតនៅអគារលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពចម្បងរបស់ រ.ទ.ស.ភ គឺការផលិត និងចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ទូទៅរបស់សាធារណជននៅរាជធានីភ្នំពេញ និងតំបន់ក្បែរដែលរួមមានក្រុងតាខ្មៅ ខេត្តត្បូងឃ្មុំ និងម្លេចក្នុងខេត្តកំពត ព្រមទាំងផ្តល់ សេវាផ្សេងៗ។ គោលដៅរបស់ រ.ទ.ស.ភ គឺ៖

- វិនិយោគ កសាង ពង្រីក ដំណើរការ ជួសជុល និងថែទាំមធ្យោបាយសម្រាប់ផលិត និងចែកចាយទឹកស្អាត
- គ្រប់គ្រងបរិក្ខារដើម្បីបង្កើនផលិតកម្មទឹក និងបង្កើនសេវាកម្ម និងគុណភាពទឹកស្អាតដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់
- ដំណើរការអាជីវកម្ម សេវាកម្ម និងភារកិច្ចពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកស្អាត ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ធ្វើសហប្រតិបត្តិការលើផ្នែកបច្ចេកវិទ្យា ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុងស្រុក និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលការណ៍របស់រដ្ឋាភិបាល និង
- ធានាឱ្យបាននូវចីរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុ សម្រាប់ផលប្រយោជន៍សាធារណៈ។

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ




គោលដៅយុទ្ធសាស្រ្តចម្បង របស់ រ.ទ.ស.ក. មានដូចខាងក្រោម៖ ពង្រីកការផ្គត់ផ្គង់ទឹកទៅតំបន់ជុំវិញរាជធានីភ្នំពេញ ដោយរក្សាអត្រា និងស្តង់ដារដូចគ្នា នៅ ក្នុងរាជធានីភ្នំពេញ។ វិភាពថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទដើម្បីកាត់បន្ថយថ្លៃ ដើមទឹក បង្កើនប្រសិទ្ធភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស។ តាំងចិត្តខ្ពស់ចំពោះការទទួលខុសត្រូវដល់សង្គម និងបរិស្ថានប្រៀបធៀបបែបយុទ្ធសាស្រ្តជាមួយ បណ្តាអង្គភាពទឹកស្អាតនានា ដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក។



ទីស្នាក់ការលេខ៤៥
ផ្លូវលេខ១០៦
សង្កាត់ស្រះចក
ខណ្ឌដូនពេញ
រាជធានីភ្នំពេញ

លេខទូរស័ព្ទ: ០៩៨ ៥៨៩ ១៩៤
លេខទូរស័ព្ទ: ០១២ ៨៩៨ ៨០៤

WEBSITE PPWSA

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ត្រីមាសទី១ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|---|
| ទ្រព្យសកម្មសរុប(ពាន់រៀល) | ២.៧៥៤.០០៤.០៦១ | ២.៦៨៤.១៣៥.៨៧៥ | ២.៣០៦.៨០៦.១៧៤ |
| បំណុលសរុប(ពាន់រៀល) | ១.៤៤៧.៦៨៥.៧៨៧ | ១.៤១១.៩២២.៨២៨ | ១.១៤០.១៧៧.៩៦១ |
| មូលធនសរុប(ពាន់រៀល) | ១.៣០៦.៣១៨.២៧៤ | ១.២៧២.២១៣.០៤៧ | ១.១៦៦.៦២៨.២១៣ |

| លទ្ធផលហិរញ្ញវត្ថុ | ត្រីមាសទី១ ឆ្នាំ២០២៣ | ត្រីមាសទី១ ឆ្នាំ២០២២ | ត្រីមាសទី១ ឆ្នាំ២០២១ |
|---|---|---|---|
| ចំណូលសរុប(ពាន់រៀល) | ៨៣.០១១.៦១៣ | ៨២.០២០.០១០ | ៨៤.៣០៤.៧២៦ |
| ចំណេញមុនបង់ពន្ធប្រាក់ចំណូល(ពាន់រៀល) | ៤១.៧៤១.៦៥០ | ៤០.៦៨៦.២៦៩ | ៤២.៤១៦.០៣៩ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ(ពាន់រៀល) | ៣៨.៤១០.៣៨៥ | ៣០.២៩១.៧៤៩ | ៣០.៧៧១.៦០៩ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ(ពាន់រៀល) | ៣៨.៤១០.៣៨៥ | ៣០.២៩១.៧៤៩ | ៣០.៧៧១.៦០៩ |

| អនុបាតហិរញ្ញវត្ថុ | | ត្រីមាសទី១ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|---|---|
| **អនុបាតសាធនភាព** | | | | |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត(ចំនួនដង) | ២,១៤ | ២,២១ | ១,៦៥ |
| | អនុបាតចរន្តលឿន(ចំនួនដង) | ១,៤៨ | ១,៤៦ | ១,១១ |

| | | ត្រីមាសទី១ ឆ្នាំ២០២៣ | ត្រីមាសទី១ ឆ្នាំ២០២២ | ត្រីមាសទី១ ឆ្នាំ២០២១ |
|---|---|---|---|---|
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម(ភាគរយ) | ១,៤១ | ១,២៨ | ១,៦០ |
| | អនុបាតចំណេញធៀបនឹងមូលធន(ភាគរយ) | ២,៩៨ | ២,៥៧ | ៣,០០ |
| | អនុបាតគម្លាតចំណេញដុល(ភាគរយ) | ៣២,៣៧ | ៣៩,០៦ | ៤១,០២ |
| | អនុបាតគម្លាតចំណេញភាព(ភាគរយ) | ៤៦,២៧ | ៣៦,៩៣ | ៣៦,៥០ |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ(រៀល) | ៤៤១,៦៣ | ៣៤៨,២៩ | ៣៥៣,៨១ |
| អនុបាតលទ្ធភាពសងការប្រាក់ (ចំនួនដង) | | ២២,៨២ | ៣៩,១៥ | ១១៥,៧១ |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប

## បម្រែបម្រួលតម្លៃភាគហ៊ុន (គិតជារៀល) និងទំហំជួញដូរ




## ប្រាក់ចំណេញតាមបណ្តាឆ្នាំនីមួយៗ (លានរៀល)




## ប្រាក់ចំណេញសម្រាប់ត្រីមាសទី១ ឆ្នាំ២០២៣ (លានរៀល)



# ឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំ២០២៣
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
# របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ

## ផ្នែកទី១. ភាគហ៊ុនិក

ក- រចនាសម្ព័ន្ធភាគហ៊ុនិក(**គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**)

### ១. ព័ត៌មានភាគហ៊ុនិក

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៣.៩០៦ | ៤.៨២៣.៧៤០ | ៥,៥៤៦% |
| | | នីតិបុគ្គល | ៦ | ២.៥៣៥.៨៦២ | ២,៩១៦% |
| | មិនមែន | រូបវន្តបុគ្គល | ៥៩៨ | ៥.២៣៣.០៣២ | ៦,០១៧% |
| | សញ្ជាតិខ្មែរ | នីតិបុគ្គល | ៦ | ៤៥៣.៣៤១ | ០,៥២១% |
| ចាប់ពី៥% ដល់តិចជាង ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមែន | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | សញ្ជាតិខ្មែរ | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| ចាប់ពី ៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ៧៣.៩២៧.១៨៧ | ៨៥% |
| | មិនមែន | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | សញ្ជាតិខ្មែរ | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |

### ២. ភាគហ៊ុនិកជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត រ.ទ.ស.ភ

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ២ | ២០.២១៦ | ០,០២៣% |
| បុគ្គលិកជាន់ខ្ពស់ | ២០ | ១២៥.៩០០ | ០,១៤៥% |
| និយោជិត | ៣៨៣ | ៧០៧.៩០៦ | ០,៨១៤% |
| **សរុប** | **៤០៥** | **៨៥៤.០២២** | **០,៩៨២%** |

# ផ្នែកទី១. ភាគហ៊ុនិក (ត)

## ខ- សិទ្ធិរបស់ភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាហ៊ុនិក

### ១. សិទ្ធិរបស់ភាគហ៊ុនិក

ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ មានសិទ្ធិស្មើៗគ្នា ដែលសិទ្ធិទាំងនោះរួមមាន៖

- សិទ្ធិទទួលបានព័ត៌មានដែលផ្តល់ដោយ រ.ទ.ស.ភ ស្របតាមច្បាប់ និងបញ្ញតិជាធរមាន។
- សិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិករបស់ រ.ទ.ស.ភ ដោយត្រូវអនុវត្តតាមសេចក្តីណែនាំសម្រាប់ការចូលរួមមហាសន្និបាតភាគហ៊ុនិក។
- សិទ្ធិបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក ដោយត្រូវអនុវត្តតាមសេចក្តីណែនាំសម្រាប់ការចូលរួមមហាសន្និបាតភាគហ៊ុនិក។
- សិទ្ធិទទួលភាគលាភ ដែលប្រកាសដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ តាមសមាមាត្រភាគហ៊ុនដែលខ្លួនកាន់កាប់។
- សិទ្ធិក្នុងការទទួលនូវទ្រព្យដែលនៅសេសសល់របស់ រ.ទ.ស.ភ នៅពេលមានការរំលាយតាមសមាមាត្រភាគហ៊ុន។
- សិទ្ធិផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងបញ្ញតិជាធរមាន។

### ២. ការការពារសិទ្ធិរបស់ភាគហ៊ុនិក និងការអនុវត្តក្នុងឆ្នាំ២០២៣

សិទ្ធិរបស់ភាគហ៊ុនិករបស់ រ.ទ.ស.ភ ត្រូវបានការពារដោយលក្ខន្តិកៈរបស់ រ.ទ.ស.ភ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ និងតាមរយៈការបង្កើតឱ្យមាននូវ ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់។

ក្នុងឆ្នាំ២០២៣ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី១១ ដែលប្រព្រឹត្តិទៅកាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ ដែលភាគហ៊ុនិកទាំងអស់ ទទួលបានព័ត៌មានស្មើគ្នា មានសិទ្ធិចូលរួមស្មើគ្នា ដោយគោរពតាមនីតិវិធី នៃការចូលរួមមហាសន្និបាតភាគហ៊ុនិក របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងធ្វើការបោះឆ្នោតលើរបៀបវារៈ ដែលបានលើកឡើង។

ទន្ទឹមនេះដែរ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក៏បានធ្វើការបែងចែកភាគលាភប្រចាំឆ្នាំ២០២២ ជូនដល់ភាគហ៊ុនិករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដោយធ្វើការទូទាត់នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ កន្លងមក។

### ៣. ការការពារសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច និងការអនុវត្តក្នុងឆ្នាំ២០២៣

ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិចរបស់ រ.ទ.ស.ភ ទទួលបានស្មើគ្នានូវការការពារ និងការអនុវត្តដូចទៅនឹងភាគហ៊ុនិកដទៃដូចបានរៀបរាប់ខាងលើ ដោយពុំមានការរើតត្បិតសិទ្ធិណាមួយទេ។

## គ- មហាសន្និបាតភាគហ៊ុនិក

### ១. នីតិវិធីនៃការរៀបចំសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត

ការរៀបចំមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោតត្រូវបានអនុវត្តទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។

# ផ្នែកទី១. ភាគហ៊ុនិក (ត)

## គ- មហាសន្និបាតភាគហ៊ុនិក (ត)

### ២. ព័ត៌មានមហាសន្និបាតភាគហ៊ុនិកលើកទី១១

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | កូរ៉ុមនៃកិច្ចប្រជុំ | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|---|
| ១ | ២៦ ឧសភា ២០២៣ | សាមញ្ញ | ១៨០នាក់ (៧៥.៧៦៦.៤៤៨ ភាគហ៊ុន) ស្មើនឹង៩៩,៦៥% | ១.របាយការណ៍លទ្ធផលអាជីវកម្មឆ្នាំ២០២២ និងទិសដៅអាជីវកម្មឆ្នាំ២០២៣<br>២.សំនួរ-ចម្លើយ<br>៣.កម្មវិធីបោះឆ្នោតអនុម័តលើ៖<br>➢ ការបោះឆ្នោតអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២២<br>➢ ការអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល ឆ្នាំ២០២៣ | លទ្ធផលនៃការបោះឆ្នោត៖<br>➢ ឯកភាពបែងចែកភាគលាភឆ្នាំ២០២២ ដែលបានមកពីប្រាក់ចំណេញឆ្នាំ២០២២ គិតជាសាច់ប្រាក់ចំនួន ២៨.៧០១.១៤៣.៤៦០រៀល៖<br>▪ ចំនួន ៣៣០ រៀលក្នុង១ភាគហ៊ុន<br>▪ កាលបរិច្ឆេទកំណត់ទុកៈថ្ងៃទី៩ខែមិថុនា ឆ្នាំ២០២៣<br>▪ កាលបរិច្ឆេទទូទាត់: ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ខែមិថុនា ឆ្នាំ២០២៣<br>➢ ឯកភាពលើលាភការរបស់ក្រុមប្រឹក្សាភិបាល ៧រូប និងមន្រ្តីត្រួតពិនិត្យរដ្ឋ ១រូប សម្រាប់ឆ្នាំ ២០២៣ ដែលមានទឹកប្រាក់សរុបចំនួន ១.១០៧.៩៧៩.០០០រៀល។ |

## ឃ- ការបែងចែកភាគលាភ

### ១- គោលនយោបាយបែងចែកភាគលាភ

ក្រោយពីបានអនុម័តលើគណនី បើពិនិត្យឃើញថាមានចំណេញ ក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ អាចសម្រេចផ្ទេរទឹកប្រាក់ទាំងនោះដើម្បី៖

១.១. ការទូទាត់ការខាតបង់នៅក្នុងឆ្នាំកន្លងទៅ

១.២. បន្ទាប់ពីបានទូទាត់ការខាតបង់នៅក្នុងឆ្នាំកន្លងទៅរួច ប្រសិនបើមានប្រាក់ចំណេញ នោះប្រាក់ចំណេញនេះត្រូវបែងចែកសម្រាប់៖

ក ថ្លែងសរសើរដល់ថ្នាក់ដឹកនាំ និងនិយោជិត តាមលក្ខខណ្ឌ៖

- ក្នុងករណីប្រាក់ចំណេញនៅសល់មានចំនួនពី ៥% ដល់ ១០% នៃចំណាយដំណើរការរបស់ រ.ទ.ស.ភ សរុបក្នុងឆ្នាំ នោះការថ្លែងសរសើរត្រូវស្មើនឹងមួយខែនៃប្រាក់បៀវត្សសុទ្ធសាធរបស់ថ្នាក់ដឹកនាំ និងនិយោជិតម្នាក់ៗ។
- ក្នុងករណីប្រាក់ចំណេញលើសពី ១០% ដល់ ២០% នៃចំណាយដំណើរការរបស់ រ.ទ.ស.ភ សរុបក្នុងឆ្នាំ នោះការថ្លែងសរសើរត្រូវស្មើនឹងពីរខែនៃប្រាក់បៀវត្សសុទ្ធសាធរបស់ថ្នាក់ដឹកនាំ និង និយោជិតម្នាក់ៗ។
- ក្នុងករណីប្រាក់ចំណេញលើសពី ២០% នៃចំណាយដំណើរការរបស់ រ.ទ.ស.ភ សរុបក្នុងឆ្នាំ នោះការថ្លែងសរសើរត្រូវស្មើនឹងបីខែនៃប្រាក់បៀវត្សសុទ្ធសាធរបស់ថ្នាក់ដឹកនាំ និងនិយោជិតម្នាក់ៗ។

ខ ចំនួន ២% សម្រាប់ប្រាក់សោធននិវត្ត និងអសមត្ថភាពវិជ្ជាជីវៈ។

គ បង្កើតភាគបម្រុងតាមច្បាប់ ៥%។

ឃ បង្កើតភាគបម្រុងសេរីចំនួន ៥%។

ង មូលនិធិ ៥% លើប្រាក់ចំណេញសម្រាប់បម្រើផលប្រយោជន៍សង្គម ដែលត្រូវកត់ត្រាចូលក្នុងបន្ទុកក្នុងឆ្នាំដែលធ្វើប្រតិបត្តិការចំណាយនោះ។



**ឯកឧត្តម ស៊ឹម ស៊ីថា**
រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍

**ប្រធានក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម ឈុំ ណារ៉ុ**
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

**សមាជិកក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម ម៉ី ផាន់**
រដ្ឋលេខាធិការ
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សមាជិកក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម ឌុន ផារ៉ុត**
អភិបាលរងនៃគណៈអភិបាល
រាជធានីភ្នំពេញ

**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក ម៉ា ណុវ៉ាទិន**
តំណាងនិយោជិត
នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក ណាំ ចន្ទ្រី**
អភិបាលមិនប្រតិបត្តិតំណាង
ភាគហ៊ុនិកឯកជន

**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក ស្រេង សំអិត**
អភិបាលឯករាជ្យ

**សមាជិកក្រុមប្រឹក្សាភិបាល**

# ហត្ថលេខាអភិបាល
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ថ្ងៃ ចន្ទ ១រោច ខែជេស្ឋ ឆ្នាំថោះ
បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤
បានអាន និងឯកភាព

ហត្ថលេខា
**ស៊ឹម ស៊ីថា**
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃ ចន្ទ ១រោច ខែជេស្ឋ ឆ្នាំថោះ
បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤
បានអាន និងឯកភាព

ហត្ថលេខា
**ឡុង ណារ៉ូ**
អភិបាល

ថ្ងៃ ចន្ទ ១រោច ខែជេស្ឋ ឆ្នាំថោះ
បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤
បានអាន និងឯកភាព

ហត្ថលេខា
**ម៉ី អ៊ាន់**
អភិបាល

ថ្ងៃ ចន្ទ ១រោច ខែជេស្ឋ ឆ្នាំថោះ
បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤
បានអាន និងឯកភាព

ហត្ថលេខា
**ឡូន ផារ័ត្ន**
អភិបាល

ថ្ងៃ ចន្ទ ១រោច ខែជេស្ឋ ឆ្នាំថោះ
បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤
បានអាន និងឯកភាព

ហត្ថលេខា
**ម៉ា ណូរ៉ាមីន**
អភិបាល

ថ្ងៃ ចន្ទ ១រោច ខែជេស្ឋ ឆ្នាំថោះ
បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤
បានអាន និងឯកភាព

ហត្ថលេខា
**ណាំ ចន្ទ្រី**
អភិបាល

ថ្ងៃ ចន្ទ ១រោច ខែជេស្ឋ ឆ្នាំថោះ
បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤
បានអាន និងឯកភាព

ហត្ថលេខា
**ស្រេង សំនិក**
អភិបាល

*លេខបញ្ជីពាណិជ្ជកម្ម៖ Co.០៤៣៩ Et/២០១២*

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

### សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

យើងខ្ញុំ ឯកឧត្តម ស៊ីម ស៊ីថា ឯកឧត្តម ឡុង ណារ៉ូ និងលោក ដេង ប៉ូលីដែន ជាអភិបាល និងមន្ត្រី នៅក្នុងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ("រ.ទ.ស.ភ") សូមបញ្ជាក់ថាតាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ រ.ទ.ស.ភ នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ និងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល និងរបាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល សម្រាប់ត្រីមាស និងរយៈពេល៣ខែ ដែលបានបញ្ចប់ និងកំណត់សម្គាល់លើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលដែលពាក់ព័ន្ធ (ត្រូវបានគេស្គាល់ថាជា "ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល") បានបង្ហាញនូវភាពសមស្របគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា លេខ ៣៤ ស្តីពី *"របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល"*។

ចុះហត្ថលេខាជំនួសក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រង

**ឡុង ណារ៉ូ**
អគ្គនាយក

**ដេង ប៉ូលីដែន**
អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច

**ស៊ីម ស៊ីថា**
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃសុក្រ ៨រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣